ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 29-Feb-2016, 10:35
CMS/CFO: Sann Rada

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**

Trial Chamber
Chambre de Premiere instance

**កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី**

**ជំនុំជម្រះក្ដីនៅជំណាក់កាលពីរ**

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៦**

**ម៉ោង ០៩:១០នាទី**

**សវនាការលើកទី៣៧១**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ម៉ាដាឡេណា ហ្គេហ្ស៊ី
*(Ms. Maddalena Ghezzi)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

លោក វីល្លៀម ស្មីត *(Mr. William SMITH)*

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោក ឡៅ ជុនធី

លោក ហុង គឹមសួន

លោក វ៉េន ពៅ

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី សួ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ា ឡាវែន៍ | បារាំង |
| លោក សេង ប៊ុនឃាង | ខ្មែរ |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក វីល្លៀម ស្មីត | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |

# កិច្ចដំណើរការនីតិវិធី

[០៩:១០:១៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការលើការដាក់បង្ហាញឯកសារគន្លឹះ ពាក់ព័ន្ធទៅនឹងអង្គហេតុនៃការប្រព្រឹត្តចំពោះក្រុមមនុស្សគោលដៅជាក់លាក់ ជនជាតិចាម ជនជាតិវៀតណាម និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ។ សវនាការនេះ មានរយៈពេល៣ថ្ងៃ ដែលនៅថ្ងៃនេះ នៅថ្ងៃស្អែក អង្គជំនុំជម្រះនឹងអនុញ្ញាតឲ្យភាគីដាក់បង្ហាញឯកសារគន្លឹះរបស់ខ្លួន។ រួចហើយភាគីទាំងអស់មានរយៈពេលមួយថ្ងៃគឺថ្ងៃ២៥ ខែកុម្ភៈ ឆ្នាំ២០១៦ ដើម្បីត្រៀមការឆ្លើយតប ឬការកត់សម្គាល់ចំពោះឯកសាររបស់ភាគីផ្សេងទៀតដែលបានដាក់បង្ហាញ។ ការឆ្លើយតប ឬក៏កត់សម្គាល់នេះ ដែលនឹងធ្វើឡើងនៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៦។

ហើយក្រឡាបញ្ជីសវនាការ លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមានអវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន។ សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន។ លើកលែងតែលោក វ៉ិចទ័រ កូប៉េ មេធាវីអន្តរជាតិការពារក្តីឲ្យលោក នួន ជា អវត្តមានដោយមិនមានមូលហេតុ។ ដោយឡែក លោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សូមអរគុណលោកប្រធាន។

[០៩:១២:០៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់

សវនាការនេះ របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៦។

ហើយបានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាល ថែទាំសុខភាពជនជាប់ចោទ នៅអ.វ.ត.ក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៦ បានកត់សម្គាល់ពីស្ថានភាពសុខភាព របស់លោក នួន ជា ថានៅថ្ងៃនេះថា មានអាការៈឈឺចង្កេះវិលមុខ ហើយមិនអាចអង្គុយយូរបាន និងផ្តល់អនុសាសន៍ថា សុំឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

ហើយដោយផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

[០៩:១៣:២១]

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនស្ថិតនៅក្រោមសាលសវនាការនេះក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ហើយអង្គជំនុំជម្រះមុននឹងចាប់ដំណើរការ ក៏សូមបញ្ជាក់ផងដែរថា អង្គជំនុំជម្រះបានទទួលនូវសំណើបញ្ជាក់វិញក បញ្ជាក់ថ្មីមួយតាមរយៈអ៊ីម៉ែល មកអង្គជំនុំជម្រះសូមឲ្យអង្គជំនុំជម្រះទទួលយកនូវឯកសារមួយរបស់សហព្រះរាជអាជ្ញា ដោយអនុវត្តតាមវិធាន៨៧(៤)នៃវិធានផ្ទៃក្នុង។ ហើយដែលសំណើនេះបានដាក់តាំងពីខែវិច្ឆិកា ឆ្នាំ២០១៥។ ហើយរហូតមកដល់ពេលនេះ អង្គជំនុំជម្រះមិនទាន់បានសម្រេចនៅឡើយទេ អង្គជំនុំជម្រះសូមជម្រាបជូនថា ដោយសារបញ្ហានេះ ទើបតែទទួលបានព័ត៌មានបន្ទាន់ ដូច្នេះអង្គជំនុំជម្រះនឹងយកបញ្ហានេះ ពិចារណាសម្រេចនៅក្រោយពេលសម្រាកនៅព្រឹកនេះ។ សូមខាងតំណាងសហព្រះរាជអាជ្ញាជ្រាប។

ដើម្បីឲ្យសវនាការនៃការដាក់បង្ហាញឯកសារគន្លឹះនាពេលនេះ ប្រព្រឹត្តទៅបានរលូន ចៀសវាង

ការភ័ន្តច្រឡំទៅលើខ្លឹមសារនៃសវនាការនេះ ដូចដែលធ្លាប់បានកើតមានពីសវនាការបង្ហាញឯកសារគន្លឹះពីមុនៗមក អង្គជំនុំជម្រះបានចេញអនុស្សរណៈមួយ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៦ (ឯកសារ E315/2) ដែលនៅក្នុងនោះ អង្គជំនុំជម្រះបានបញ្ជាក់រំឭកបំភ្លឺថា អង្គជំនុំជម្រះមានបំណងឲ្យភាគីផ្តោតលើការបង្ហាញឯកសារទាំងឡាយដែលពាក់ព័ន្ធទៅនឹង ពាក់ព័ន្ធដោយផ្ទាល់ជាមួយនឹងអង្គហេតុនៃការជំនុំជម្រះ។

[០៩:១៥:១១]

ភាគីអាចជ្រើសរើសការបង្ហាញកំណត់ហេតុស្តាប់ចម្លើយ ឬក៏ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមកដាក់បង្ហាញបាន ប្រសិនបើភាគីមានបំណងធ្វើដូច្នេះ។ អង្គជំនុំជម្រះនឹងអនុញ្ញាតឲ្យផ្តល់ភាពបទបែនបន្ថែម ហើយនិងផ្តល់សិទ្ធិឲ្យភាគីបង្ហាញឯកសារទាំងឡាយដែលជាប់ពាក់ព័ន្ធនឹងគោលនយោបាយនៅក្នុងកម្រិតថ្នាក់ជាតិបាន ទោះបីជាអង្គជំនុំជម្រះកត់សម្គាល់ឃើញថា ឯកសារទាំងនោះទំនងសមស្របជាង សម្រាប់អង្គហេតុនៃការជំនុំជម្រះស្តីពីតួនាទីរបស់ជនជាប់ចោទក៏ដោយ។

ទោះបីជាការទទួលស្គាល់ថា អង្គជំនុំជម្រះពិបាកនឹងបញ្ចៀសមិនឲ្យលើកឡើងពីការផ្តល់យោបល់លើតម្លៃភ័ស្តុតាងនៃឯកសារក៏ដោយ ក៏អង្គជំនុំជម្រះលើកទឹកចិត្តឲ្យភាគីផ្តោតជាសំខាន់លើការបង្ហាញឯកសារគន្លឹះ (ប្រតិចារឹកសវនាការថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៥ ទំព័រ១៤, ១៥)។

មានតែឯកសារដែលបានទទួលស្គាល់រួចហើយប៉ុណ្ណោះ ដែលអាចយកមកដាក់បង្ហាញនៅក្នុងអំឡុងពេលនៃដំណើរការសវនាការទាំងនេះ។ ឯកសារដែលបានទទួលមកពីការធ្វើទារុណកម្មត្រូវគោរពតាមសេចក្តីសម្រេចទាំងឡាយ ពីមុនរបស់អង្គជំនុំជម្រះទៅលើការប្រើប្រាស់ភ័ស្តុតាងបែបនេះ។ ត្រង់ចំណុចនេះ កាលពីថ្ងៃសុក្រ ទី០៥ ខែកុម្ភៈ ឆ្នាំ២០១៦ អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចផ្អែកលើមតិភាគច្រើន ក្នុងការប្រើប្រាស់ភ័ស្តុតាងដែលបានមកពីការធ្វើទារុណកម្ម (ឯកសារ E350/8)។

មួយវិញទៀត អង្គជំនុំជម្រះក៏ធ្លាប់បានរំឭកភាគីទាំងអស់ជាច្រើនដងហើយថាសវនាការបង្ហាញឯកសារគន្លឹះ ពុំមែនជាសវនាការស្តីពីភាពអាចទទួលយកបាននៃភ័ស្តុតាងឡើយ។ ហេតុដូច្នេះ ភាគីពាក់ព័ន្ធមិនគប្បីពិភាក្សាពីភាពអាចទទួលយកបាន ឬមិនអាចទទួលបាននៃឯកសារនៅក្នុងសវនាការនេះទេ ពីព្រោះភាគីត្រូវបានផ្តល់ឱកាសឲ្យធ្វើការជំទាស់ ក៏ដូចជាការឆ្លើយតបទៅនឹងការជំទាស់ជាលាយលក្ខណ៍អក្សររួចហើយ ទៅលើបណ្តាឯកសារទាំងឡាយដែលត្រូវបានដាក់សម្រាប់ជំនុំជម្រះសំណុំរឿង ០០២/០២នេះ (ឯកសារ E327 ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៤)។

[០៩:១៧:២៨]

នៅក្នុងអនុស្សរណៈ E315/2 អង្គជំនុំជម្រះបានស្នើភាគីដែលមានបំណងដាក់បង្ហាញឯកសារត្រូវជូនដំណឹងមកអង្គជំនុំជម្រះពីចេតនានៃការដាក់បង្ហាញឯកសារគន្លឹះ និងការឆ្លើយតប ឬការកត់សម្គាល់តបទៅនឹងបណ្ដាឯកសាររបស់ភាគីផ្សេងទៀត ប្រសិនបើពួកគេមានបំណងធ្វើដូច្នេះ យ៉ាងយូរបំផុតត្រឹមថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៦។

ដូចគ្នានេះដែរ អង្គជំនុំជម្រះក៏បានណែនាំឲ្យភាគីផ្ដល់ឯកសារដែលខ្លួនមានបំណងចង់បង្ហាញមកអង្គជំនុំជម្រះ និងភាគីផ្សេងទៀត ឲ្យបានមុនពេលចាប់ផ្ដើមសវនាការ និងយ៉ាងយូរបំផុតត្រឹមម៉ោងមួយកន្លះរសៀល ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៦ ព្រមជាមួយលេខយោង ERNនៅគ្រប់ភាសាដែលមាន។

សហព្រះរាជអាជ្ញា សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងក្រុមសហមេធាវីការពារក្ដី ខៀវ សំផន បានឆ្លើយតបមកអង្គជំនុំជម្រះថា ពួកគេមានបំណងបង្ហាញឯកសារ និងឆ្លើយតប ឬកត់សម្គាល់ទៅលើបណ្ដាឯកសារដែលដាក់បង្ហាញដោយភាគីផ្សេងទៀត។ ភាគីទាំងនេះបានផ្ដល់បញ្ជីឯកសារគន្លឹះរបស់ខ្លួនទៅតាមការណែនាំរបស់អង្គជំនុំជម្រះ ដោយឡែកក្រុមសហមេធាវីការពារក្ដី នួន ជា បានបញ្ជាក់ថា ក្រុមខ្លួនមិនមានបំណងបង្ហាញឯកសារណាមួយ ហើយក៏មានបំណងឆ្លើយតប ឬក៏កត់សម្គាល់ទៅលើបណ្ដាឯកសារដែលបានដាក់បង្ហាញដោយភាគីផ្សេងទៀតដែរ។

សម្រាប់សវនាការក្នុងការដាក់បង្ហាញឯកសារគន្លឹះនេះ ភាគីនីមួយៗ មានពេលវេលាកន្លះថ្ងៃនៃសវនាការ ដើម្បីបង្ហាញឯកសារគន្លឹះរបស់ខ្លួនពាក់ព័ន្ធនឹងការប្រព្រឹត្តទៅលើក្រុមគោលដៅទាំងបីខាងទៅតាមលំដាប់លំដោយដែលខ្លួនយល់ឃើញថាសមស្រប។

[០៩:១៩:១៣]

ការបង្ហាញឯកសារគន្លឹះ នឹងចាប់ផ្ដើមមុនដំបូងគេ ដោយសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី បន្ទាប់មកក្រុមមេធាវីការពារក្ដី ខៀវ សំផន។ ក្រោយការបង្ហាញឯកសារ ក្រុមមេធាវីការពារក្ដី ខៀវ សំផន សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានរយៈពេលកន្លះថ្ងៃ ដើម្បីធ្វើការឆ្លើយតប ឬការធ្វើការកត់សម្គាល់លើបណ្ដាឯកសាររបស់ក្រុមមេធាវីការពារក្ដី ខៀវ សំផន។ ហើយចុងក្រោយ ចុងបញ្ចប់នៃការសវនាការ ក្រុមមេធាវីការពារក្ដី ខៀវ សំផន ឬជនជាប់ចោទ ខៀវ សំផន មានរយៈពេល១វគ្គនៃសវនាការសម្រាប់ធ្វើការឆ្លើយតបចុងក្រោយទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើម

បណ្តឹងរដ្ឋប្បវេណី។

ហើយអ៊ីម៉ែលហ្នឹង បានបញ្ជាក់បន្ថែមថា តាមរយៈមន្ត្រីច្បាប់ជាន់ខ្ពស់សាលាដំបូង កាលថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ២០១៦ ពាក់ព័ន្ធនឹងការកែសម្រួលពេលវេលានៃការបង្ហាញឯកសារ និងឆ្លើយតបបន្ទាប់ពីក្រុមមេធាវីការពារក្តី នួន ជា បានបង្ហាញជំហរថាខ្លួនមិនមានឯកសារត្រូវដាក់បង្ហាញ និងមិនមានការបំណងក្នុងការឆ្លើយតប ឬក៏កត់សម្គាល់តបទៅនឹងឯកសារភាគីផ្សេងទៀតទេ។

ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវី -- តំណាងសហព្រះរាជអាជ្ញា ដើម្បីធ្វើការដាក់បង្ហាញឯកសារគន្លឹះរបស់ខ្លួន។ បាទសូមអញ្ជើញ!

សហព្រះរាជអាជ្ញារងជាតិ កុំអាលសិន! មានបញ្ហាបន្តិច។

សូមអញ្ជើញលោកស្រី អង់តា ស្តីសសេ!

[០៩:២០:៥៧]

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណ។ ខ្ញុំមិននិយាយអ្វីវែងឆ្ងាយទេ គ្រាន់តែចង់ធ្វើការកត់សម្គាល់បន្តិច ដើម្បីទាញចំណាប់អារម្មណ៍អង្គជំនុំជម្រះ និងភាគី ជាពិសេសសហព្រះរាជអាជ្ញាទៅលើបញ្ហាមួយ។ លោកប្រធាន លោកប្រធានបានរំឭកអំពីខ្លឹមសារនៃអនុស្សរណៈរបស់ខ្លួន ដោយសារពន្យល់ថា ភាគីត្រូវផ្តល់កាលពីម្សិលមិញនៅម៉ោងមួយកន្លះ ដើម្បីបង្ហាញបញ្ជីដែលខ្លួនចង់បង្ហាញ។ ហើយភាគីទាំងអស់បានគោរពតាម រយៈពេលនេះ លើកលែងតែសហព្រះរាជអាជ្ញា។ ខ្ញុំគ្រាន់តែចង់បញ្ជាក់ ពេលកំណត់ត្រឹមម៉ោងមួយកន្លះនេះ គឺដើម្បីឲ្យភាគីពិនិត្យមើលឯកសារ ដើម្បីដកស្រង់ឃ្លាឃ្លោង ហើយនិងពិនិត្យ ERN ផ្សេងៗ ហើយនៅពេលដែលមានការយឺតយ៉ាវដូចដែលសហព្រះរាជអាជ្ញាបានលើកធ្វើឡើងនោះ វាមានផលប៉ះពាល់ទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន។ ខ្ញុំមិនដឹងថាដើមបណ្តឹងយ៉ាងម៉េចទេ ក៏ប៉ុន្តែពួកយើងគឺមានផលប៉ះពាល់។

ហើយអ៊ីចឹងមានន័យថា ដើម្បីឲ្យយើងមានពេលគ្រប់គ្រាន់ដើម្បីពិនិត្យការងាររបស់យើង ដូច្នេះខ្ញុំចង់ទាក់ទាញចំណាប់អារម្មណ៍ភាគីទាំងអស់លើចំណុចនេះ ពីព្រោះថានឹងមានបញ្ហាសវនាការទៅលើឯកសារបែបហ្នឹងទៀត ហើយនៅពេលដែលមានភាគីមួយផ្តល់បញ្ជីយឺតយ៉ាវរយៈពេលវែងអ៊ីចឹង មានន័យថា ភាគីយើងត្រូវធ្វើការពីពេលព្រឹកទៀត។ អ៊ីចឹងវាមានផលប៉ះពាល់សម្រាប់យើង ខ្ញុំមិនអាចនៅស្ងៀមដោយមិននិយាយអំពីផលប៉ះពាល់បែបហ្នឹងទេ ព្រោះថាយើងធ្វើការតឹងតែងណាស់ យើងមាន

បន្ទុកការងារយើងច្រើន។ ដូច្នេះសូមជម្រាបបញ្ហានេះជូនអង្គជំនុំជម្រះ។ សូមអរគុណលោកប្រធាន។

[០៩:២២:៤៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ យ៉ាងម៉េចទៅខាងតំណាងសហព្រះរាជអាជ្ញា? នៅពេលការឃើតយ៉ាវហ្នឹង មានអីដែលចង់ធ្វើការបំភ្លឺដែរទេ ឬក៏មិនមានអីទេ? បើមិនមានទេ ក៏សូមអញ្ជើញបន្តដាក់បង្ហាញឯកសារ បើសិនជាមិនមានទេ។

**លោក ឌេល លីសាក់៖**

ខ្ញុំសូមលើកឡើងដោយសង្ខេបលោកប្រធាន។ គឺមានបញ្ហាបច្ចេកទេសខាងផ្នែកយើងខ្ញុំកាលពីម្សិលមិញ ព្រោះថាបញ្ជីរបស់យើងខ្ញុំ ទាក់ទងទៅនឹងចាម ហើយនិង លន់ នល់ ត្រូវបានដាក់ប្រហែលជា២០នាទីក្រោយម៉ោងមួយសាមសិបនាទី។ ហើយចំពោះឯកសារទាក់ទងទៅនឹងវៀតណាមវិញ គឺសហព្រះរាជអាជ្ញារងបានដាក់ចូលទៅក្នុងប្រព័ន្ធនៅពេលថ្ងៃត្រង់ ហើយបន្ទាប់មកយើងទើបតែដឹងថាយើងកំពុងតែបញ្ជូនតែបញ្ជីតែប៉ុណ្ណោះ។ ហេតុដូច្នេះហើយទើបយើងមានការបញ្ជូនឯកសារពីវៀតណាមនៅពេលក្រោយមកទៀត នៅក្នុងពេលរសៀលនោះ។ ហើយប្រហែលដូចដែលអង្គជំនុំជម្រះបានដឹង គឺថាយើងមានការឈប់សម្រាក ហេតុដូច្នេះហើយយើងមិនបានបញ្ជូន។ ដូច្នេះយើងខ្ញុំមិនដឹងថាតើវាអាចមានផលប៉ះពាល់យ៉ាងណាចំពោះមេធាវីការពារក្តី ក្នុងការឆ្លើយតបទៅនឹងឯកសារនេះទេ។

សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយនេះគ្រាន់តែជាការកត់សម្គាល់ទេ ដែលជាការរំឭកថា គួរតែប្រឹងប្រែងព្យាយាមធ្វើយ៉ាងណាឲ្យបានល្អប្រសើរនូវសវនាការរបៀបក្នុងការដាក់បង្ហាញឯកសារគន្លឹះ នូវបណ្តាអង្គហេតុដែលយើងនឹងធ្វើសវនាការនៅពេលក្រោយៗទៀត។

បាទ សូមអញ្ជើញបាទ សហព្រះរាជអាជ្ញារងជាតិ!

[០៩:២៤:៣៦]

**លោក សេង ប៊ុនឃាង៖**

បាទ អរគុណលោកប្រធាន។ ជាដំបូងសូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងភាគីទាំងអស់ដែលមានវត្តមាននៅទីនេះ។ ពេលនេះខ្ញុំចាប់ផ្តើមធ្វើការបង្ហាញឯកសារពាក់ព័ន្ធនឹងការ

ប្រព្រឹត្តចំពោះជនជាតិចាម។

លោក លោកស្រីចៅក្រមបានស្តាប់សក្ខីកម្មរបស់អ្នកជំនាញម្នាក់ គឺលោក អ៊ីសា ឧស្មាន រួចមកហើយ ដែលគាត់បានធ្វើការសិក្សាយ៉ាងលម្អិតអំពីអ្វីដែលកើតឡើងចំពោះជនជាជាតិចាមក្នុងរបបខ្មែរក្រហម។

ដូច្នេះពេលនេះខ្ញុំនឹងចាប់ផ្តើមពីភ័ស្តុតាងផ្សេងទៀតរបស់អ្នកជំនាញម្នាក់ទៀត ដែលបានធ្វើការសិក្សាស្រាវជ្រាវយ៉ាងលម្អិត គឺលោក ប៉ែន ឃៀរនិន។ នៅក្នុងសៀវភៅរបស់គាត់មាននៅក្នុងឯកសារលេខ E3/1593 គឺមានចំណងជើងថា "របបប៉ុល ពត"។ ត្រង់ជំពូកទី៧ បានលើកឡើងអំពីការធ្វើវិស្សមកម្មជាតិសាសន៍។ បក្សកុម្មុយនីស្តកម្ពុជា និងបណ្តាជនជាតិភាគតិចរបស់កម្ពុជា ឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៧ ជំពូកនេះបានពិភាក្សាយ៉ាងច្រើនពាក់ព័ន្ធទៅនឹងការប្រព្រឹត្តចំពោះជនជាតិចាមក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ នៅត្រង់ERNជាភាសាខ្មែរគឺ 00637752 ដល់ 809 ហើយជាភាសាអង់គ្លេសគឺ 01150133 ដល់51 ហើយជាភាសាបារាំងគឺ 00639020 ដល់ 63។

[០៩:២៦:៤៩]

នៅត្រង់ជើងទំព័រទី៦៧ នៃផ្នែក នេះលោក ប៉ែន ឃៀរនិន បានរៀបរាប់អំពីប្រភពចម្បងនានានៃឯកសាររបស់គាត់ ដូចជា ផ្នែកនេះគឺ ផ្តោតសំខាន់ទៅកិច្ចសម្ភាសន៍របស់អ្នកនិពន្ធជាមួយជនជាតិចាមចំនួន២៩នាក់ ដែលរស់នៅឆ្លងកាត់របបខ្មែរក្រហម។ ការសម្ភាសទាំងអស់នេះត្រូវបានធ្វើឡើងភាគច្រើនក្នុងអំឡុងឆ្នាំ១៩៨០ នៅក្នុងភូមិរបស់ប្រជាជនកម្ពុជា និងមានការថតជាសំឡេងផងដែរ។ ហើយក៏មានការសម្ភាសជាច្រើនផ្សេងទៀតដែលមិនបានថតជាសំឡេង។ ក្រោមមកទៀតមានការសម្ភាសជនជាតិចាមដែលជាជនភៀសខ្លួន៥០នាក់ផ្សេងទៀត ត្រូវបានធ្វើឡើងដោយលោក នេត ថាយ៉រ នៅឯប្រទេសថៃ និងលោក ដាន ឌីកកាសាន់ នៅសហរដ្ឋអាមេរិក។

នៅក្នុងសៀវភៅរបស់លោក ប៉ែន ឃៀរនិន គាត់បានពន្យល់ថា តើនរណាជាជនជាតិចាម? គឺគាត់ពន្យល់ថា ជាក្រុមសាសនានិងក្រុមជាតិពន្ធ គឺមាននៅក្នុងត្រង់ ERN ជាភាសាខ្មែរគឺ 00637752 ដល់ 54, ជាភាសាអង់គ្លេសគឺ 01150133 ដល់ 34, ជាភាសាបារាំងគឺ 00639020 ដល់ 22។ ខ្ញុំសូមដកស្រង់៖ "មាតុភូមិដើមរបស់ពួកគេគឺចម្ប៉ា ជារដ្ឋហិណ្ឌូ-ពុទ្ធសាសនានិយមដំបូងមួយក្នុងចំណោមរដ្ឋហិណ្ឌូ-ពុទ្ធសាសនានិយមដំបូងៗនៅអាស៊ីអាគ្នេយ៍នោះ បានធ្លាក់ទៅក្រោមនឹមត្រួតត្រារបស់វៀតណាមនៅឆ្នាំ១៤៧១។ ៥សតវត្សរ៍ក្រោយ ជនជាតិចាមនៅសល់តែ៦០.០០០នាក់ប៉ុណ្ណោះ នៅភាគកណ្តាល

ប្រទេសវៀតណាម ប៉ុន្តែគេបានជំរឿនឃើញមានចាមមួយចំនួនធំនៅប្រទេសកម្ពុជាដែលពួកគេ ពេលដែលពួកដូនតារបស់ខ្លួនចាកចោលស្រុកចូលមករស់នៅទីនេះ។ ពួកគេបានប្រកាន់យកសាសនាអ៊ីស្លាម និងបានរៀបការជាមួយជនជាតិម៉ាឡេ ហើយប្រែក្លាយខ្លួនទៅជាជនជាតិភាគតិចដែលកើតក្នុងស្រុកដ៏សំខាន់បំផុតនៅប្រទេសកម្ពុជា។”

[០៩:២៩:៣៩]

ហើយចុះមកក្រោមប្រហែលជាបួនកថាខណ្ឌទៀត ខ្ញុំសូមដកស្រង់៖ “វៀតណាមសម្រេចលេបត្របាក់ដែនដីចាមដោយផ្ទាល់ ការច្បាំងដណ្តើមយកផាន់រ៉ាងដោយប្រទេសវៀតណាមនៅឆ្នាំ១៦៩៣ បានបណ្តាលឲ្យមានពួកអ្នកភៀសខ្លួនចាមមកកាន់ប្រទេសកម្ពុជាចំនួន៥.០០០នាក់ ក្នុងចំណោមនោះមានសមាជិកព្រះរាជវង្សានុវង្សយ៉ាងច្រើន។ ពួកនេះបានតាំងលំនៅជាប់នៅភាគខាងជើងរាជធានីភ្នំពេញ ហើយសព្វថ្ងៃក្រុមអ្នកតពូជពង្សរបស់ពួកនេះ បានបង្កើតជាសហគមន៍មួយច្បាស់លាស់ មិនច្រឡំនឹងគេ ហើយនៅប្រើប្រាស់អក្ខរក្រមរបស់ឥណ្ឌា និងប្រតិបត្តិសាសនាអ៊ីស្លាម តាមលទ្ធិហិណ្ឌូដដែល។ ប៉ុន្តែអ្វីដែលប្រហែលជាការធ្វើដំណើរផ្លាស់ស្រុកទេសដ៏ធំរបស់ជនជាតិចាមនោះ គឺបានកើតមានក្រោយចុងទសវត្សរ៍១៩៨០។ ព្រះវិហារដែលមានអាយុចំណាស់ជាងគេរបស់ប្រទេស ត្រូវបានសាងឡើងនៅភាគខាងជើងរាជធានីក្នុងឆ្នាំ១៨១៣។”

លោក ប៉ែន ឃៀរនិន ក៏បានសរសេរផ្នែកដំបូងនៃចលនារបស់ខ្មែរក្រហម មុនពេលដែលពួកខ្មែរក្រហមចាប់ផ្តើមទុក្ខបុកម្នេញលើជនជាតិចាម អំឡុងពេលដែលប្រជាជនចាមជាច្រើននៅក្នុងភូមិភាគបូព៌ាបានចុះចូល និងបានគាំទ្រដល់ខ្មែរក្រហម។ គឺមាននៅត្រង់ ERN ជាភាសាខ្មែរគឺ 00637759 ដល់60, ជាភាសាអង់គ្លេសគឺ 01150136 និងជាបារាំងគឺ 00639025 ដល់26។

[០៩:៣២:០៣]

ខ្ញុំសូមដកស្រង់៖ “សុះ ម៉ាន បានត្រឡប់មកប្រទេសវិញនៅឆ្នាំ១៩៧០ ហើយបានចូលធ្វើការក្នុងគណៈកម្មាធិការបក្សកុម្មុយនីស្តរបស់ភូមិភាគបូព៌ា។ គាត់បានបង្កើតចលនាអ៊ីស្លាមរបស់ភូមិភាគបូព៌ាផងដែរ។ គាត់បានដឹកនាំជាមួយកូនរបស់គាត់គឺ ម៉ាត់ លី។ ម៉ាន បានធ្វើដំណើរខ្វាត់ខ្វែងពាសពេញភូមិភាគ ដើម្បីលើកទឹកចិត្តជនជាតិចាមទាំងអស់ឲ្យប្រព្រឹត្តល្អជាមួយការបដិវត្ត។ សុះ ម៉ាន ជានិមិត្តរូបមួយដែលមានកិត្តិនាមល្បីសុះសាយ ប៉ុន្តែវាជាករណីលើកលែងមួយ។ ក្នុងភូមិភាគផ្សេងៗទៀត គណៈដឹកនាំនៃបក្សកុម្មុយនីស្តកម្ពុជា ដែលគ្រប់តំបន់ទាំងអស់ក្នុងរយៈពេលសង្គ្រាមឆ្នាំ១៩៧០ ដល់ឆ្នាំ

១៩៧៥ មិនដែលយោគយល់ក្រុមអ៊ីស្លាមណាមួយឡើយ។ តំបន់ភូមិភាគខាងត្បូង គឺជាកន្លែងដែលមានការវាយលុកដំបូងគេមួយ ក្នុងចំណោមការវាយលុកដំបូងៗ ប្រឆាំងនឹងវប្បធម៌ចាម។ នៅពេលដំបូងគេតម្រូវឱ្យស្រីៗកាត់សក់របស់ខ្លួនតាមរបៀបខ្មែរ។ បន្ទាប់មក គេហាមឃាត់មិនឱ្យស្លៀកសារុងតាមប្រពៃណី ព្រមគ្នាជាមួយសម្លៀកបំពាក់ដែលជាទីពេញនិយមរបស់ប្រជាជនខ្មែរ។ គេក៏កម្រិតព្រំដែនក្នុងការប្រតិបត្តិសាសនាផងដែរ។ ការហាមឃាត់ទាំងនេះ ត្រូវបានអនុវត្តនៅក្នុងភូមិភាគនិរតីតាំងពីពាក់កណ្ដាលឆ្នាំ១៩៧២ ដោយអនុលោមទៅតាមបទបញ្ជាផ្សេងៗរបស់ ម៉ុក។”

[០៩:៣៤:១៧]

ហើយបន្តទៅទំព័រខាងមុខទៀត គឺនៅត្រង់ទំព័រ ERN ជាភាសាខ្មែរគឺ 00637761 និងជាភាសាអង់គ្លេសគឺ 01150136, ជាភាសាបារាំងគឺ 00639027។ ខ្ញុំសូមដកស្រង់៖ “នៅអង្គរជ័យ ជនជាតិចាមទាំងអស់របស់ភូមិភាគនិរតី បានទទួលឈ្មោះតាមផ្លូវការថា ប្រជាជនថ្មី (ប្រជាជនមូលដ្ឋានដែលគេដកហូតសិទ្ធិ)។ នេះជាគំរូដែលមានពីយូរយាណាស់មកហើយ ក្នុងការប្រើប្រាស់ពាក្យពេចន៍នេះចំពោះពួកអ្នកជម្លៀសនោះ។ ប៉ុន្តែជាពិសេសពួកចាមដែលរស់នៅភូមិភាគនិរតីនៅតែត្រូវគេហៅពួកអ្នកជម្លៀសមិនឈប់ បន្ទាប់ពីបានត្រឡប់ទៅភូមិកំណើតរបស់ខ្លួនវិញនៅឆ្នាំ១៩៧៤ រួចហើយក៏ដោយ។ ពាក្យពេចន៍ដែលគេប្រើនេះ បង្ហាញឱ្យឃើញថា ការកំណត់ច្បាស់លាស់អំពីប្រភេទប្រជាជនផ្សេងៗ គឺគេផ្ដើមធ្វើជាដំបូងចំពោះពួកចាមសម្រាប់ហេតុផលខាងជាតិសាសន៍ និងពុំមែនខាងផ្នែកភូមិសាស្ត្រទេ។”

ហើយនៅត្រង់ទំព័រ ERN ជាភាសាខ្មែរគឺ 00637763 ដល់ 65, ជាភាសាអង់គ្លេសគឺ 00 អ៊ំ សូមទោសម្ដងទៀត ជាភាសាអង់គ្លេសគឺ 01150137 ហើយជាភាសាបារាំងគឺ 00639028 ដល់ 30។ នៅត្រង់ចំណុចនេះ លោក ប៉ែន យៀវនិន បានពិភាក្សាអំពីឯកសាររបស់បក្សកុម្មុយនីស្តកម្ពុជា នៅចន្លោះចាប់ពីឆ្នាំ១៩៧៣ ដល់ ឆ្នាំ១៩៧៤ ដែលបានឆ្លុះបញ្ចាំងអំពីទស្សនៈរើសអើងរបស់ពួកមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ប្រឆាំងជាមួយនឹងចាម។ ទី១ គឺឯកសារខែមេសា ឆ្នាំ១៩៧៣ របស់បក្សកុម្មុយ-នីស្តកម្ពុជា ដែលមានចំណងជើងថា “ការវិភាគពីវណ្ណៈ និងការតស៊ូវណ្ណៈ” ដែលក្នុងនោះបានលើកឡើងថា៖ “ក្រុមជាតិសាសន៍ទាំង អស់សុទ្ធតែមានវណ្ណៈពលករ ដូចយើងកម្ពុជាដែរ លើកលែងតែខ្មែរអ៊ីស្លាមដែលគ្មានជីវភាពលំបាកដូចយើង។”

[០៩:៣៧:៣៣]

ហើយលោក ប៉ែន យៀវនិន បានសរសេរដូច្នេះ ខ្ញុំសូមដកស្រង់៖ “ការវិភាគពីវណ្ណៈ នេះបង្ហាញ

ឲ្យឃើញលក្ខណៈរើសអើងជាតិសាសន៍យ៉ាងជាក់ស្តែង ហើយដែលថា ជាមួយនឹងភាសា និងវប្បធម៌ដែលប្លែកខុសគ្នារបស់ខ្លួន ជាមួយភូមិធំៗ និងខ្សែបណ្តាញទាំងឡាយរបស់ខ្លួនដែលឯករាជ្យក្នុងទូទាំងប្រទេសនោះ ជនជាតិចាមប្រហែលជាដឹងដោយវិញ្ញាណថា ខ្លួនមានសភាពហាក់ដូចជាការគំរាមកំហែងមួយ ចំពោះសង្គមដែលគេបំបែកប្រជាជនឲ្យនៅដាច់ដោយឡែកៗ ពីគ្នានេះ។ ជនជាតិចាមបានរួមបង្កជាឧបសគ្គមួយចំពោះការបង្កើតសហករណ៍ផងដែរ។" សូមបញ្ចប់ការដកស្រង់។

ហើយលោក ប៉ែន ឃៀវនិន ក៏បានពិពណ៌នាឯកសារចុះខែកុម្ភៈ ១៩៧៤ របស់បក្សកុម្មុយនីស្តកម្ពុជា ដែលចេញពីភូមិភាគឧត្តរដែលមានចំណងជើងថា "សេចក្តីសម្រេចចិត្តទាក់ទងទៅនឹងមាគ៌ាគោលនយោបាយ ស្តីពីសហករណ៍របស់បក្សក្នុងតំបន់៣១"។ "ថាអ្វីដែលទាក់ទងទៅនឹងពួកខ្មែរអ៊ីស្លាមជាបងប្អូន គឺពន្យារពេលការចូលជាសមាជិកសហករណ៍។ រៀបចំពួកគេជាក្រុមសាមគ្គីជួយគ្នាទៅវិញទៅមក ប៉ុន្តែគេត្រូវបំបែកក្រុមនេះ ឲ្យរស់នៅដាច់ពីគ្នាជាចាំបាច់ តាមវិធានការដ៏ជាក់លាក់មួយ។ គេមិនត្រូវបណ្តោយឲ្យពួកនេះរស់នៅប្រមូលផ្តុំក្នុងតំបន់តែមួយនោះទេ។" លោក ប៉ែន ឃៀវនិន ក៏បានកត់សម្គាល់ ដែរថា នេះជាភ័ស្តុតាងដែលមានតាំងពីយូរមកហើយ ស្តីពីការសម្រេចចិត្តរបស់មជ្ឈិមក្នុងការបំបែកជនជាតិចាម។

[០៩:៥០:០០]

លោក ប៉ែន ឃៀវនិន បានពិពណ៌នាពីរបៀបដែលពួកមេដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា នៅក្នុងភូមិភាគបូព៌ា ក្នុងឆ្នាំ១៩៧៣ បានចាប់ផ្តើមប្រាប់ជនជាតិចាមថា ពួកគេបានលះបង់ពេលវេលាច្រើនណាស់ ក្នុងការប្រតិបត្តិសាសនា និងពុំសូវមានពេលគ្រប់គ្រាន់ដើម្បីបម្រើបដិវត្តន៍ទេ។ ហើយការចាប់ខ្លួនជនជាតិចាម បានចាប់ផ្តើមពីខែវិច្ឆិកា ឆ្នាំ១៩៧៣មក។ ក្រោយពីចាមមួយចំនួនបានចាប់ផ្តើមងើបបះបោរប្រឆាំងនឹងការគាបសង្កត់របស់ពួកកុម្មុយនីស្តប្រឆាំងនឹងជំនឿសាសនារបស់ខ្លួន។

លោក ឃៀវនិន ក៏បានយោងទៅរកឯកសារមួយដែលសរសេរដោយលោក ហ្គាហ្វា ពាងម៉េតបានអះអាងថា នៅពាក់កណ្តាលឆ្នាំ១៩៧៤ យ៉ាងហោចខ្មែរអ៊ីស្លាមចំនួន៣០០នាក់ដែលមានដើមកំណើតនៅស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ត្រូវបានចាប់ខ្លួន។ អ្នកដែលត្រូវចាប់ខ្លួន សុទ្ធតែអ្នកដែលមានមុខមាត់នៅតាមភូមិ និងមេដឹកនាំសាសនា។ ជាសំខាន់គឺគ្រូៗ ដែលបង្រៀនគម្ពីរគូរ៉ាន់។

ដោយយោងលើការសិក្សាស្រាវជ្រាវរបស់គាត់ លោក ប៉ែន ឃៀវនិន ក៏បានសរសេរផងដែរថា៖ "នៅខែកញ្ញា ១៩៧៤ ប៉ុល ពត បានធ្វើដំណើរដោយខ្លួនឯង ទៅកាន់ភូមិភាគបូព៌ា ដើម្បីចូលរួម

មហាសន្និបាតថ្នាក់ភូមិភាគមួយរបស់បក្ស។ ហើយចលនាអ៊ីស្លាមនៅភូមិភាគបូព៌ាដែលបង្កើតដោយ សុះ ម៉ាន ត្រូវបានរំលាយចោល។ សុះ ម៉ាន បានត្រូវគេកម្ចាត់ចេញពីឆាកនយោបាយ និងបង្ខាំង ឲ្យរស់នៅក្នុងភូមិមួយ។ ការផាត់រូបគាត់ចោល បានកើតឡើងជួនពេលគ្នានឹងការចាប់ខ្លួនពួកកុម្មុយនីស្តខ្មែរ នៅភូមិភាគបូព៌ាដែលបណ្តុះបណ្តាលនោះនៅក្រុងហាណូយ ចំនួន៧១នាក់ ក្នុងខែសីហា ឆ្នាំ១៩៧៤ ដែរ។"

[០៩:៤២:៤១]

មកដល់ចំណុចនេះ ខ្ញុំសូមកត់សម្គាល់ផងដែរថា សកម្មភាពទាំងអស់របស់ ប៉ុល ពត ដែលប្រឆាំងនឹងកម្មាភិបាលដែលបណ្តុះបណ្តាលនៅក្រុងហាណូយ និងសមាជិកនៃចលនាខ្មែរក្រហម ដែលបានកើតឡើងភ្លាមៗ ក្រោយពីមានកិច្ចប្រជុំមួយរបស់គណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តដែលបានប្រព្រឹត្តក្នុងខែឧសភា ឬក៏ខែមិថុនា ឆ្នាំ១៩៧៤។

លោក ឃៀរនិន ក៏បានសរសេរលម្អិតពីបទពិសោធន៍របស់ប្រជាជនចាម ក្នុងតំបន់២១ នៃភូមិភាគបូព៌ា ដែលជាភូមិភាគមួយដែលលោក លោកស្រីចៅក្រម បានស្តាប់ភ័ស្តុតាងជាសក្ខីកម្មរួចហើយ។ លោក ឃៀរនិន បានសរសេរនៅត្រង់ទំព័រ ERN ជាភាសាខ្មែរគឺ 00637767 ដល់ 68, ជាភាសាអង់គ្លេសគឺ 01150138, ជាភាសាបារាំងគឺ 00639031 ដល់ 32។ ថា ខ្ញុំសូមដកស្រង់៖ "សហគមន៍ចាមដែលធំជាងគេនៅប្រទេសកម្ពុជា គឺស្ថិតនៅតំបន់២១ ខេត្តកំពង់ចាម ភាគខាងកើតទន្លេមេគង្គ និងខាងជើងផ្លូវជាតិលេខ៧។ តំបន់២១ រួមមានដែនដីដ៏មានជីជាតិតាមមាត់ទន្លេនៃស្រុកក្រូចឆ្មារ ចំការកៅស៊ូជប់ និងដីស្រែទាំងឡាយនៅស្ទួង ក្នុងស្រុកត្បូងឃ្មុំ។ ក្នុងទសវត្សរ៍១៩៧០ ស្រុកក្រូចឆ្មារមានចាមរស់នៅប្រហែល៣០.០០០នាក់។ ភូមិធំៗចំនួនបួន មានចាមរស់នៅយ៉ាងកកកុញ តាមបណ្តោយមាត់ទន្លេមេគង្គ គឺភូមិទ្រា ស្វាយឃ្លាំង ជំនីក និងប៊ឺស។ ភូមិទាំងនេះ បានធ្លាក់ក្នុងកណ្តាប់ដៃពួកអ្នកបះបោរក្នុងឆ្នាំ១៩៧០។ ពួកចាមនៅតំបន់នោះបានភ្ជាប់ខ្លួនទៅក្នុងការបដិវត្តទាំងស្រុង យ៉ាងហោចណាស់ក៏រហូតដល់ឆ្នាំ១៩៧៥ដែរ។"

[០៩:៤៥:២១]

ខ្ញុំក៏ចង់បញ្ជាក់ផងដែរថា ចំនួនប្រជាជនចាមនៅក្នុងភូមិបូព៌ា គឺបានឆ្លុះបញ្ចាំងផងដែរនៅក្នុងទូរលេខមួយចុះខែវិច្ឆិកា ឆ្នាំ១៩៧៥ ដែលផ្ញើឲ្យ ប៉ុល ពត ហើយក៏មានចម្លងជូន នួន ជា ផងដែរ។ គឺឯកសារលេខ E3/154 ដែលបានរាយការណ៍ក្រោយពីចាមត្រូវបានបំបែក ហើយជម្លៀសចេញពី

ភូមិភាគ។ ខ្ញុំសូមដកស្រង់៖ "នៅសល់ចាមប្រមាណជាង១០០.០០០នាក់នៅក្នុងភូមិភាគបូព៌ា"។

ហើយលោក ប៉ែន យៀរនិន ក៏បានរៀបរាប់នៅត្រង់ទំព័រ ERN ជាភាសាខ្មែរផងដែរគឺ 00637 773ដល់74, ភាសាអង់គ្លេសគឺ 01150140 និងជាភាសាបារាំងគឺ 00639036 ដល់37 ថាការបង្ក្រាបជនជាតិចាមនៅភូមិភាគ ក្នុងឆ្នាំ១៩៧៥ និងបានបញ្ជាក់ពីអ្នកដែលត្រូវទទួលខុសត្រូវចំពោះការធ្វើទុក្ខម្នេញដូច្នេះថា ខ្ញុំសូមដកស្រង់៖ "ខ្មែរម្នាក់នៅស្រុកនោះដែលធ្វើការដើម្បីបដិវត្តន៍នៅស្រុកក្រូចឆ្មារ តាំងពីឆ្នាំ១៩៧០ បានអះអាងបន្ថែមពីការបង្ក្រាបនៅឆ្នាំ១៩៧៥នេះ។ ប៉ុន្តែការប្រកាសថា មានកម្មាភិបាលចាមម្នាក់ដែលនិយមផ្លូវកណ្តាល ធ្វើការនៅក្នុងគណៈកម្មាធិការស្រុកក្រូចឆ្មារ ដូច ម៉ាត់ លី នៅត្បូងឃ្មុំផងដែរ។ គាត់បានរៀបរាប់ពី សោ ភឹម ថាជាមនុស្សល្អម្នាក់ ប៉ុន្តែបានបន្ទោសគណៈស្រុកខ្លះ ដែលក្នុងនោះប្រហែលជាគណៈស្រុក ផា ផងដែរ ថាបានធ្វើតាមបញ្ជាផ្សេងៗរបស់ ប៉ុល ពត។ ខ្សែអាកាសវិទ្យុរបស់ក្រុម សេ.អ៊ី.អា នៅស្ថានទូតសហរដ្ឋអាមេរិកប្រចាំក្រុងបាងកក បានចាប់បានសារមួយរបស់វិទ្យុក្រុងភ្នំពេញដែលបញ្ជាឲ្យធ្វើការសម្លាប់បណ្តាមេដឹកនាំចាម មកនៅភូមិមួយនាភូមិភាគកណ្តាលនៃប្រទេសកម្ពុជា។ ទោះជាគេបំភ្លឺ ឬមិនបំភ្លឺពីការផ្ទុះឡើងនូវអំពើឃោរឃៅនៅស្រុកក្រូចឆ្មារក៏ដោយ ក៏សារនេះបានបង្ហាញឲ្យឃើញ។ ក្នុងការប្រជុំបុគ្គលិករបស់ខ្លួនជាច្រើនលើកនៅក្រសួងការបរទេស ឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៧ អៀង សារី និងឧបការីទាំងឡាយបានលើកយកបញ្ហាសញ្ជាតិមកជជែកគ្នាដែរ បើសិនជាកាលៈទេសៈមកដល់។ សាក្សីម្នាក់បានប្រកាសថា ពួកគេនិយាយតែបញ្ហាសញ្ជាតិមួយប៉ុណ្ណោះគឺសញ្ជាតិខ្មែរ។ ពួកគេមិនចូលចិត្តពួកចាមទេ ពីព្រោះពួកនេះបានសម្លាប់កម្មាភិបាលបដិវត្តន៍អស់ជាច្រើននាក់។ ពួកគេបានទន្ទេញរឿងនេះតាំងពីច្រើនឆ្នាំមកហើយ។"

[០៩:៤៩:១០]

ហើយនៅត្រង់ ERN ដដែល លោក ប៉ែន យៀរនិន បានសរសេរផងដែរពីអ្វីដែលកើតឡើងចំពោះកម្មាភិបាលខ្មែរក្រហមដែលជាជនជាតិចាម នៅក្នុងភូមិភាគ ម៉ាត់ លី និងឪពុករបស់គាត់ឈ្មោះ សុះ ម៉ាន។ ខ្ញុំសូមដកស្រង់៖ "ស្រុកមួយទៀតរបស់តំបន់២១ គឺត្បូងឃ្មុំ ដែលមានជនជាតិចាមរស់នៅយ៉ាងច្រើន បន្ទាប់ពីការរំលាយចលនាអ៊ីស្លាមរបស់ភូមិភាគបូព៌ានៅឆ្នាំ១៩៧៤ មជ្ឈិមបានបង្ខាំង សុះ ម៉ាន ដែលជាប្រធានចលនានេះក្នុងផ្ទះមួយ ស្ថិតនៅមាត់ផ្លូវជាតិលេខ៧។ តាមការរៀបរាប់របស់ ម៉ាត់ លី ថាពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៤ ឪពុករបស់គាត់បានទទួលគុណប្រយោជន៍ពីការគាំទ្ររបស់ សោ ភឹម ដែរ។ ក្រោយមក ភឹម បានស្តាប់តាមឱវាទរបស់ ប៉ុល ពត ហើយបានដកសេចក្តីទុកចិត្តលើឪពុករបស់

ខ្ញុំ ប៉ុន្តែគាត់បានសាងសង់ផ្ទះមួយឲ្យឪពុកខ្ញុំ ដែលគាត់អាចរស់នៅដោយគ្មានអ្វីមកធ្វើឲ្យព្រួយបារម្ភឡើយ។ កូនរបស់គាត់បាននិយាយរៀបរាប់ថា មនុស្សដែលគេមិនស្គាល់ពីរនាក់ បានជិះម៉ូតូមកដល់ផ្ទះម៉ាន និងផ្តល់ថ្នាំពេទ្យមួយចំនួនទៅឲ្យគាត់។ គាត់បានលេបថ្នាំនោះ ហើយបានត្រូវស្លាប់នៅពេលយប់ក្នុងអាយុឆ្នាំ ៧៣ឆ្នាំ។ អ៊ុក ប៊ុនឈឿន សមាជិកគណៈកម្មាធិការតំបន់ បានរំឭកថា ដូចកម្មាភិបាលៗចាមនៅស្រុកក្រូចឆ្មារដែរ ម៉ាត់ លី បានស្ថិតនៅក្នុងគណៈកម្មាធិការស្រុកក្នុងរយៈពេលពីរឆ្នាំ ប៉ុន្តែគេយល់ថា គាត់ជាខ្មោចបិសាចម្នាក់ ព្រោះគាត់ពុំមានសេរីភាពណាមួយទាល់តែសោះ។” សូមបញ្ចប់ការដកស្រង់។

[០៩:៥១:៣០]

ហើយលោក ប៉ែន យៀវនិន បានសម្ភាសលោក ម៉ាត់ លី នៅឆ្នាំ១៩៨០ និងឆ្នាំ១៩៨៦ ហើយមានភ័ស្តុតាងនៃបទសម្ភាសន៍ចំនួនពីរផ្សេងទៀតរបស់លោក ម៉ាត់ លី ត្រូវបានធ្វើឡើងមុនពេលដែលគាត់បានបាត់បង់ជីវិត គឺបទសម្ភាសន៍ដែលធ្វើឡើងដោយលោក ស្ទីវិន ហេដឌ័រ នៅថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៨០ គឺឯកសារលេខ E3/390។ ខ្សែអាត់សំឡេងមួយទៀត គឺឯកសារលេខ E3/2780R និងឯកសារ E3/2781R គឺជាកិច្ចសម្ភាសន៍លោក ម៉ាត់ លី ដែលធ្វើឡើងដោយលោក សឹម សុរិយ៉ា និងឯកសារ E3/7821 ដែលធ្វើឡើងលោក អ៊ីសា ឧស្មាន នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០០។ រួមនិងកិច្ច-សម្ភាសន៍មួយផ្សេងទៀតដែរ ធ្វើឡើងដោយលោក ក្រេក ស្តេនសុន និង ឆឹម៉ារី ស្ងួន ដែលជាខ្សែអាត់សំឡេង ហើយមានក្នុងឯកសារលេខ E3/2967R និង E3/2968R។

នៅក្នុងអំឡុងពេលសវនាការស្តីពីចាម មេធាវីការពារក្តីជាញឹកញាប់ ត្រូវបានផ្តល់ឱកាសផ្សេងគ្នា ដើម្បីសាកសួរអំពីសក្ខីកម្មទាក់ទងនឹងចាម។ ហើយមានចាមម្នាក់ គឺលោក ម៉ាត់ លី ដែលជាកម្មាភិ-បាលនៅក្នុងតំបន់២១ ប៉ុន្តែមេធាវីការពារក្តីព្យាយាមដោយប្រយ័ត្នប្រយែងក្នុងការគេចវេសមិនយោងទៅដល់អ្វីដែលលោក ម៉ាត់ លី បានរៀបរាប់ពីការប្រព្រឹត្តរបស់ពួកខ្មែរក្រហម មកលើជនជាតិចាមក្នុងភូមិភាគនោះទេ។ ហេតុដូច្នេះ ខ្ញុំសូមលើកជម្រាបជូនលោក លោកស្រីចៅក្រម នូវអ្វីដែលលោក ម៉ាត់ លី បាននិយាយពីប្រធានបទនេះ ក្នុងកិច្ចសម្ភាសន៍នានារបស់គាត់។

[០៩:៥៤:០៩]

នៅក្នុងកិច្ចសម្ភាសន៍របស់គាត់ក្នុងឆ្នាំ១៩៨០ ជាមួយនឹងលោក ស្ទីវិន ហេដឌ័រ គឺឯកសារលេខ E3/390 ត្រង់ERN ជាភាសាខ្មែរគឺ 00392080 ដល់81, ជាភាសាអង់គ្លេសគឺ 00436856 ដល់57,

ជាភាសាបារាំងគឺ 00479792 ដល់93។ គឺលោក ម៉ាត់ លី បានរៀបរាប់អំពីការគាបសង្កត់ និងការធ្វើទុក្ខបុកម្នេញទៅលើជនជាតិចាម ក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយខ្ញុំសូមដកស្រង់ដូចតទៅ៖ “គឺថានៅពេលនោះ គឺក្រោយរំដោះ៧៥ ខែ៦ ខែ៧ និងចាប់ផ្ដើមមានអង្គការមួយកាត់សក់ កាត់សក់ចេញ ធម្មតាអ្នកមកពីក្រៅគឺបួងសក់។ ទី២ទៀត ប្រមូលសារុងច្រកបារទាំងអស់ ប្រមូលច្រកបារមិនទាន់អីទេ យកមកដាក់ជិតប្រធានភូមិ។ ទី៣ទៀត ជម្លៀសទីតាំង ទៅណាទៅណីទៅ យកខ្មែរមកដាក់ ហើយយកចាមទៅដាក់ភូមិខ្មែរ។ ហើយដាក់តាមមើលមានច្រើនណាស់ វាហាមមិនឲ្យថ្វាយបង្គំសុទ្ធតែកាន់សាសនា។ ខ្ញុំនិយាយហ្នឹងសុទ្ធតែមានឃើញស្រាប់ បើមិនឃើញ ខ្ញុំមិននិយាយទេ។”

ហើយបន្តចុះមកក្រោមពីរបីសំណួរទៀត គឺខ្ញុំសូមដកស្រង់៖ “តំបន់ គឺតំបន់២០ បញ្ជាឲ្យយើងដុតសារុង គ្រប់ភូមិទាំងអស់ឲ្យដុតចោលទាំងអស់។ អ៊ីចឹងវាសម្លាប់ស្ទើរអស់ទៅហើយ គ្មានសល់អីទេ។ គេបែងចែក ពេលខ្លះគេយកទៅសម្លាប់ចោល ពេលខ្លះគេយកទៅធ្វើនៅភូមិ ធ្វើនៅស្រុកលើនោះម្នាក់បន្តិចៗ។ ហើយទី៣ យកទៅដាក់ព្រៃ អាហ្នឹងគឺជំងឺស្លាប់នៅភូមិកោះផល មកថាកោះផេះវិញ។ ហើយគេឈប់ឲ្យនិយាយភាសាចាម ហើយអ្នកណានិយាយភាសាចាម យកទៅចងឲ្យអង្រួងខាំមួយយប់ទៅ។” សូមបញ្ចប់ការដកស្រង់។

[០៩:៥៧:០៨]

ហើយនៅត្រង់ ERN ជាភាសាខ្មែរមួយទៀតដែរគឺ 00392096 និងជាភាសាអង់គ្លេសគឺ 00436868, ជាភាសាបារាំងគឺ00479808។ លោក ម៉ាត់ លី បាននិយាយប្រាប់ ស្ទីវិន ហេដឌ័រ អំពីការសម្លាប់សមាជិកសាច់ញាតិជនជាតិចាមរបស់គាត់ថា ខ្ញុំសូមដកស្រង់៖ “ជាការពិតណាស់ ប៉ុល ពត បានសម្លាប់គ្រួសារខ្ញុំ ប្រពន្ធខ្ញុំ កូនៗខ្ញុំបីនាក់ កូនប្រសារបីទៀត ប្រពន្ធមួយទៀត ប្រាំបួន ចៅកំពុងអឹមបីនាក់។” សូមបញ្ចប់ការដកស្រង់។

ហើយនៅត្រង់ឯកសារដដែលនេះ គឺបានលើកឡើងដែរ គឺនៅត្រង់ទំព័រ ERN ជាភាសាខ្មែរគឺ 00392105 និងជាភាសាអង់គ្លេសគឺ 00436874, ជាភាសាបារាំងគឺ 00479819។ គឺលោក ម៉ាត់ លី បានឆ្លើយនឹងសំណួរថា ហេតុអ្វីបានជារបប ប៉ុល ពត សម្រិតសម្រាំង និងបោសសម្អាត? ខ្ញុំសូមដកស្រង់ដូចតទៅ៖ “បញ្ហានេះ ខ្ញុំនិយាយខាងដើមដូចចូលអាហ្នឹងដែរ។ ការដែលមើលឃើញការកាប់សម្លាប់ផ្ទាល់ខ្លួន ចាប់ពី៧៥មកដែលអំណាចពេញដៃក្នុងដៃហើយ គឺថាពេលហ្នឹងហើយចាប់ផ្ដើម។ ដូចខ្ញុំបាននិយាយខាងដើម សួរគេ គេថា សេ.អ៊ី.អា សួរគេថា ស័ក្តិ៤ ស័ក្តិ១ ហើយបងប្អូនចាម។ ហើយខ្ញុំ

ជនជាតិចាមដែរ គេដឹកតែ-កៗទៅ តែមិនឲ្យអង្គុយទេ ឲ្យដេកយកស្នឹគ្របពីលើ ហើយយោធាគេ នគរបាលគេមិនឲ្យអង្គុយទេ។”

ហើយនៅទំព័របន្ទាប់នៃកិច្ចសម្ភាសន៍ដែរគឺនៅត្រង់ ERN ជាភាសាខ្មែរគឺ 00392106, ជាភាសាអង់គ្លេសគឺ 00436875 និងជាភាសាបារាំងគឺ 00479819 គឺលោក ម៉ាត់ លី បានប្រាប់ពីចំនួនជនជាតិចាមដែលត្រូវបានសម្លាប់ដូចតទៅ ខ្ញុំសូមដកស្រង់៖ “ខ្ញុំជម្រាបលោកត្រង់ថា បើជនជាតិចាមវិញ កាលមុនមានជាង៧០ម៉ឺន៧សែននាក់ ក្នុងឯកសារ៧០ម៉ឺន ឯកសារនៅនេះ។ ហើយក្រោយរំដោះ ខ្ញុំទៅប្រាប់វាថា នៅប្រហែល២០០.០០០ តែការពិត៨៧ នៅខ្វះ៦៤នាក់ទៀត រាប់ទាំងអាទើបតែកើតផងអត់ទាន់ដល់២០០.០០០ទេ។ សព្វថ្ងៃប្រហែល២០០.០០០ – ២០០.០០០ជាងបន្តិចបន្តួច អាហ្នឹងវាអ៊ីចឹងតាមពិតវាអ៊ីចឹង។ គិតទៅសម្លាប់ជនជាតិចាម អស់ជាង៥០០.០០០ ទូទាំងប្រទេស ជាងជ្រូក ជាងក្របីទៀត។” សូមបញ្ចប់ការដកស្រង់។

[១០:០១:០០]

ហើយនៅក្នុងកិច្ចសម្ភាសន៍របស់លោក ម៉ាត់ លី ក្នុងឆ្នាំ២០០០ ជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា គឺឯកសារលេខ E3/7821 នៅត្រង់ទំព័រERN ជាភាសាខ្មែរគឺ 00229130 និង ERN ជាភាសាអង់គ្លេសគឺ 00441578 ដល់79, ជាភាសាបារាំងគឺ 00611785 ដល់86។ លោក ម៉ាត់ លី បាននិយាយអំពីថា ប៉ុល ពត បានចូលរួមសន្និបាតនៅភូមិភាគបូព៌ា ក្នុងឆ្នាំ១៩៧៤ និងពិភាក្សា និងការពិភាក្សាដែល ប៉ុល ពត បានព្រមានលោក ម៉ាត់ លី អំពីការឲ្យបញ្ឈប់គោរពប្រតិបត្តិសាសនាចាម។ ហើយខ្ញុំសូមដកស្រង់ដូចតទៅ៖ “ខ្ញុំនិយាយពីរឿងចាមស្លាប់ជិតភូមិចាម យោធាស្លាប់ គ្នាសុំយកទៅកប់ខ្លួនឯង។ ចាម គេកប់ក្បាលទៅជើង ហើយជើងទៅត្បូង ហើយដេកផ្អៀងបែរមុខទៅលិច។ ដល់គាត់យកទៅកប់ដូចខ្មែរ យើងមានក្បាលទៅកើត ទៅលិច ដល់អ៊ីចឹងខ្ញុំសុំ រួចក្រោយមក តាស៊ីម គាត់ថា ចាំគាត់សម្រួលឡើងវិញ ប៉ុន្តែពេលសន្និបាតនោះ ប៉ុល ពត អត់ថាឲ្យខ្ញុំទេ។ ប៉ុល ពត ទៅចូលរួមដែរពេល៧៤។ ដល់ចុះពីហ្នឹងទៅ គាត់ទៅនិយាយជាមួយ សោ ភឹម ខ្ញុំមិនដឹងថា ប៉ុល ពត កំពុងនិយាយ ខ្ញុំចូលទៅ។ ដល់ចូលទៅ គាត់ហៅខ្ញុំសួរថា ម៉ាត់ លី ឯងចេះសូត្រគូរ៉ង់ ខ្ញុំថា បាទ ខ្ញុំចេះសូត្រគូរ៉ង់។ ដល់ពេលខ្ញុំរៀបចេញមកហើយ ប៉ុល ពត និយាយថា ឥឡូវយើងចូលបដិវត្តន៍ហើយ គេកប់យ៉ាងម៉េចស្រេចលើបដិវត្តន៍។”

[១០:០៣:២១]

ហើយលោក សុរិយ៉ា ក៏បានសួរលោក ម៉ាត់ លី តទៀតថា៖ "សោ ភឹម និយាយអ៊ីចឹង? ហើយលោក ម៉ាត់ លី គាត់ឆ្លើយតទៀតថា៖ អត់ទេ ប៉ុល ពត និយាយខ្លួនឯង។ បានខ្ញុំរាង ដល់ពេលខ្ញុំរៀបចេញមក បានខ្ញុំរៀបចេញមក ខ្ញុំសុំទោសគាត់។ គាត់និយាយថា អត់អីទេ។ ខ្ញុំប្រាប់គាត់ថា ខ្ញុំនិយាយតាមប្រពៃណី ខ្លាចបងប្អូនចាមបះបោរនឹងយើង។ គាត់ថា បះបោរយ៉ាងម៉េច យើងរស់ប៉ុណ្ណឹង យើងទៅខ្លាចអីចាម ម៉ាដំបប្រាំ។ ដល់ពេលខ្ញុំចេញមក ខ្ញុំឮគាត់និយាយជាមួយ សោ ភឹម ថា អាមួយ អាអនុប្រធាននោះ ចាប់ទៅ ត្រូវតែដោះស្រាយអាហ្នឹង។" សូមបញ្ចប់ការដកស្រង់។

ហើយចុះមកក្រោមពីរបីសំណួរ នៅត្រង់ERN ជាភាសាខ្មែរគឺ 00229131, ជាភាសាអង់គ្លេសគឺ 00441579, ជាភាសាបារាំងគឺ 00611786 គឺលោក ម៉ាត់ លី ត្រូវបានគេសួរថា៖ "មាននយោបាយស្អប់ចិន យួន ទេ?" ម៉ាត់ លី ឆ្លើយបញ្ជាក់ ខ្ញុំសូមដកស្រង់៖ "កាលនុ៎ង លែងទាំងអស់ យួនកាន់តែធ្ងន់ ចិនក៏ធ្ងន់ដែរ។ ចិន គ្មានសល់ទេ។ បានតែចិននិយាយច្បាស់ មិនសូវអីទេ ចេះតែបន្លំ។" បាទ ខ្ញុំសូមបញ្ចប់ការដកស្រង់។ ហើយខ្ញុំក៏បញ្ចប់ការបង្ហាញឯកសាររបស់ខ្ញុំនៅពេលនេះដែរ ហើយឱ្យសហការីរបស់ខ្ញុំបន្តការបង្ហាញទៀត។ បាទ សូមអរគុណ។

**លោក ឌេល លីសាក់៖**

សូមជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម។ ខ្ញុំសូមបន្ត ហើយខ្ញុំសូមធ្វើការដកស្រង់នូវការដកស្រង់មួយចំនួនពីបុគ្គលមួយទៀត ដែលធ្វើការស្រាវជ្រាវយ៉ាងលម្អិតទៅលើបទពិសោធន៍របស់ជនជាតិចាមនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ នារីម្នាក់នោះគឺឈ្មោះ ហ្វារីណា សូ ហើយក៏ជាអ្នកនិពន្ធឯកសារ E3/4519 គឺជាសៀវភៅមួយដែលមានចំណងជើងថា "ប្រវត្តិស្ត្រីជនជាតិចាមនៅក្នុងប្រទេសកម្ពុជា នៅក្នុងរបបខ្មែរក្រហម"។ នៅត្រង់ភាសាខ្មែរមានលេខ 00714582, អង់គ្លេសមានលេខ 00524486, បារាំងមានលេខ 00772376។ គាត់បានសរសេរនូវទស្សនៈដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ "វត្តចាមជាច្រើនត្រូវបានគេប្តូរទៅជាកន្លែងស្តុកទំនិញ ជាកន្លែងចិញ្ចឹមជ្រូក គោ មាន់ ទា និងកន្លែងធ្វើទារុណកម្ម។ ហើយហាគីម និងអ្នកដទៃទៀត គឺជាគ្រូបង្រៀនសាសនាដទៃទៀតហ្នឹងត្រូវបានគេសម្លាប់ ហើយត្រូវបានគេធ្វើទារុណកម្ម ហើយសម្លាប់។ សៀវភៅសាសនា និងឯកសារសាសនា ក៏ដូចជាឯកសារនានា ត្រូវបានគេយកទៅដុតចោល ឬក៏ត្រូវបានគេប្រើប្រាស់ជាក្រដាសអនាម័យ។ ខ្មែរក្រហមបានលុបបំបាត់នូវជនជាតិភាគ និងខ្មែរជនជាតិភាគតិចទាំងអស់។" សូមបញ្ចប់ការដកស្រង់។

[១០:០៧:៣៨]

ដូចដែលយើងបានឮពី អ៊ីសា ឧស្មាន ដូចគ្នាដែរ ហើយនិងពីការដកស្រង់របស់ ម៉ាត់ លី ដូចដែលសហការីខ្ញុំទើបតែបានបង្ហាញ។ ហ្វារីណា សូ ក៏បានបញ្ជាក់ថា មុនឆ្នាំ៧៥សហគមន៍ជនជាតិចាមរួមមានប្រជាជនប្រហែល៧០០.០០០នាក់។ យើងអាចរកឃើញនូវឯកសារមានលេខ 00554488, ខ្មែរមានលេខ00714583, អង់គ្លេសមានលេខ00554489 និងបារាំងមានលេខ00772379។ គាត់បានដកស្រង់នូវប្រភពមកពីឯកសារមួយចំនួន ដូចជារបាយការណ៍ឆ្នាំ៧៤ មកពីលេខាធិការដ្ឋានសមាគមចាមសម្រាប់ខ្មែរសាធារណរដ្ឋ ហើយនិងរបាយការណ៍ឆ្នាំ១៩៨៧ ដែលមានចំណងជើងថា "អ៊ីស្លាមនៅក្នុងប្រទេសកម្ពុជា"។ ហើយនៅក្នុងឯកសារបន្តរបស់គាត់ ដែលមានចំណងជើងថា "ការកម្ទេចសហគមន៍ម៉ូស្លាម និងការលុបបំបាត់អត្តសញ្ញាណចាម" ដែលយើងអាចរកឃើញនៅត្រង់ឯកសារលេខ 00714617 ដល់18, អង់គ្លេសមានលេខ 00554567 ដល់69 និងភាសាបារាំងមានលេខ 0077 2452 ដល់54។ គាត់បានសរសេរ ហើយខ្ញុំសូមដកស្រង់៖ "ការហាមឃាត់ជំនឿសាសនា និងគោលនយោបាយសាសនា គឺចេញមកពីមេដឹកនាំខ្មែរក្រហមខ្ពស់បំផុត រហូតមកដល់ថ្នាក់ភូមិភាគ ស្រុក ហើយនិងប្រធានសហករណ៍។ ខ្មែរក្រហមបានរៀបចំការប្រជុំ ហើយបានព្រមានអំពីផលវិបាកធ្ងន់ធ្ងរចំពោះអ្នកដែលប្រឆាំងជាមួយគោលនយោបាយនេះ។ ហើយបន្ទាប់មកទៀតគេបានចាប់ផ្ដើមបិទ ឬក៏បំផ្លាញវិហារអ៊ីស្លាម វត្តព្រះពុទ្ធសាសនា ហើយនិងព្រះវិហារសាសនាគ្រិស្ដជាដើម។ (ហើយបន្តបន្តិចមកក្រោម) បន្ទាប់ពីបានហាមឃាត់សាសនារួចហើយ ខ្មែរក្រហមបានបន្តលុបបំបាត់អត្តសញ្ញាណនៃជនជាតិភាគតិច ដោយបានបញ្ជាឲ្យប្រជាជនប្រកាន់យកពូជសាសន៍តែមួយ គឺខ្មែរ។ ពួកគេបានបង្កើតនូវជាតិសាសន៍មួយនៅក្នុងគោលនយោបាយ ដែលតម្រូវឲ្យមានការចូលរួមទៅក្នុងពូជសាសន៍ខ្មែរដោយបង្ខំឲ្យចាមចូលរួមទៅក្នុងពូជសាសន៍ខ្មែរ។ ខ្មែរក្រហមបានប្រកាសថា ភាសាក្រៅពីភាសាខ្មែរ ត្រូវបានហាមឃាត់ ហើយភាសាចាម ត្រូវបានគេចាត់ទុកថាជាភាសាបរទេស។ នៅតាមខេត្ត ខ្មែរក្រហមបានប្រកាសថា មានបដិវត្តកម្ពុជាតែមួយប៉ុណ្ណោះ។ ហើយនៅក្នុងប្រទេសកម្ពុជា គឺមានជាតិសាសន៍តែមួយ និងភាសាតែមួយ គឺភាសាខ្មែរ។ ចាប់ពីពេលឥឡូវនេះតទៅ ជាតិសាសន៍ដទៃ មិនមានតទៅទៀតឡើយនៅក្នុងប្រទេសកម្ពុជា។ អត្តសញ្ញាណ ភាសា ប្រពៃណី និងជំនឿសាសនារបស់ជនជាតិចាម ត្រូវលុបបំបាត់ចោល។ អ្នកដែលមិនគោរពតាមបញ្ជានេះ នឹងត្រូវទទួលបាននូវផលវិបាកនានា។"

[១០:១១:១៧]

ហើយគាត់បានដកស្រង់បន្តទៅទៀតនូវចម្លើយមួយចំនួន ដែលៗគេបានលើកឡើងបង្ហាញនូវ

អង្គការសិទ្ធិមនុស្សនោះទៅ គណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិផងដែរ។

ភ័ស្តុតាងប្រហែលគ្នានេះ ដែលនិយាយអំពីគោលនយោបាយក្នុងការលុបបំបាត់ជនជាតិភាគតិច ដូចជាជនជាតិចាមជាដើម ត្រូវបានផ្តល់ឡើងដោយ ប៉ែន យៀវនិន នៅក្នុងសៀវភៅរបស់គាត់ គឺរបប ប៉ុល ពត គឺឯកសារ E3/1593 ខ្មែរមានលេខ 00637772, ភាសាអង់គ្លេសមានលេខ 01150139 ដល់40 និងបារាំងមានលេខ00639035។ គាត់បានដកស្រង់ចេញពីការសម្ភាសរបស់គាត់ នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ៨០ ជាមួយនឹងអតីតអនុលេខាតំបន់២១គឺ អ៊ុក ប៊ុនឈឿន។ ប៉ែន យៀវនិន បានសរសេរដូច តទៅនេះ ខ្ញុំសូមដកស្រង់៖ “មិនមានគោលនយោបាយអនុញ្ញាតឲ្យមានជនជាតិភាគតិចឡើយ។ ប្រជាជនទាំងអស់ ត្រូវប្រមូលផ្តុំជាមួយគ្នា គឺមានពូជសាសន៍តែមួយគត់ គឺខ្មែរ។ ចាប់តាំងពីពេលរំដោះនៅក្នុងឆ្នាំ១៩៧៥ ប៉ុល ពត គឺជិតស្និទ្ធជាមួយនឹងចាវ៉ាយ ហើយនិងពូជជនជាតិភាគតិចដទៃទៀត ប៉ុន្តែគាត់បំបែកពូជសាសន៍អ៊ីស្លាម។ ហេតុផល គឺថាជនជាតិចាមមានអង្គការមួយដែលគេហៅ ហ្វុលរ៉ូចម៉្បា ដើម្បីការពារប្រយោជន៍របស់ជនជាតិចាមដែលដឹកនាំដោយ ឡេះ កាសេម។ ដូច្នេះហើយ ប៉ុល ពត មិនជឿទុកចិត្តទៅលើជនជាតិចាមនោះឡើយ។ បន្ទាប់ពីឆ្នាំ៧៥ នៅក្នុងកែវភ្នែករបស់អង្គការរដ្ឋ គឺមិនមានមូស្លីមទាល់តែសោះ។”

[១០:១៣:២៣]

យៀវនិន ក៏បានសរសេរផងដែរ អំពីកិច្ចប្រជុំមួយដែលធ្វើឡើងនៅតំបន់២១នៃភូមិភាគបូព៌ា នៅក្នុងពាក់កណ្តាលឆ្នាំ៧៦។ ហើយនៅពេលនោះ គឺកម្មាភិបាលបក្សបានប្រកាសដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ “ឥឡូវនេះ យើងនៅក្នុងឆ្នាំ៧៦ យើងត្រូវតែអនុវត្តផែនការផ្សេង។ ចាំបាច់មិនត្រូវ -- ចាំបាច់ត្រូវគ្មានជនជាតិចាម ឬក៏គ្មានជនជាតិចិន ឬក៏គ្មានជនជាតិវៀតណាម។ ទាំងអស់គ្នាត្រូវចូលរួមនៅក្នុងជាតិសាសន៍តែមួយគត់ គឺខ្មែរ។”

លោក លោកស្រីចៅក្រម ឥឡូវនេះខ្ញុំចង់លើកឧទាហរណ៍បន្ថែមមួយចំនួនទៀតមកពីឯកសារភ័ស្តុតាង អំពីអ្វីដែលកើតឡើងចំពោះជនជាតិចាម ដែលបានបះបោរប្រឆាំងជាមួយគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ដែលមានគោលដៅលុបបំបាត់ជំនឿសាសនាពូជសាសន៍ និងភាសា។ ហើយខ្ញុំអាចបន្តទៅទៀតបាន ប្រសិនបើលោកប្រធានអនុញ្ញាត ឬមួយក៏លោកប្រធានអាចថាសម្រាក សម្រេចឲ្យសម្រាកនៅពេលនេះ។ សូមលោកប្រធានសម្រេច។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយឥឡូវនេះ ដល់ពេលវេលាសមស្របសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១០:១៤ នាទី ដល់ម៉ោង ១០:៣២ នាទី)*

[១០:៣២:៣៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ មុននឹងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាបន្តការដាក់បង្ហាញឯកសារគន្លឹះរបស់ខ្លួន អង្គជំនុំជម្រះចេញសេចក្តីសម្រេចផ្ទាល់មាត់លើសំណើសុំឲ្យទទួលយកឯកសារE319/33.3.4 ជាឯកសារភ័ស្តុតាង។ កាលពីថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៥ អង្គជំនុំជម្រះបានទទួលសំណើសុំរបស់សហព្រះរាជអាជ្ញាឲ្យទទួលយកឯកសារភ័ស្តុតាងឯកសារ E319/36 ហើយសំណើសុំនេះ រួមបញ្ចូលទាំងឯកសារ E319/33.3.4 ដែលការិយាល័យសហព្រះរាជអាជ្ញាបានបង្ហាញថា ខ្លួនមានបំណងប្រើប្រាស់នៅក្នុងអំឡុងពេលនៃសវនាការលើការដាក់បង្ហាញឯកសារគន្លឹះនៅថ្ងៃនេះ គឺនៅថ្ងៃ២៣ កុម្ភៈ ឆ្នាំ២០១៦។ អង្គជំនុំជម្រះបានស្តាប់សំណើសុំនេះ និងឆ្លើយតបរបស់ភាគីរួចហើយកាលពីថ្ងៃទី០១ និងថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥។ ហេតុដូច្នេះអង្គជំនុំជម្រះសម្រេចទទួលយកឯកសារ E319/33.3.4 ជាឯកសារភ័ស្តុតាង ហើយសម្អាងហេតុនៃសេចក្តីសម្រេចនេះនឹងចេញនៅពេលឆាប់ៗខាងមុខ។

ហើយជាបន្តទៅនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការងាររបស់ខ្លួន គឺដាក់បង្ហាញឯកសារគន្លឹះពាក់ព័ន្ធជាមួយនឹងអង្គហេតុទៅលើក្រុមគោលដៅជាក់លាក់។

[១០:៣៤:១៧]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងលើកឡើងនូវឧទាហរណ៍ចេញពីឯកសារភ័ស្តុតាងនូវអ្វីដែលបានកើតឡើងទៅដល់ការបះបោររបស់ជនជាតិចាម ដូចដែលបានជ្រាបមកហើយ គឺការបះបោរនៅកោះ

ផល និងស្វាយឃ្លាំង។ ខ្ញុំសូមផ្តល់នូវឯកសារយោងបួនទៀត ឯកសារE3/178ៗ ជារបាយការណ៍ប្រចាំសប្តាហ៍ចេញពីគណៈកម្មាធិការតំបន់៥ ចុះខែឧសភា ១៩៧៧ ដែលជាផ្នែកមួយនៃភូមិភាគពាយ័ព្យ គឺនៅខេត្តបន្ទាយមានជ័យ។ ERN ជាភាសាខ្មែរ 00275588, អង់គ្លេស 00342709 និងបារាំង 00623305 ដល់06។ របាយការណ៍នេះ បានសរសេរដូចតទៅ៖ “សមាសភាព ១៧មេសា ចេញពីភ្នំពេញដែលជាជនជាតិចាមបានធ្វើការជំទាស់តវ៉ានៅសហករណ៍ ទាក់ទងទៅនឹងជំនឿរបស់ខ្លួននូវអ្វីដែលគេត្រូវហូប។ នេះបើយោងទៅតាមសាសនារបស់គេ ដោយខ្ញុំសូមយោងទៅមាត្រា១០នៃរដ្ឋធម្មនុញ្ញ។ ចំពោះស្ថានភាពនេះ គឺយើងបានចាត់វិធានការពិសេស គឺយើងមើលរកខ្សែបណ្តាញ រកមើលក្បាលដឹកនាំនៃចលនារបស់ពួកគេ ដើម្បីបោសសម្អាតឲ្យជ្រះស្រឡះ”។ បញ្ចប់ការដកស្រង់។

ហើយក៏មានឯកសារ E3/7145(ក)។ នេះជាពាក្យបណ្តឹងដែលជនជាតិចាមដែលរស់ក្នុងស្រុកស្ទឹងត្រង់ ដាក់ប្តឹងនៅអង្គជំនុំជម្រះវិសាមញ្ញ។ គាត់បានលើកឡើងថា សូមដកស្រង់៖ “នៅល្ងាចមួយខ្មែរក្រហមបានយកជីដូនមួយរបស់ខ្ញុំ ប្រពន្ធរបស់គេ និងកូនរបស់គេ យកទៅសម្លាប់ចោល ដោយចោទប្រកាន់ថា បានធ្វើការថ្វាយបង្គំព្រះស្ងាត់ៗ។ ថ្ងៃមួយ នៅពេលដែលខ្ញុំបដិសេធមិនព្រមហូបសាច់ជ្រូក ប្រធានភូមិបានបញ្ជាឲ្យខ្ញុំសម្លាប់ជ្រូក ហើយនិងគំរាមកំហែងខ្ញុំ ថានឹងសម្លាប់ខ្ញុំចោល បើខ្ញុំមិនសម្លាប់សត្វជ្រូកនោះទេ។” បញ្ចប់ការដកស្រង់។

[១០:៣៧:១៦]

ប៉ែន យៀវនិន ក៏បានសរសេរអំពីបទពិសោធន៍របស់ជនជាតិចាម នៅក្នុងខេត្តក្រចេះ ដែលជាតំបន់ស្វយ័ត (តំបន់១០៥) គឺឯកសារ E3/1593 ដែលនិយាយអំពីរបប ប៉ុល ពត។ ERN ជាភាសាខ្មែរ 00637788 ដល់89, អង់គ្លេស 01150144 និងបារាំង 00639048។ ប៉ែន យៀវនិន បានសរសេរដូចតទៅ៖ “ខ្មែរដែលរស់នៅទីនោះ គឺនៅក្នុងខេត្តក្រចេះ បានលើកឡើងថា បក្សកុម្មុយនីស្តកម្ពុជាចង់ឲ្យជនជាតិចាម និងជនជាតិចិនក្លាយទៅជាជនជាតិខ្មែរ។ នៅឆ្នាំ១៩៧៧ ចាមនៅសំបូរ គឺបានធ្វើការជំទាស់តវ៉ាជាចំហ ចំពោះការឲ្យហូបសាច់ជ្រូក។ ដោគវាសនារបស់អ្នកទាំងនោះមិនដឹងទេ ប៉ុន្តែនៅស្រុកស្នួលវិញ ជនជាតិចាមនោះ ក៏ត្រូវបង្ខំឲ្យហូបសាច់ជ្រូកផងដែរ។ គ្រួសារចាមម្នាក់ ដែលមានគ្នាប្រាំបីនាក់នោះគឺថាបដិសេធមិនហូបសាច់ជ្រូក ត្រូវបានគេសម្លាប់ចោលទាំងអស់ នៅក្នុងឆ្នាំ១៩៧៧។” បញ្ចប់ការដកស្រង់។

ហើយឧទាហរណ៍មួយផ្សេងទៀត ទៅលើប្រធានបទនេះ គឺជាចម្លើយចេញពីមកការិយាល័យ

សហចៅក្រមស៊ើបអង្កេត E3/9672 នៅត្រង់ចម្លើយលេខ៤៧ គឺស្ត្រីចាមម្នាក់ដែលរស់នៅក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យបានរៀបរាប់រឿងរ៉ាវដូចតទៅ នូវអ្វីដែលកើតមានឡើងនៅអង្គប្រជុំទិតៀន ស្វ័យទិតៀនមួយ ដែលគាត់និយាយថា គាត់មិនអាចហូបសាច់ជ្រូកបានទេ។ សូមដកស្រង់៖ “យើងត្រូវបានគេឲ្យទៅចូលរួមប្រជុំធ្វើស្វ័យទិតៀន រហូតដល់ម៉ោងម្ភៃពីរ។ នៅក្នុងពេលប្រជុំ គេសួរខ្ញុំថា ហេតុអីបានជាហូបសាច់ជ្រូកមិនបាន? ខ្ញុំបានឆ្លើយទៅវិញថា ខ្ញុំសម្រេចចិត្តថា បើគ្រាប់កាំភ្លើង ហើយនិងសាច់ជ្រូក ខ្ញុំសម្រេចយកគ្រប់កាំភ្លើងវិញ។ នេះមានន័យថាគឺ -- មានន័យថា បើឲ្យខ្ញុំហូបសាច់ជ្រូកដូចអ្នកដទៃ។”

[១០:៣៩:៤៤]

ខ្ញុំសូមយោងទៅឯកសារមួយផ្សេងទៀត និយាយអំពីការសម្លាប់ទ្រង់ទ្រាយធំចំពោះជនជាតិចាម ដោយខ្មែរក្រហម។ ជាពិសេស បញ្ហាមួយដែលពាក់ព័ន្ធទៅនឹងផ្នែកនៃសវនាការដំណាក់កាលនេះ គឺការសម្លាប់ពាក់ព័ន្ធទៅនឹងជនជាតិចាម គេហៅថាសមាសភាពមិនល្អ ឬក៏ការសម្លាប់សមាជិកជនជាតិចាមទាំងគ្រួសារតែម្តង។ ខ្ញុំនឹងបង្ហាញភ័ស្តុតាងទៅលើប្រធានបទមួយនេះ ចាប់ផ្តើមឡើងជាមួយនៅស្រុកផ្សេងៗ តំបន់ផ្សេងៗ ក៏ដូចជាពីភូមិភាគៗផ្សេង ដោយចាប់ឡើង ចាប់ផ្តើមឡើងជាមួយស្រុកជាក់លាក់មួយចំនួន។

ស្រុកក្រុចឆ្មារជាផ្នែកមួយនៃតំបន់២១ ភូមិភាគបូព៌ា។ ក្នុងសៀវភៅរបស់លោក អ៊ីសា ឧស្មាន សរសេរអំពីការបះបោររបស់ជនជាតិចាម ហើយក៏មានការសម្ភាសសាក្សី យ៉ាងហោចណាស់បីនាក់ផ្សេងទៀត។ ទាក់ទងទៅនឹងការសម្លាប់ចាមនៅភូមិទ្រា ដែលស៊ីសង្វាក់គ្នាទៅនឹងភ័ស្តុតាងរបស់ នោសាទះ ក៏ដូច អះម៉ាត់ សហ្វីយ៉ាស់។ គឺនៅត្រង់ខ្មែរ 00904387 ដល់ 393, អង់គ្លេស 00219198 ដល់ 202 ហើយបារាំងគឺពាក់ព័ន្ធតែនឹង បុគ្គលនោះគឺ 00943983 គឺជាមួយនឹងសាក្សីទី៣តែប៉ុណ្ណោះ។ សាក្សីទាំងបីនាក់នេះ ម្នាក់ៗគឺនិយាយអំពីការចាប់យកទៅឃុំឃាំងខ្លួន ដោយឈ្មោះ ហូ ជាមេសន្តិសុខស្រុក ហើយរួចហើយសួរថាអ្នកទាំងនោះជាចាម ឬក៏មិនមែនទេ។ ហើយអ្នកដែលត្រូវប្រាប់ខ្លួនជាជនជាតិចាម ត្រូវគេនាំខ្លួនយកទៅបាត់។

[១០:៤១:៥៥]

ប៉ែន យៀវនិន ក៏ធ្វើការសិក្សាស្រាវជ្រាវទាក់ទងទៅនឹងការសម្លាប់ក្រុមគ្រួសារចាមទាំងមូលនៅក្នុងតំបន់២៤ នៃភូមិភាគបូព៌ាដែលចាប់ផ្តើមនៅពេលដែលកម្មាភិបាលភូមិភាគនិរតីទៅគ្រប់គ្រងភូមិ

ភាគនេះ គឺឯកសារ E3/1593។ ខ្មែរគឺ 00637785 ដល់86, អង់គ្លេស 01150143 ដល់44, បារាំង 00639045 ដល់46។ លោក យៀរនិន សរសេរដូចទៅ៖ "តំបន់២៤គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់កម្លាំងភូមិភាគនិរតី របស់ តាម៉ុក ដែលឈ្មោះ អ៊ីស្មាឯល ដែលមានការប្រឆាំងជាមួយនឹង សោ ភឹម។ សោ ភឹម មិនទទួលខុសត្រូវសម្រាប់ការធ្វើទុក្ខបុកម្នេញ ឬការសម្លាប់នោះទេ ប៉ុល ពត និងភូមិភាគនិរតីទេជាអ្នកសម្លាប់។"

រួចហើយគាត់បន្តទៅមុខទៀត ទាក់ទងទៅនឹងជនជាតិចិនភាគតិចដែលរស់នៅក្នុងតំបន់២៤ផងដែរ ដែលនិយាយអំពីជនជាតិចាមរស់នៅក្បែរភូមិរបស់គាត់ ក៏ត្រូវគេនាំខ្លួនយកទៅ។ សូមដកស្រង់៖ "ពួកគេត្រូវបានសម្លាប់នៅក្នុងឆ្នាំ១៩៧៧ គឺគ្រួសារដែលមានគ្នាប្រាំបីនាក់។ ខ្ញុំបានឃើញខ្មែរក្រហមនិយាយថា ចាមគឺមិនមែន ដែលមិនមែនជាជនជាតិខ្មែរ ត្រូវចាត់ទុកថាជនជាតិខ្មាំងដោយសារថាអ្នកទាំងអស់នេះគឺបានធ្វើដើបបះបោរនៅក្នុងឆ្នាំ១៩៧៥។" បញ្ចប់ការដកស្រង់។

[១០:៤៣:៤១]

ទាក់ទងទៅនឹងស្រុកកងមាសវិញម្តង ដែលជាផ្នែកមួយនៃតំបន់៤១នៃភូមិភាគកណ្តាល។ អង្គជំនុំជម្រះក៏បានស្តាប់សក្ខីកម្មស្តីអំពីការសម្លាប់រង្គាលនៃជនជាតិចាមទាំងអស់នៅពាមជីកង នៅវត្តអូរត្រកួន។ នេះគឺជាឯកសារមួយយោងចំនួនទៀត ដែលស៊ីសង្វាក់គ្នាទៅនឹងសក្ខីកម្មនោះ ជាពិសេសគឺវាពាក់ព័ន្ធទៅនឹងបញ្ហាដែលបង្ហាញឲ្យឃើញថាគ្រួសារចាមទាំងមូលត្រូវបានចាប់ខ្លួន និងសម្លាប់ចោលទាំងអស់តែម្តង មិនមែនសម្លាប់តែម្នាក់ៗទេ ដោយសារថាអ្នកទាំងអស់នោះជាសមាសភាពមិនល្អ។

ឯកសារ E3/9654 ជាកំណត់ហេតុស្តាប់ចម្លើយរបស់ ក.ស.ច.ស ដែលនិយាយអំពីក្រុមឈ្លបនៅស្រុកកងមាស នៅត្រង់ចម្លើយលេខ១២និង១៣ អតីតកងឈ្លបនេះគឺនិយាយផ្ទុយគ្នាចំពោះការចាប់ខ្លួនអ្នកមូលដ្ឋាន និងអ្នកថ្មី។ សូមដកស្រង់ នៅពេលគេប្រព្រឹត្តអ្វីមួយខុស ឬក៏លួចអ្វី គឺគេត្រូវចាប់ជនជាតិចាមដែលគាត់បានរៀបរាប់ដូចតទៅ សូមដកស្រង់៖ "ការចាប់ជនជាតិចាមភាគតិច គឺវាមានការខុសគ្នាបន្តិច សមាជិកគ្រួសារទាំងអស់នៅក្នុងគ្រួសារនីមួយៗ ត្រូវបានចាប់ក្នុងពេលជាមួយគ្នា ហើយភ្លាមនោះក៏ត្រូវបានគេបញ្ជូនទៅវត្តអូរត្រកួន"។

ឯកសារE3/9671 នេះគឺចម្លើយរបស់បុគ្គលម្នាក់ដែលគេបានឃុំខ្លួននៅមន្ទីរសន្តិសុខវត្តអូរត្រកួនត្រង់ចម្លើយលេខ១៣។ គាត់បានរៀបរាប់នៅថ្ងៃដែលគេបានចាប់ខ្លួនគាត់យកទៅវត្តអូរត្រកួន គាត់បានឃើញអ្នកទោស២០នាក់ដែលជាជនជាតិចាម ត្រូវបានគេយកទៅសម្លាប់ចោល។ សូមដកស្រង់៖ "អ្នក

ទោសទាំងអស់នេះគឺមានទាំងប្រុស ទាំងស្រី រួមទាំងក្មេងៗផងដែរ គឺសុទ្ធតែជាជនជាតិចាម។" បញ្ចប់ការដកស្រង់។

[១០:៤៥:៥៣]

ឯកសារ E3/9661 ជាកំណត់ហេតុស្តាប់ចម្លើយរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត និយាយអំពីអ្នកមូលដ្ឋានម្នាក់រស់នៅស្រុកពាមជីកង ដែលនិយាយថា បានឃើញជនជាតិចាម ៥00នាក់ ទាំងប្រុសទាំងស្រី ទាំងក្មេង គេនាំយកទៅវត្តអូរត្រកួន។ អ្នកទាំងអស់នោះ គេដឹកខ្លួនដឹកទៅតាមទូក។ គាត់ថានោះគឺជាចាត់ទុកថាជាសាឡាងមួយដ៏ធំហើយ។ ហើយក្នុងនោះក៏គាត់បានរៀបរាប់នៅពេលមួយទៀតនោះ គាត់បានបញ្ជាដោយអនុប្រធានសហករណ៍ឲ្យដឹកជនជាតិ គ្រួសារចាមទៅវត្តអូរត្រកួន រួមមានទាំងក្មេងៗដែលមានអាយុត្រឹម១0ឆ្នាំផងដែរ។

លោក លោកស្រីចៅក្រម លោក ប៉ែន ឃៀរនិន ក៏បានធ្វើការសិក្សាស្រាវជ្រាវទៅលើជនជាតិចាម ដែលត្រូវបានសម្លាប់ដោយខ្មែរក្រហមនៅក្នុងស្រុកកងមាសផងដែរ គឺឯកសារ E3/1593 ERN ជាភាសាខ្មែរ00637789, អង់គ្លេស01150145, បារាំង00639049។ លោក ប៉ែន ឃៀរនិន សរសេរដូចតទៅ៖ "មេដឹកនាំចាមម្នាក់និយាយថា ចាមបានស្លាប់យ៉ាងច្រើននៅក្នុងឃុំចំនួនប្រាំមួយ ឬក៏ប្រាំពីរ តាមបណ្តោយទន្លេមេគង្គច្រាំងខាងជើងនៃខេត្តកំពង់ចាម។ នៅក្នុងឆ្នាំ១៩៤0 គ្រួសារចាមចំនួន៣៨0 រស់នៅតាមបណ្តោយទន្លេ ភូមិតាមបណ្តោយទន្លេចំនួនបីនៅស្រុកកងមាស ហើយមាន៥0នាក់ជាសិស្ស ហើយប្រជាជនធម្មតាត្រូវបានគេយកនាំខ្លួនមកដែលមានសរុប -- យើងមើលទៅឃើញកាលនោះមានប្រជាជនចាមទាំងអស់១.២00គ្រួសារ នៅក្នុងឆ្នាំ១៩៧៥។ នៅស្រុកកំពង់សៀមវិញម្តងដែលមានព្រំប្រទល់ជាប់នឹងស្រុកកងមាសនៅព្រំប្រទល់ខាងជើងតាមបណ្តោយទន្លេមេគង្គ។ ស្រុកកងមាសនេះក៏ជាផ្នែកមួយនៃតំបន់៤១ នៃភូមិភាគកណ្តាលផងដែរ។"

[១០:៤៨:២៦]

ខ្ញុំយោងទៅនឹងសក្ខីកម្ម ក៏ដូចជាឯកសារស្តីអំពីការបះបោររបស់ជនជាតិចាម ដែលសរសេរអំពី "អ៊ូគួបះ" នៅក្នុងតំបន់នោះដែលថា ចាមរាប់ពាន់នាក់ត្រូវបានសម្លាប់ចោល។ នេះគឺជាសិក្សាស្រាវជ្រាវរបស់លោក អ៊ីសា ឧស្មាន ដែលគាត់បានរកឃើញនៅក្នុង ចាមចំនួន១០នាក់ត្រូវបានបាត់ខ្លួន ប្រាំនាក់មកពីស្រុកកំពង់សៀម។ ខ្ញុំសូមផ្តល់ឯកសារយោងមួយចំនួនស្តីអំពីអ្នកដែលមកពីស្រុកកំពង់សៀម ហើយដែលបានឃើញការចាប់ខ្លួន និងសម្លាប់ក្រុមគ្រួសារចាមទាំងមូលតែម្តងនៅក្នុងឆ្នាំ១៩៧៨។

មិនមែនសម្លាប់តែម្នាក់ៗនោះទេ ដោយសារអ្នកទាំងនេះជាសមាសភាពមិនល្អ។

ឯកសារ E319/33.3.4 ជាឯកសារដែលអង្គជំនុំជម្រះទើបតែទទួល និយាយអំពីស្រុកកំពង់សៀម ដែលរៀបរាប់ថា ក្រុមគ្រួសារចាម១០០គ្រួសារត្រូវបានគេនាំខ្លួនដឹកតាមរទេះគោចេញទៅបាត់ គឺចាប់ផ្តើមតាំងពីខែមេសា ១៩៧៨ ត្រង់ចម្លើយលេខ២៦។ នៅត្រង់ចម្លើយ៣០ ដល់៣១ គាត់បានផ្តល់ភ័ស្តុតាងដូចតទៅ នូវអ្វីដែលបានកើតឡើងក្រោយមកទៀតនោះ៖ “សួរ៖ តើមានការប្រជុំ ឬការប្រកាសណាមួយដែរទេ ក្រោយពេលគេយកជនជាតិចាមទាំងនោះចេញទៅ? ឆ្លើយ៖ បាទ មាន។ មានអង្គប្រជុំធំមួយដែលចូលរួមដោយកងកុមារ ក៏ដូចជាកងចល័ត ក៏ដូចជាប្រជាជនមូលដ្ឋាន។” គាត់ក៏បានផ្តល់នូវឈ្មោះមនុស្សនៅទីនេះផងដែរ។ គាត់យោងទៅដល់លេខាស្រុកដែលឡើងនិយាយនៅពេលប្រជុំនោះ៖ “ចាមដែលជាខ្មាំងរបស់ -- ចាមគឺជាខ្មាំងរបស់អង្គការ ដោយសារគេមានផែនការងើបបះបោរដោយ-សារអង្គការ -- ដូច្នេះអង្គការត្រូវតែកម្ទេចពួកគេចោល។ បើសិនមានជនជាតិចាមណានៅសល់ គឺថាត្រូវតែរាយការណ៍។ ដូច្នេះយើងអាចបោសសម្អាតឲ្យអស់ ដោយសារថានេះគឺជាផែនការរបស់ថ្នាក់លើ។” បញ្ចប់ការដកស្រង់។

[១០:៥០:៥៣]

ហើយលេខាស្រុកបន្តទៅទៀត៖ “អ្នកមូលដ្ឋានណាលាក់ជនជាតិចាម គឺក៏ត្រូវចាត់ទុកអ្នកនោះថាជាខ្មាំងដែរ។ សួរ៖ តើមានចាមឯណារស់នៅក្នុងភូមិរបស់លោកទៀតទេ ក្រោយមកទៀត? ឆ្លើយ៖ អត់ទេ អត់មានចាមរស់នៅតទៅទៀតទេ។ បញ្ចប់ការដកស្រង់។

មានកំណត់ហេតុស្តាប់ចម្លើយរបស់សហចៅក្រមស៊ើបអង្កេត ដែលនិយាយអំពីការចាប់ខ្លួនក្រុមគ្រួសារទាំងមូលតែម្តង គឺឯកសារE3/9657។ សាក្សីម្នាក់នេះ និយាយអំពីការចាប់ខ្លួនជនជាតិចាមនៅភូមិត្រពាំងឫស្សី គឺប្រធានភូមិជាអ្នកចាប់ ហើយគេបានយកមកចូលក្នុងកន្លែងប្រជុំដ៏ធំមួយ។ ហើយអ្នកទាំងអស់នោះ គឺត្រូវបានកោះហៅឲ្យមកប្រជុំដោយមេភូមិ។ ព្រឹកបន្ទាប់មកខ្ញុំកត់សម្គាល់ឃើញថា នៅក្នុងភូមិត្រពាំងឫស្សីហ្នឹងស្ងាត់ជ្រាបតែម្តង។ ចាមទាំងអស់ ទាំងចាស់ ទាំងក្មេងបានបាត់ខ្លួន សូម្បីតែកុមារតូចមួយឈ្មោះ រ៉ូម៉ាស់ ហ្នឹងដែលខ្ញុំស្គាល់ ហើយធ្លាប់លេងជាមួយគេហ្នឹងក៏បានបាត់ខ្លួនដែរ។ ហើយយើងមានឯកសារយោងមួយទៀតគឺE3/8667 ត្រង់ចម្លើយលេខ២ ភ័ស្តុតាងស្រដៀងគ្នានេះដែរ គឺឯកសារ E3/9663 ឃុំមួយទៀត នៅក្នុងស្រុកកំពង់សៀម ហៅថាឃុំរកា។

នេះគឺជាឯកសារ E3/9651 ត្រង់ចម្លើយលេខ៥ដល់លេខ៧ ដែលសាក្សីរៀបរាប់ថា៖ “តើ

ចាមទាំងអស់នេះ ត្រូវបានគេសម្លាប់ដោយរបៀបណា ក្រោយពេលកម្មាភិបាលភូមិភាគនិរតីទៅដល់? គាត់បានឆ្លើយថា៖ មានចាមរស់នៅក្នុងភូមិរបស់គាត់ច្រើនណាស់ ហើយអ្នកទាំងអស់ត្រូវបានគេចាប់យកទៅសម្លាប់ចោល។ គេយកទៅសម្លាប់ម្តងៗ បីទៅប្រាំគ្រួសាររហូតដល់អស់តែម្តង។

[១០:៥៣:១៨]

ហើយឯកសារ E3/9548 ជាចម្លើយរបស់កម្មាភិបាលម្នាក់ដែលធ្វើការនៅមន្ទីរឃុំក្រឡា ត្រង់ចម្លើយលេខ១១ គឺឯកសារ E3/9548នេះឯង។ គាត់បានឆ្លើយថា៖ "ចាមទាំងអស់ហ្នឹងនៅក្នុងស្រុកកំពង់សៀម ត្រូវបានចាប់ខ្លួន និងយកទៅសម្លាប់ខ្លួនផងដែរនៅក្នុងស្រុកនេះ។ មិនមានចាមណាម្នាក់រស់រានមានជីវិតទៀតទេ លើកលែងតែម្នាក់ឈ្មោះ ភា គឺជាមនុស្សម្នាក់ដែលត្រូវបានលេខាស្រុកហ្នឹងជាអ្នកជួយការពារ។"

ឯកសារលេខ 3/9667 ត្រង់ចម្លើយលេខ២០ ទៅ ២៣៖ "ចាមត្រូវបានគេនាំយកទៅសម្លាប់ចោលនៅក្នុងពេលជាមួយគ្នាជាមួយនឹងទាហាន លន់ នល់ និងមន្ត្រីរដ្ឋការ លន់ នល់។ នៅក្នុងរដូវប្រាំងចុងឆ្នាំ៧៧ ខ្ញុំបានស្តាប់ឮ ប្រាក់ យុត ចៅហ្វាយស្រុកហ្នឹង ប្រាប់ទៅមេឃុំ ឲ្យពិនិត្យមើលតើមានចាមរស់នៅទៀតដែរ ឬក៏អត់ទេ។ ហើយនៅក្នុងកិច្ចប្រជុំ គេនិយាយថា ចាមដែលមានសាសនាដទៃទៀតនោះ គឺថាមិនត្រូវចាត់ទុកថាជាខ្មែរទេ ព្រោះខ្មែរក្រហមយល់ឃើញថា ពួកគេអាចនឹងងើបបះបោរនៅពេលណាមួយ។" បញ្ចប់ការដកស្រង់។

លោក លោកស្រីចៅក្រម មានកំណត់ហេតុស្តាប់ចម្លើយដែលសរសេរឡើងដោយ ប៉ែន ឃៀរនិន នៅពេលដែលគាត់ធ្វើដំណើរទៅកាន់តំបន់នីមួយៗ ដើម្បីស្រាវជ្រាវនូវអ្វីកើតឡើងទៅលើជនជាតិចាម។ ខ្ញុំ ដោយសារតែពេលវេលា ខ្ញុំមិនលើកឡើងទេអំពីបញ្ហានេះ។ ខ្ញុំដឹងថា មានភស្តុតាងពាក់ព័ន្ធទៅនឹងស្រុកចំការលើ ដែល បាន សៀក ហៅ ហ្វ នោះធ្លាប់បានធ្វើជាអនុលេខាស្រុក មុនពេលដែលបញ្ជូនទៅឲ្យធ្វើជា ទៅស្រុកក្រូចឆ្មារ ហើយដែលពេលនោះ ស៊ូ សឿន ប្រពន្ធរបស់ កែ ពក គឺជាលេខាស្រុក។ រឿងរ៉ាវលម្អិត គឺមានលើកឡើងនៅក្នុងសៀវភៅរបស់លោក ប៉ែន ឃៀរនិន គឺE1/1593, ខ្មែរ 00637792 ដល់ 93, បារាំង 00639051 ដល់ 52, អង់គ្លេស 01150146។

[១០:៥៦:១៦]

ខ្ញុំនឹងលើកឡើងចម្លើយ កិច្ចសម្ភាសន៍របស់ ជា ស៊ីម ដែលជាលេខាតំបន់មួយនៅភូមិភាគបូព៌ាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺគាត់ត្រូវបានសម្ភាសដោយ ប៉ែន ឃៀរនិន នៅថ្ងៃទី០៣ ខែកញ្ញា

១៩៨១ គឺឯកសារ E3/1568, ERN ជាភាសាខ្មែរ 00713929 ដល់ 290, អង់គ្លេស 00743336។ ខ្ញុំសូមដកស្រង់ចេញអំពីកិច្ចសម្ភាសន៍របស់ ប៉ែន យៀរនិន៖ "សួរ៖ តើ ប៉ុល ពត និយាយថាយ៉ាងម៉េចដែរអំពីជនជាតិចាម? ឆ្លើយ៖ នៅពេលនោះ ជនជាតិចាមត្រូវបានចាត់ទុកថា ជាជនជាតិភាគតិចនៅក្នុងចំណោមជនជាតិដទៃទៀតនៅក្នុងប្រទេសកម្ពុជា។ ហើយអ្នកទាំងអស់នោះ ត្រូវបានសម្លាប់ចោលរួមគ្នាតែម្តង។ ទោះបីជាជនជាតិភាគតិចនោះជាចាមក្តី ឬជាជនជាតិដទៃក្តី គឺថាត្រូវតែសម្លាប់ចោល។ ការសម្លាប់ហ្នឹង គឺចាប់ផ្តើមឡើងតាំងពីមុនឆ្នាំ១៩៧០មកម្ល៉េះ ហើយបន្តមកដល់ឆ្នាំ៧០ ហើយមកដល់ឆ្នាំ១៩៧៥ទៀត ក៏មានការគាបសង្កត់ សម្លាប់កាន់តែច្រើនឡើងៗ។"

ហើយឃ្លាចុងក្រោយនៅក្នុងចម្លើយនេះ ដែលខ្ញុំចង់លើកមកបង្ហាញជូនអង្គជំនុំជម្រះ នៅក្នុងប្រតិចារឹកដែលវាយចំឡើងដោយមន្ត្រីតុលាការ គឺចេញពីកំណត់ត្រាដោយដៃរបស់ ប៉ែន យៀរនិន ឃ្លាចុងក្រោយរបស់គាត់ហ្នឹង សរសេរថា ក្នុងឆ្នាំ៧៣ គឺនិយាយអំពីកាសម្លាប់ជនជាតិចាម។ គឺមានពាក្យខ្មែរមិនច្បាស់ទេ ពាក្យថា "ការតវ៉ា" ហើយនៅក្នុង នេះគឺឯកសារ E3/5593 ERN 00419375 គឺនេះឆ្នាំ១៩៧៣ហើយ។ បាទ សូមកែតម្រូវ គឺឆ្នាំ១៩៧៨ ប៉ុន្តែជាអក្សរខ្មែរអានមិនច្បាស់ទេ គេសរសេរថា៖ "នៅក្នុងឆ្នាំ១៩៧៨ គឺនិយាយអំពីការសម្លាប់ជនជាតិចាម"។ គឺប្រើថា ដោយសារពួកគេហ្នឹងខ្លាំងណាស់ ពាក្យខ្មែរគឺ "ខ្លាំង"។ រវាងអត្ថបទដែលសរសេរដោយដៃរបស់ ប៉ែន យៀរនិន និងវាយកុំព្យូទ័រនោះ ខ្ញុំសូមឲ្យបង្ហាញនូវកិច្ចសម្ភាសន៍ស្តាប់ចម្លើយនេះ គឺកិច្ចសម្ភាសន៍របស់ ប៉ែន យៀរនិន ជាមួយនឹង ជា ស៊ីម។ ឯកសារ E3/2960R – E3/2960R នៅម៉ោង៥៥:៥៦ ដល់៥៩:០៥។ ដូច្នេះអង្គជំនុំជម្រះអាចនឹងស្តាប់ឮពាក្យដែលសពរបស់សម្តេច ជា ស៊ីម នេះ បានប្រើកាលពេលគេសម្ភាសគាត់នៅពេលនោះ។

ដូច្នេះយើងខ្ញុំសូមការអនុញ្ញាតដើម្បីបញ្ចាំងវីដេអូឃ្លីបត្រង់ផ្នែកនេះលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

[១១:០០:៣០]

*(ការបង្ហាញឯកសារជាសំឡេង)*

"[...] ចុះ ប៉ុល ពត ដែលនិយាយម៉េចពីរឿងប្រជាជនចាម? តាមលោកបានដឹង តាមលោកស្តាប់គាត់ គាត់ដែលនិយាយពីរឿងចាម? ប្រជាជនចាមនៅពេលហ្នឹង ក៏ចាត់ទុកថា នេះក៏ជាជនជាតិមួយដែរនៅក្នុងចំណោមជនជាតិទាំងឡាយនៅទូទាំងប្រទេសកម្ពុជា ក៏ទុកដូចជាជនៗជាតិផ្សេងៗដែរ។

ចុះជនជាតិភាគតិចនៅខាងវៀតណាមក៏ដូចគ្នាដែរ? ដូចគ្នាដែរ ហើយសម្លាប់ៗដូចគ្នា ជនជាតិភាគតិចជា ជនជាតិចាម ឬក៏ជនជាតិផ្សេងៗ ក៏សម្លាប់ដូចគ្នា។ តាមលោកដឹង ប៉ុល ពត ចាប់ផ្ដើមសម្លាប់មនុស្ស តាំងពីឆ្នាំណា? ខ្ញុំ ការសម្លាប់ហ្នឹងគឺថា ពីមុន៧០ហ្នឹងក៏មានហើយខ្លះដែរ ដល់ក្រោយ៧០ហ្នឹងក៏ចេះតែ មានជាបន្តបន្ទាប់។ ហើយដល់ឆ្នាំ៧៥ បានមានចេះតែច្រើនឡើងបន្តិចម្ដងៗ ចេះតែមានអ៊ីចឹង ហូរហែ ជាបន្តបន្ទាប់។ ដល់៧៨ហ្នឹងខ្លាំង វាទៅជាយុទ្ធនាការ[...]។”

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង)*

[១១:០១:៥៥]

**លោក ឌេល លីសាក់៖**

សូមអរគុណលោក លោកស្រីចៅក្រមដែលបានអនុញ្ញាតឲ្យខ្ញុំចាក់បង្ហាញនេះ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ ជាព័ត៌មាន តើលោកមានប្រតិចារឹកនៃកិច្ចសម្ភាសន៍នេះទេ? ព្រោះថាយើងស្ដាប់ឮនូវការ បកប្រែភ្លាមៗក្នុងឯកសារហ្នឹង។ អ៊ីចឹងប្រសិនបើមានប្រតិចារឹកហ្នឹងគឺច្បាស់លាស់ ដើម្បីឲ្យដឹងថាតើ ការបកប្រែហ្នឹងបកប្រែត្រឹមត្រូវឬអត់ នៅក្នុងខ្សែវីដេអូហ្នឹង?

**លោក ឌេល លីសាក់៖**

ខ្ញុំគិតថា អ្វីដែលយើងមានគឺជាកំណត់ត្រារបស់ ប៉ែន យៀរនិន ដែលគាត់កត់នៅពេលសម្ភាស ហើយមានអ្នកវាយកំណត់ត្រាទាំងអស់នោះ។ ហើយដោយសារថាយើងបានស្ដាប់ឮថា កំណត់ត្រាហ្នឹង វាដូចគ្នាសឹងតែទាំងអស់ជាមួយនឹងការសម្ភាស ប៉ុន្តែយ៉ាងណាក៏ដោយខ្ញុំនឹងធ្វើសំណើឲ្យធ្វើការវាយជា ប្រតិចារឹកទៅលើកំណត់ត្រាជាខ្សែអាត់សំឡេងនៃការសម្ភាសទាំងមូលតែម្ដង។ ប៉ុន្តែដូចខ្ញុំបញ្ជាក់អ៊ីចឹង កំណត់ត្រាដែលយើងមាន គឺជាកំណត់ត្រាដែលធ្វើឡើងដោយលោក ប៉ែន យៀរនិន តែម្ដង។

សូមអរគុណចំពោះការយកចិត្តទុកស្ដាប់។ ឥឡូវនេះខ្ញុំសូមប្រគល់វេទិកាជូនលោក ស្មីត ដើម្បី និយាយអំពីឯកសារពាក់ព័ន្ធទៅនឹងជនជាតិវៀតណាម។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញលោក ស្មីត!

**លោក វីល្លៀម ស្មីត៖**

សូមជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម។ សូមជម្រាបសួរដល់មេធាវី និងភាគីទាំងអស់។ ខ្ញុំនឹងលើកបង្ហាញនូវឯកសារមួយចំនួន ទាក់ទងទៅនឹងការកំណត់គោលដៅទៅលើជនជាតិវៀតណាម។ យើងដឹងហើយថាមានឯកសារជាច្រើននៅលើសំណុំរឿង ទាក់ទងទៅនឹងការកំណត់គោលដៅទៅលើជនជាតិវៀតណាម។ ដូច្នេះដោយសារតែយើងមានពេលវេលាខ្លី ខ្ញុំមិនអាចលើកយកបង្ហាញទាំងអស់នោះទេ ប៉ុន្តែខ្ញុំនឹងព្យាយាមបង្ហាញដោយត្រួសៗ ទៅលើឯកសារមួយចំនួន ហើយខ្ញុំបានជ្រើសរើសឯកសារចំនួន៣០។ ហើយឯកសារទាំងអស់នេះគឺផ្តោតទៅលើ គឺជាឯកសារពីសម័យនោះតែម្តង គឺមកពីកម្ពុជាប្រជាធិបតេយ្យ។ ហើយឯកសារទាំងអស់នោះ បើផ្អែកតាមមតិរបស់អ្នកជំនាញ គឺបានធ្វើការស្រាវជ្រាវ។

មានកំណត់ត្រាជាលាយលក្ខណ៍អក្សរជាច្រើននៃការស្តាប់ចម្លើយ ក៏ដូចជាពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលនិយាយពាក់ព័ន្ធទៅនឹងគោលនយោបាយ តាមរយៈការអនុវត្តការសម្លាប់ជនជាតិវៀតណាមនៅទូទាំងប្រទេស។ ខ្ញុំមិននិយាយអំពីឯកសារទាំងអស់នោះទេ ដោយសារតែយើងមានពេលវេលាកំណត់ ប៉ុន្តែឥឡូវនេះ ខ្ញុំនឹងផ្តោតជាសំខាន់ទៅលើឯកសារដែលសល់ពីសម័យនោះ។ យើងសូមលើកឡើងផងថា ឯកសារដែលយើងលើកមកបង្ហាញនៅថ្ងៃនេះ គឺបង្ហាញអំពីបទចោទប្រល័យពូជសាសន៍ប្រឆាំងជនជាតិវៀតណាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ធ្វើឡើងប្រឆាំងជនជាតិវៀតណាម ហើយនិងបទចោទពីការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ដែលធ្វើឡើងចំពោះជនជាតិវៀតណាម នៅមន្ទីរ ស-២១។

[១១:០៥:៥០]

ដូច្នេះខ្ញុំសូមលើកយកទៅនឹងឯកសារទី១ ហើយខ្ញុំនឹងធ្វើការរៀបរាប់ជាលំដាប់លំដោយទាក់ទងទៅនឹងហេតុការណ៍ដែលកើតឡើងនៅក្នុងពេលវេលានីមួយៗ។ ឯកសារទី១ ដែលខ្ញុំនិយាយយោង គឺឯកសារដែលពាក់ព័ន្ធទៅនឹងហេតុការណ៍នៅឆ្នាំ មេសា ឆ្នាំ៧៥ គឺE3/7842 ERN មានលេខ 00387629 អង់គ្លេស, ខ្មែរមានលេខ 00791383 និងបារាំងមានលេខ 00771176។ ឯកសារនេះ គឺពាក់ព័ន្ធទៅនឹងការសម្ភាសដែលផ្តល់ដោយប្រធានកងពល៤ ដែលធ្វើការ -- ១៦៤ ដែលធ្វើការនៅជាមួយនឹងឯក -- ហើយវាកើតឡើងនៅខែមិថុនា ឆ្នាំ៧៥។ ហើយឯកសារនេះ បាននិយាយអំពីឆ្នាំដែលកើតឡើង អំពីហេតុការណ៍នៅឆ្នាំ៧៥។ គាត់បានបញ្ជាក់នៅក្នុងកថាខណ្ឌ៦ ដែលនិយាយអំពីការចាប់ទូក៖ “បន្ទាប់ពី

កប៉ាល់បានទៅដល់កោះហ្នឹង គឺកងពលបានចាប់បានជនជាតិវៀតណាមប្រហែលជា១០នាក់ រួមបញ្ចូលទាំងស្ត្រី និងកុមារ។ នៅក្នុងផ្នែកខាងបូព៌ា ពួកយើងបានចាប់វៀតណាមនៅជិតកំពង់ផែថ្ម ហើយបន្ទាប់មកទៀតបានបញ្ជូនទៅកោះថ្មី។ បន្ទាប់ពីបានចាប់ទូកកាណូតនោះហើយ គឺមេបញ្ជាការបានទាក់ទងជាមួយនឹងខាងកំពង់សោម ដើម្បីស្នើសុំការណែនាំ ទាក់ទងទៅនឹងជនអៀសខ្លួននោះ។ មេបញ្ជាការបានបញ្ជា ដោយមេបញ្ជាការឲ្យសម្លាប់ជនអៀសខ្លួនទាំងនោះ។ មេបញ្ជាការនិងអនុមេបញ្ជាការ បានអនុវត្តនូវការបញ្ជា។”

ឯកសារមួយនេះ គឺជួយដល់ការបង្ហាញថា ជនស៊ីវិលវៀតណាម ត្រូវបានគេកំណត់គោលដៅនៅក្នុងឆ្នាំ៧៥។ បន្ថែមពីនេះ ក៏មានការបញ្ជាឲ្យសម្លាប់ជនជាតិស៊ីវិលវៀតណាមដែលធ្វើឡើងនៅក្នុងឆ្នាំ៧៥ផងដែរ។

[១១:០៨:២៤]

ឯកសារបន្តដែលខ្ញុំនិយាយយោងគឺE3/759 គឺជាទស្សនាវដ្ដីទង់បដិវត្តនៅក្នុងខែមេសា ឆ្នាំ៧៥។ ហើយឯកសារមួយនេះ ក៏បាននិយាយអំពីខួបលើកទី១នៃកងកម្លាំង -- ខ្ញុំសូមដកស្រង់៖ “លទ្ធផលនៃបដិវត្តន៍បានបង្ហាញថា ប្រជាជនយើងត្រូវបានគេហៅថា “ប្រជាជនបដិវត្តន៍កម្ពុជា” ហើយក៏មានជនបរទេសជាច្រើនរាប់ពាន់នាក់ ដែលជនបរទេសទាំងអស់នោះធ្វើឲ្យបំបាត់ បំពុលដល់ប្រជាជនរបស់យើង។ ប្រជាជនទាំងនោះ ត្រូវបានគេហៅថា ជាធាតុផ្សំពុល តែពួកគេបានមកលេបបំពានរបស់យើង ហើយបានកម្ទេចពួកយើងទាំងស្រុង។ ហើយពួកគេបង្កឲ្យមានផលប៉ះពាល់ដល់ប្រជាជនយើង ហើយបានបណ្ដាលឲ្យប្រជាជន បណ្ដាលឲ្យយើងបាត់បង់ទឹកដី។ សូម្បីតែក្នុងពេលថ្មីៗនេះ នៅពេលដែលយើងផ្ដល់ យើងធ្វើសង្គ្រាម ក៏ដូចជានៅក្នុងរយៈពេល៥ឆ្នាំដែលយើងបង្កសង្គ្រាម គឺថាតំបន់មួយចំនួននៅតែស្ថិតក្រោមរបស់បរទេស។ ហើយនៅតាមឃុំស្រុក គឺមានជនបរទេសទាំងអស់។ ពួកគេមកទីនេះដើម្បីលេបបំបាត់ ហើយនិងលុបបំបាត់ប្រទេសយើង។ មានការបះទង្គិចនៅក្នុងប្រទេស ដើម្បីលេបបំបាត់ ក៏ដូចជាលុបបំបាត់នូវទឹកដីរបស់យើង។”

[១១:១០:០៦]

ហើយបន្តទៀតបាននិយាយថា៖ “នៅក្នុងរយៈពេល២០ឆ្នាំ ជនបរទេសទាំងអស់នេះមានគោលដៅបង្កើតឲ្យបានប្រជាជន២០លាននាក់ ហើយគោលដៅដើម្បីលេបទឹកដីកម្ពុជា ហើយនិងប្រជាជនកម្ពុជា។ នេះគឺជាស្ថានភាពបច្ចុប្បន្នរបស់ប្រទេសយើង ក៏ប៉ុន្តែបដិវត្តន៍របស់យើងនៅក្នុងថ្ងៃ១៧ មេសា

៧៥ បានដោះស្រាយបញ្ហាទាំងអស់នេះយ៉ាងស្អាត ហើយបានដោះស្រាយបញ្ហាទាំងស្រុង។ យើងដោះស្រាយដោយអចិន្ត្រៃយ៍ ក្នុងរយៈពេលរាប់រយ រាប់ពាន់ឆ្នាំហើយ យើងមិនអាចដោះស្រាយបញ្ហានេះបាន។ នៅក្នុងវណ្ណៈឈ្លានពាន គឺមិនបានដោះស្រាយបញ្ហានោះឡើយ គឺគេបានកាត់ដីទៅឲ្យជនបរទេសទាំងអស់នេះ ប៉ុន្តែឥឡូវនេះ យើងដោះស្រាយបញ្ហាទាំងអស់នេះបាន។ កម្មករ កសិករបដិវត្តន៍របស់យើងក៏ដូចជាទាហានបដិវត្តន៍របស់យើងបានដោះស្រាយបញ្ហានេះ។ គឺដោះស្រាយជាអចិន្ត្រៃយ៍ និងដោយស្អាតបាត។ ជ័យជម្នះរបស់យើងគឺមានទំហំធំធេងយ៉ាងខ្លាំង។ ហើយការដោះស្រាយបញ្ហានេះមិនមែនជាការងាយស្រួលឡើយ ប៉ុន្តែយើងធ្វើឡើងដោយកម្ទេចពួកចក្រពត្តិអាណានិគម តាមគោលការណ៍បដិវត្តន៍របស់យើង។ នេះគឺជាព្យុះដ៏ធំធេងរបស់បដិវត្តន៍ ក៏ជាព្យុះដ៏មហិមារបស់បដិវត្តន៍ដែលបានបក់បោកកម្ទេចជនបរទេសចេញពីប្រទេសយើង។ គឺធ្វើឲ្យពួកវាចាកចេញពីប្រទេសកម្ពុជា ហើយយើងមានការពេញចិត្តយ៉ាងខ្លាំង។ កងទ័ពរបស់យើង ក៏ដូចជាបក្សរបស់យើងពេញចិត្តយ៉ាងខ្លាំង។”

លោក លោកស្រីចៅក្រម យើងខ្ញុំសូមលើកយកឯកសារនេះ ដើម្បីបង្ហាញអំពីការបង្ហាញអំពីការបណ្តេញប្រជាជនវៀតណាមរាប់សែននាក់ចេញពីប្រទេសកម្ពុជា។ ហើយយើងក៏សូមបញ្ជាក់ផងដែរថា ប្រជាជនទាំងអស់នេះ ដែលត្រូវតែបានបណ្តេញចេញពីកម្ពុជា គឺៗជាជនបរទេសដែលគេមិនចង់បាន ហើយត្រូវបានគេចាត់ទុកថាជាខ្មាំង។

[១១:១២:៣៣]

ឯកសារបន្តគឺឯកសារ E3/805 ចុះខែ១៦ កញ្ញា ឆ្នាំ៧៦ គឺជាកំណត់ហេតុការប្រជុំ គឺនិយាយអំពីវិធានការណ៍ដើម្បីប្រឆាំងជាមួយនឹងវៀតណាម។ ហើយខ្ញុំសូមដកស្រង់ គឺឯកសារមានលេខ 00185237, ខ្មែរមាន 00052333 ហើយបារាំងមានលេខ 00155670។ គឺកថាខណ្ឌមួយ សូមបញ្ចប់ការដកស្រង់៖ “ស្ថានភាពខ្មាំង៖ បច្ចុប្បន្ននេះគឺមិនមានបញ្ហាអ្វីឡើយ គឺមិនមានការធានាថា ខ្មាំងឈ្មោះអុល ត្រូវបានគេបានបញ្ជូនទាក់ទងទៅនឹងអង្គការ ដោយសារតែមិនមានអង្គការ ហើយក៏មិនមានការជួយ ដែលអាចជួយដល់អង្គការក្នុងការដោះស្រាយបញ្ហា។ យើងសម្រេចថា ប្រមូលផ្តុំនៅមួយកន្លែង គឺមនុស្សប្រហែលជា១០០នាក់ ដែលមកពីកងវៀតណាម។ ហើយបានបន្តបញ្ជាក់ទៀតថា ស្ថានភាពផ្ទៃក្នុង បញ្ហានៅក្នុងអង្គភាពផ្ទៃក្នុង គឺចំពោះបញ្ហាទាក់ទងទៅនឹងវៀតណាម គឺមិនអនុញ្ញាតឲ្យពួកវាផ្តោតទៅលើបញ្ហានោះឡើយ។ យើងត្រូវតែបំបែក ហើយបញ្ជូនទៅធ្វើជាជាងឈើ ជាងដីវិញ ហើយយើងហើយកម្លាំងទាំងអស់នេះត្រូវតែកម្ទេចឲ្យបាន។

លោក លោកស្រីចៅក្រម ឯកសារទាំងអស់នេះដែលយើងខ្ញុំបានលើកឡើងនេះ គឺជួយដល់ការបង្ហាញថា បក្សកុម្មុយនីស្តកម្ពុជាគឺថា អ្នកដែលមិនអាចជឿទុកចិត្តបាន ហើយត្រូវតែគ្រប់គ្រង ហើយត្រូវតែចាត់ចែងគ្រប់ឱ្យបានច្បាស់លាស់។

ឥឡូវនេះខ្ញុំសូមលើកយកឯកសារថ្ងៃ១៩ មេសា ៧៧ E3/200។ នេះគឺជាសុន្ទរកថារបស់ ខៀវ សំផន នៅខួបលើកទី២ របស់កម្ពុជាប្រជាធិបតេយ្យ។ គាត់បាននិយាយអំពីសមិទ្ធិផលធំធេងរបស់បដិវត្តន៍ ហើយគាត់បានពិភាក្សាអំពីបញ្ហាខ្មាំងបក្សកុម្មុយនីស្តកម្ពុជា។ អង់គ្លេសមានលេខ00004165, ខ្មែរមានលេខ 00292804 ដល់ 05។ បារាំងមានលេខ 00612166។ ខ្ញុំសូមដកស្រង់៖ “ភ្លាមៗក្រោយពេលរំដោះ នៅពេលដែលយើងទទួលរងនូវការលំបាកដែលមិនអាចរៀបរាប់បានយើង ដោយសារតែយើងទើបតែងើបចេញពីសង្គ្រាមជាមួយអាមេរិក ខ្មាំងគឺមិនអាចបង្កឱ្យមានបញ្ហាបន្ថែមឡើង។ បច្ចុប្បន្ននេះ ខ្មាំងមិនអាចបង្កគ្រោះថ្នាក់ដល់យើងឡើយ វាគឺជាការជឿជាក់ដ៏រឹងមាំរបស់យើង។ ប៉ុន្តែយ៉ាងណាក៏ដោយ យើងត្រូវតែបំពេញការងារការពារកម្ពុជាប្រជាធិបតេយ្យរបស់យើង ការពារកម្មករ កសិករ រដ្ឋបាល និងរក្សានូវផ្លែផ្កានៃបដិវត្តន៍កម្ពុជា ដោយការទប់ស្កាត់ទៅលើគ្រប់ប្រភេទនៃខ្មាំង។ រារាំងពួកគេមិនឱ្យប្រព្រឹត្តការឈ្លានពាន ការជ្រៀតជ្រែក ឬក៏ការលុកលុយប្រឆាំងយើង។ យើងត្រូវតែបោសសម្អាតខ្មាំងក្នុងសមត្ថភាពរបស់យើងជាម្ចាស់ការ ដែលគោរពទៅតាមមាគ៌ាគោលនយោបាយក្នុងស្រុក គោលនយោបាយបរទេស និងគោលនយោបាយយោធា។ អ្វីៗទាំងអស់ត្រូវតែធ្វើដោយស្អាត ត្រូវតែធ្វើដោយអនុវត្តដោយស្អាតបាត ហើយទូលាយ។ យើងមិនត្រូវភ្លេចខ្លួន មិនត្រូវមិនប្រុងប្រយ័ត្ននោះឡើយ។ ផ្ទុយទៅវិញ យើងត្រូវតែពង្រឹងខ្លួនយើងឱ្យបានរឹងមាំ រក្សាឱ្យបានម៉ឺងម៉ាត់នូវស្មារតីបដិវត្តន៍ខ្ពស់ ហើយត្រូវកម្ទេច និងប្រឆាំងជាមួយខ្មាំងនៅគ្រប់ពេលវេលា។

លោក លោកស្រីចៅក្រម យើងលើកយកនូវសុន្ទរកថាមួយនេះ ដើម្បីបង្ហាញថា បក្សកុម្មុយនីស្តកម្ពុជាបានចាត់ កំណត់យ៉ាងច្បាស់ថា អ្នកណាជាខ្មាំង ហើយដូចដែល ខៀវ សំផន បាននិយាយគឺថា យើងត្រូវកម្ទេច និងទប់ស្កាត់នូវរាល់ប្រភេទខ្មាំងទាំងអស់។ ហើយយើងលើកយកឯកសារមួយនេះ ដើម្បីគាំទ្រថាអ្នកណាក៏ដោយ ក៏ត្រូវបាន -- ដែលគេចាត់ទុកថាជាខ្មាំងត្រូវបានសម្លាប់ចោល។

[១១:១៧:៤០]

ឥឡូវនេះខ្ញុំយោងទៅលើឯកសារខែមេសា ៧៧ គឺE3/742 នេះគឺជាទស្សនាវដ្ដីទង់បដិវត្តលេខពិសេស។ អង់គ្លេសមានលេខ00478495, ខ្មែរមានលេខ 00062985, បារាំងមានលេខ 00499753។

ខ្ញុំត្រូវបញ្ជាក់ឡើងវិញទៅលើ ERNគឺអង់គ្លេសមានលេខ 00478496, ខ្មែរមានលេខ 00062986, បារាំងមានលេខ 00499754។ ហើយខ្ញុំសូមដកស្រង់អំពីទស្សនាវដ្ដីទង់បដិវត្តខែមេសា ៧៥៖ "ចំពោះខ្មាំង សេ.អ៊ី.អា, កា.ហ្សេ.បេ និងភ្នាក់ងារយួន គឺខ្មាំងបានជ្រាបចូលទៅក្នុងបដិវត្តន៍របស់យើង ហើយនិងក្នុងកងកម្លាំងរបស់យើង។ ពួកគេគឺបាត់បង់នូវស្មារតី ម្ចាស់ការពីព្រោះដោយសារតែមានការវាយប្រហារភ្លាមៗរបស់យើង ហើយត្រូវបានកម្ទេចសឹងតែទាំងស្រុងដោយកម្លាំងរបស់យើង គឺដូចជាកណ្ដុរត្រូវបានគេកម្ទេចសម្បុក ហើយរត់ចូលទៅក្នុងទឹក ហើយត្រូវបានប្រជាជនតាមវាយពីក្រោយ។ យើងត្រូវបន្តកម្ទេចពួកវា ហើយនិងកម្ចាត់ពួកវាចេញពីផ្ទៃប្រទេសយើង ដោយវាយកម្ទេចឲ្យបាននៅក្នុងឆ្នាំ ៧៧ ហើយកម្ទេចបន្ថែមដើម្បីកុំឲ្យពួកវាងើបក្បាលបាន។ ធ្វើដូច្នេះបាន យើងនឹងបង្កើតបាននូវស្ថានភាពមួយដែលថា យើងអាចនឹងកម្ទេចខ្មាំងកាន់តែខ្លាំងឡើងថែមទៀតនៅក្នុងឆ្នាំ៧៨ ហើយនៅក្នុងឆ្នាំបន្តបន្ទាប់ទៅមុខ ដែលធ្វើឲ្យយើងទទួលបានជោគជ័យសំខាន់ៗបន្ថែមទៀត។"

ភ័ស្តុតាងទាំងអស់នេះ របស់បក្សកុម្មុយនីស្តកម្ពុជា ដែលនិយាយអំពីការកម្ទេចភ្នាក់ងារយួនដែលមានពាក់ព័ន្ធនៅក្នុងប្រទេសកម្ពុជា។ នៅក្នុងសារនេះផងដែរ គឺថាបក្សកុម្មុយនីស្តកម្ពុជាក៏បានធ្វើការប្រៀបធៀបភ្នាក់យួនទៅនឹងកណ្ដុរញី ដែលមានលក្ខណៈបែបនេះ។

[១១:២០:២៣]

ឥឡូវនេះខ្ញុំនឹងលើកយកនូវទស្សនាវដ្ដីដដែលនេះ គឺឯកសារE0048500*(ស៊ីក)*, ខ្មែរមានលេខ 00062990 ដល់ 91 ហើយបារាំងមានលេខ 00499757 ដល់ 58។ ខ្ញុំសូមដកស្រង់៖ "បទពិសោធន៍កន្លង បានធ្វើឲ្យយើងដឹងច្បាស់ ហើយមើលឃើញច្បាស់ថា ទោះបីជាខ្មាំងផ្ទៃក្នុង និងខ្មាំងខាងក្រៅត្រូវបានកម្ទេចយ៉ាងធ្ងន់ធ្ងរនៅពេលកន្លងមកក៏ដោយ ក៏យើងមិនត្រូវបោះបង់ចោលនូវយុទ្ធសាស្ត្រប្រឆាំងជាមួយនឹងបដិវត្តន៍កម្ពុជាដ៏ត្រឹមត្រូវរបស់ពួកយើងដែរ។ ពួកគេគឺជាផ្នែករបស់ សេ.អ៊ី.អា, កា.ហ្សេ.បេ និង យួន ដែលព្យាយាមបន្តសកម្មភាពឧក្រិដ្ឋរបស់ពួកគេ។ នេះគឺជាទស្សនៈដែលយើងត្រូវបញ្ជាក់ឲ្យបានច្បាស់ ដើម្បីទទួលបាននូវស្មារតីប្រុងប្រយ័ត្នបដិវត្តខ្ពស់ ដើម្បីប្រឆាំង និងកម្ទេចខ្មាំងជាមុន។"

ឯកសារE 00478501, ខ្មែរ 00062991 និងបារាំងមានលេខ 00499758។ ខ្ញុំសូមដកស្រង់៖ "ចាំបាច់ត្រូវបញ្ចូលមនោគមន៍វិជ្ជា និងឲ្យកម្លាំងស្វែងរកខ្មាំង វាយតម្លៃខ្មាំង តាមដានខ្មាំង ចាប់ខ្មាំង ហើយនិងកម្ទេចខ្មាំង។ ធ្វើឲ្យខ្មាំង វាហាក់ដូចជា -- ធ្វើឲ្យខ្មាំងដូចជាកណ្ដុរដែលត្រូវមនុស្សឡោមព័ទ្ធកម្ទេច ហើយនិងសម្លាប់ចោល។"

លោក លោកស្រីចៅក្រម ផ្នែកមួយនេះ គឺបង្ហាញអំពីវៀតណាមដែលគេបង្កើតនូវស្ថានភាពមួយនៅក្នុងកងកម្លាំងបដិវត្តន៍កម្ពុជា ហើយនិងការទទួលស្គាល់ថា វៀតណាមគឺជាផ្នែកមួយនៃខ្មាំងផ្ទៃក្នុងរបស់កម្ពុជា។

[១១:២២:៣៦]

នៅភាសាអង់គ្លេស00478502, ខ្មែរមានលេខ 00062993 និងបារាំងមានលេខ 00499759។ ខ្ញុំសូមដកស្រង់៖ "បញ្ហាសំខាន់ដែលត្រូវផ្តោត គឺត្រូវបោសសម្អាតភ្នាក់ងារ សេ.អ៊ី.អា, ភ្នាក់ងារ កា.ហ្សេ.បេ និងយួនលេបទឹកដី ព្រមទាំងបរិវាររបស់ពួកវានៅទូទាំងបក្ស ហើយនិងក្នុងកងកម្លាំង ហើយត្រូវកម្ទេចជារៀងរហូត ដើម្បីការពារមិនឲ្យពួកវាជ្រៀតចូលក្នុងបក្សយោធា និងប្រជាជនយើង។ ចំពោះឫសគល់ដើមរបស់ពួកវា គឺនៅតែបន្តមាន ប៉ុន្តែយើងត្រូវកម្ទេចឲ្យក្លាយទៅជាផេះផង់ ហើយត្រូវបោសសម្អាត ដើម្បីសម្អាតឲ្យអស់ចេញពីទឹកដីរបស់យើង។"

ចំណុចបន្ទាប់ គឺនៅត្រង់ភាសាអង់គ្លេស 00458506, ខ្មែរមានលេខ 00062998 និងបារាំងមានលេខ 00479764 គឺមានការណែនាំមូលដ្ឋាន និងកងកម្លាំងទាំងអស់ត្រូវរៀបចំការសិក្សាឯកសារមួយនេះ ចាំបាច់ត្រូវរៀបចំនូវការរៀនសូត្រជារួម ជាសមូហភាព ហើយត្រូវមានការសិក្សាជាក្រុម ឬក៏ជាបុគ្គល។

លោក លោកស្រីចៅក្រម យើងលើកយកឯកសារទាំងអស់នេះ ដើម្បីបង្ហាញថា បក្សកុម្មុយនីស្តកម្ពុជាមានគោលនយោបាយតាំងពីកម្រិតកំពូល រហូតដល់កម្រិតទាបបំផុតនៅក្នុងប្រទេសកម្ពុជា។ ហើយអ្វីដែលបានបញ្ជាក់ គឺថា មានការបញ្ជូនទៅកម្មាភិបាលថ្នាក់ក្រោម ហើយនិងការបង្ហាញថាវៀត-ណាមមិនមែនត្រឹមតែជាខ្មាំងផ្ទៃក្រៅទេ ក៏ប៉ុន្តែសូម្បីតែក្នុងប្រទេស ក៏គេចាត់ទុកថា ជាខ្មាំងផងដែរ។

[១១:២៤:៤២]

ឥឡូវនេះខ្ញុំសូមយោងបន្តទៅឯកសារឆ្នាំ -- ឯកសារខែមេសា ៧៧ គឺឯកសារ E3/18 ជាសៀវភៅរបស់ ខៀវ សំផន ដែលមានចំណងជើងថា "ប្រវត្តិសាស្ត្រកន្លងមក និងមូលហេតុនៅពីក្រោយការសម្រេចចិត្តរបស់ខ្ញុំ" គឺនិយាយអំពីការវាយប្រហារនៅក្នុងប្រទេសវៀតណាម ដែលធ្វើឡើងដោយកងទ័ពកម្ពុជាប្រជាធិបតេយ្យ នៅប្រហែលជានៅក្នុងខែមេសា ៧៧។ នៅពេលនោះគឺមានបង្ហាញថា បក្សកុម្មុយនីស្តកម្ពុជាបានធ្វើការវាយប្រហារ និងកម្ទេចយ៉ាងខ្លាំងទៅលើវៀតណាម។ នៅភាសាអង់គ្លេសមានលេខ 01103759ដល់60, ខ្មែរមានលេខ 00103849ដល់50, បារាំងមានលេខ 005954

46។ ខៀវ សំផន បានបញ្ជាក់នៅក្នុងសៀវភៅរបស់គាត់ថា៖ "ខ្ញុំដឹងអំពីការវាយប្រហាររបស់កម្ពុជាទៅលើភូមិទីញបៀន នៅក្នុងស្រុកអានយ៉ាង នៅចុងខែមេសា ៧៧។ វៀតណាមបានឆ្លើយតបទៅនឹងវាយប្រហារនេះ ដោយប្រើប្រាស់យន្តហោះអា-៣៧ ជាជយភណ្ឌ។ រឿងនេះក៏បាននាំឲ្យខ្មែរក្រហមតបតទៅវិញ ដោយចូលទៅលុកលុយនៅក្នុងតៃនិញ ហើយនិងហាទៀង។ ច្បាស់ណាស់ថា ហើយនៅក្នុងហេតុការណ៍បានកើតឡើង គឺមិនអាចចៀសវាងបាន។ មិនការឆ្ងល់ឡើយថា ខ្មែរក្រហមបានធ្វើការវាយកម្ទេចទៅលើវៀតណាមនៅតាមព្រំដែន ប្រព្រឹត្តនូវឧក្រិដ្ឋកម្មប្រឆាំងជនស៊ីវិលវៀតណាម។ នៅពេលដែលខ្ញុំដឹងអំពីអំពើហិង្សាបែបនេះ ខ្ញុំហាក់ដូចជាមានការឆ្លើយតបយ៉ាងខ្លាំង។"

មូលហេតុដែលយើងដាក់ឯកសារនេះ គឺមិនមែនដើម្បីបង្ហាញអំពីការវាយប្រហារនៅប្រទេសវៀតណាមនោះឡើយ ប៉ុន្តែដើម្បីបង្ហាញអំពីចេតនារបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងជនស៊ីវិលវៀតណាម ដែលមិនមែនជាការវាយប្រហារប្រឆាំងយុទ្ធជនវៀតណាមនោះឡើយ។

[១១:២៧:២១]

ដើម្បីគាំទ្រដល់ហេតុការណ៍នេះ ក៏ដូចជាការដែល ខៀវ សំផន បានលើកឡើងអំពីឯកសារនេះ គឺខ្ញុំសូមលើកយកឯកសារ E3/7336 ដែលនិយាយអំពីហេតុអ្វីបានជាវៀតណាមបានជានេះ គឺមានតែគឺមិនមានភាសាបកប្រែជាភាសាខ្មែរ ឬបារាំងឡើយ គឺមានតែអង់គ្លេសមានលេខ 01001765។ ខ្ញុំសូមដកស្រង់នូវឯកសារមួយនេះ៖ "នៅខែមេសា ៧៧ នៅក្នុងខួបលើកទី២នៃការរំដោះទីក្រុងភ្នំពេញ រដ្ឋាភិបាល និងប្រព័ន្ធផ្សព្វផ្សាយដែលគ្រប់គ្រងដោយរដ្ឋាភិបាលនៅទីក្រុងហាណូយ បានផ្តល់នូវការអបអរសាទរ និងការសសើរដល់របបកម្ពុជាប្រជាធិបតេយ្យ។ ជាកាយវិការសាធារណៈ រដ្ឋាភិបាលមិនបានបង្ហាញអំពីការតានតឹង ឬក៏ការស្អប់ខ្ពើមប្រឆាំងនឹងប្រទេសជិតខាងឡើយ។ ឡានដាន បានបញ្ចេញនូវព័ត៌មានអំពីប្រតិភូស្ត្រីវៀតណាមដែលទើបតែត្រឡប់មកពីប្រទេសកម្ពុជា គឺបានបញ្ជាក់ថា ប្រជាជនកម្ពុជាបានចូលរួមក្នុងការងារសាងសង់ទំនប់យ៉ាងសស្រាក់សស្រាំ ស្ត្រីនិងបុរសបានចូលរួមជាមួយគ្នាយ៉ាងសស្រាក់សស្រាំ។ ហើយបក្សវៀតណាមនិងមេដឹកនាំរដ្ឋបានបញ្ជូនសារអបអរសាទរទៅដៃគូរបស់ខ្លួននៅខួបជ័យជម្នះរបស់វៀតណាម។ ប៉ុន្តែចេតនាបំណងល្អនេះៗ គឺមិនទទួលបានផលប្រយោជន៍នោះឡើយ។ ខ្មែរក្រហមបានសម្រេចជ្រើសរើសខួបលើកទី២ របស់បក្សកុម្មុយនីស្តវៀតណាមដែលបានវាយឈ្នះលើវៀតណាមខាងត្បូង ដើម្បីធ្វើការវាយប្រហារយ៉ាងបង្ហូរឈាម។ នៅថ្ងៃ៣០ មេសា ៧៧ ខ្មែរក្រហមបានវាយប្រហារភូមិជាច្រើននៅក្នុងអានយ៉ាង និងចូវដុក ដោយបានដុតកម្ទេចផ្ទះ និងសម្លាប់

ប្រជាជនស៊ីវិលរាប់រយនាក់។ មេដឹកនាំវៀតណាមមានការរន្ធត់យ៉ាងខ្លាំង ដោយសារការវាយប្រហារដែលមិនមានការដុត ហើយក៏មិនយល់អំពីហេតុផលជាយុទ្ធសាស្ត្រនៅពីក្រោយការវាយប្រហារនេះឡើយ ប៉ុន្តែជាលទ្ធផលពួកគេសម្រេចឆ្លើយតប។ យោងទៅតាមអនុបញ្ជាការស្រុកតៃនិញវៀតណាម គឺក្នុងខែមេសា-ឧសភា ៧៧ ខ្មែរក្រហមបានធ្វើការវាយប្រហារជាប្រព័ន្ធប្រឆាំងភូមិនៅតាមព្រំដែនវៀតណាម ដែលធ្វើឱ្យកសិករវៀតណាមមិនអាចធ្វើការនៅទីនោះបាន។ ខាងវៀតណាម បានអះអាងថា បន្ទាប់មកទៀតពួកគេបានធ្វើការដោះស្រាយបញ្ហាព្រំដែនដោយសន្តិវិធីជាមួយខ្មែរក្រហម ប៉ុន្តែត្រូវបានបដិសេធ។

[១១:៣០:១៦]

យោងទៅតាមវៀតណាម ខ្មែរក្រហមបន្តមកទៀត បានបញ្ជូនកងពលពីរមកព្រំដែន ដែលនៅៗជាប់ស្រុកតៃនិញ ហើយនៅក្នុងខែឧសភា កងកម្លាំងបានធ្វើការវាយប្រហារយ៉ាងធ្ងន់ធ្ងរទៅលើទឹកដីវៀតណាម។” ឯកសារទាំងអស់នេះ គឺគាំទ្រទៅដល់ការពិតដែលថា នៅក្នុងខែមេសា ៧៧ គឺមានការវាយប្រហារយ៉ាងធ្ងន់ធ្ងរ ដោយបក្សកុម្មុយនីស្តកម្ពុជា ប្រឆាំងជនស៊ីវិលនៅវៀតណាម។ ហើយក៏បានបង្ហាញផងដែរថា ជនស៊ីវិលវៀតណាម ទោះបីថានៅមានទូទាំងប្រទេសកម្ពុជាក៏ដោយ ត្រូវបានគេចាត់ទុកថា ជាខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជា។

ឥឡូវនេះ ខ្ញុំសូមបន្តយោងទៅលើរបាយការណ៍ស្រុកត្រាំកក់ គឺនៅក្នុងខែមេសា ៧៧ គឺឯកសារ E3/2435 ហើយមានការស្នើសុំការណែនាំពីមេឃុំអង្គតាសោម ផ្ញើជូនមន្ទីរស្រុកត្រាំកក់។ ភាសាអង់គ្លេសមានលេខ 00322141, ខ្មែរមានលេខ 00271001ដល់02, បារាំងមានលេខ 00612225។ ហើយចំណងជើងមានចំណងជើងថា “លិខិតស្នើសុំមតិយោបល់ ផ្ញើជូនអង្គការស្រុកជាទីគោរពស្រឡាញ់”។ ខ្ញុំសូមដកស្រង់៖ “ពាក់ព័ន្ធទៅនឹងការចុះឈ្មោះប្រជាជនកម្ពុជាក្រោម ខ្ញុំចង់ដឹង ខ្ញុំចង់រាយការណ៍ដូចតទៅនោះ។ ប្តីដែលរស់នៅក្នុងប្រទេសកម្ពុជា បានរៀបការជាមួយប្រពន្ធមកពីប្រទេសយួន ប៉ុន្តែអ្នកខ្លះទៀត ជាជនជាតិយួន គឺប្តីយួន រៀបការជាមួយប្រពន្ធវៀតណាម។ បន្ទាប់ពីយើងចុះឈ្មោះពួកគេទៅក្នុងបញ្ជីហើយ ពួកគេបានមកស្នើសុំត្រឡប់ទៅប្រទេសវៀតណាមវិញ។ ប្រសិនបើអង្គការអនុញ្ញាត ពួកគេនឹងឱ្យទៅបាន។ ប្រសិនបើពួកគេទាំងអស់ជាយួន យើងនឹងបញ្ជូនគ្រួសារទាំងនេះ ទៅអង្គការ។ ប្រសិនបើដូច្នេះមែន តើអង្គការសម្រេចយ៉ាងដូចម្តេចដែរ? សូមអង្គការផ្តល់មតិយោបល់។”

[១១:៣២:៤៧]

នេះគឺជាឯកសារដែលបង្ហាញថា ជនស៊ីវិលវៀតណាមនៅក្នុងប្រទេសកម្ពុជា ត្រូវបានគេកំណត់

គោលដៅ ដោយសារតែពូជសាសន៍របស់ពួកគេ។ ហើយក៏បានបង្ហាញផងដែរថា វៀតណាមសុទ្ធ គឺគ្រួសារវៀតណាមសុទ្ធ ត្រូវបានគេកំណត់គោលដៅសម្រាប់ការសម្លាប់។

ខ្ញុំគិតថា ឥឡូវនេះ គឺម៉ោងដប់មួយសាមសិបនាទីហើយ ដូច្នេះតើលោកប្រធានចង់សម្រាក ឬក៏យ៉ាងម៉េច ឬក៏សម្រេចយ៉ាងដូចម្ដេចដែរ?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ឥឡូវនេះ ដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាក ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឱ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការ នៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះ ឱ្យបានមុនម៉ោងមួយកន្លះ។

បាទ សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៣៣ នាទី ដល់ម៉ោង ១៣:៣៣ នាទី)*

[១៣:៣៣:៤១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយមុននឹងផ្ដល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញា អង្គជំនុំជម្រះក៏ចង់ដឹងពីការប្រើប្រាស់ពេលវេលារវាងតំណាងសហព្រះរាជអាជ្ញាជាមួយនឹងក្រុមសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងការដាក់បង្ហាញឯកសារហ្នឹង ប្រើប្រាស់ពេលវេលាយ៉ាងម៉េចដែរ?

**លោក វីល្លៀម ស្មីត៖**

បាទ ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម។ ខាងព្រះរាជអាជ្ញាស្នើសុំ៤៥នាទីទៀត ប្រសិនបើអាច។ ហើយវគ្គបន្ត គឺយើងនឹងជជែកអំពីការកំណត់គោលដៅទៅលើជនជាតិវៀត-

ណាម។ ហើយប្រសិនបើអាច ខ្ញុំសូមបង្ហាញ សូមចំណាយពេល៤៥នាទីដើម្បីនិយាយអំពីការកំណត់គោលដៅទៅលើទាហាន លន់ នល់។ ហើយខ្ញុំគិតថា វៀតណាម -- ខ្ញុំគិតថាខាងព្រះរាជអាជ្ញាអាចបន្តពីម៉ោង -- ខាងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីអាចតពីម៉ោងបីដល់ម៉ោងបួន។ ហើយខ្ញុំនឹងលើកយកនូវឯកសារមួយចំនួនដើម្បីគាំទ្រដល់ការអះអាងរបស់ខ្ញុំ។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតលោកប្រធានបង្ហាញៗប្រហែលជា៤៥នាទី។

[១៣:៣៥:៣១]

**ប្រធានអង្គជំនុំ៖**

យ៉ាងម៉េចទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី?

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ដូចការបញ្ជាក់របស់ខាងសហព្រះរាជអាជ្ញា គឺខាងមេធាវីនាំមុខត្រូវការរយៈពេលមួយម៉ោង។ ដូច្នេះគឺចាប់ពីម៉ោងបីរហូតទៅដល់ម៉ោងបួនលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះអនុញ្ញាត!

សូមអញ្ជើញ!

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ គឺយើងបានផ្អាកនៅខែមេសា ឆ្នាំ៧៩ ឥឡូវនេះខ្ញុំសូមត្រឡប់ទៅការប្រជុំថ្ងៃ១៥ មិថុនា ៧៥ គឺឯកសារ E3/240 ជាសារទូរលេខមកពីភូមិភាគពាយ័ព្យផ្ញើជូនទៅមជ្ឈិមបក្ស។

[១៣:៣៦:៣៤]

ខ្ញុំសូមដកស្រង់នូវភាសាអង់គ្លេសមានលេខ00897667ដល់68, ភាសាខ្មែរនៅត្រង់លេខ 0000 1266 ដល់67 និងបារាំងមានលេខ 00282550 ដល់51។ ខ្ញុំសូមអានដោយសង្ខេបនូវរបាយការណ៍៖ “ខាងលេខាភូមិភាគពាយ័ព្យនៅម៉ោងប្រាំបួនព្រឹក និងថ្ងៃ១៤ មិថុនា កងផលិត៨០១ ដែលមានទីតាំងនៅ១០៧ ក្នុងពេលដែលធ្វើការត្រួតពិនិត្យបានចាប់ខ្លួនទាហានវៀតណាម២០៩នាក់ រួមបញ្ចូលទាំងស្ត្រីចំនួនប្រាំបួននាក់នៅក្នុងបរិវេណអូរឡាក់ចម្ងាយ៤គីឡូម៉ែត្រពីផ្លូវលេខ៩។ ពួកគេសឹងតែទាំងអស់ជាជនជាតិ

ចាវ៉ាយដែលនិយាយភាសាខ្មែរ ប៉ុន្តែមានតុងជាជនជាតិ។ ពួកគេត្រូវបានរក្សាទុកនៅកន្លែងឃុំឃាំងរបស់យើង។ ហើយពួកគេបានរៀបរាប់បន្តទៅទៀតថា ផ្អែកទៅលើការពិនិត្យរបស់យើង ពួកគេគឺជាខ្មាំងមកពីខាងក្រៅដែលមានចេតនាមកចូលស៊ើបរូងផ្ទៃក្នុងចូលតំបន់របស់យើង ប៉ុន្តែមិនអាចធ្វើបាន ដូច្នេះគេក៏ផ្លាស់ប្តូរទីតាំងរបស់ពួកគេ។" សូមបញ្ចប់ការដកស្រង់។

លោក លោកស្រីចៅក្រម ភូមិភាគពាយ័ព្យមិនបានជឿជាក់ទៅលើពួកគេនេះ ហើយនៅចុងបញ្ចប់នៃឯកសារ គឺគេស្នើសុំឲ្យមានមតិណែនាំពីអង្គការ។ ហើយឯកសារនេះបានចម្លងជូន ប៉ុល ពត, នួន ជា និងអ្នកដទៃទៀត ហើយនិងផ្ញើជូនមន្ទីរនិងឯកសារ។

លោក លោកស្រីចៅក្រមនៅក្នុងសំណុំរឿងគឺមានភស្តុតាងដែលបង្ហាញថា ហើយមានសាក្សីនៅកចាខណ្ឌ៨០៤ ដែលបានបញ្ជាក់ថា កងកម្លាំងវៀតណាមត្រូវបានគេសម្លាប់។ ហើយឯកសារដែលពាក់ព័ន្ធផងដែរ គឺចង់និយាយថាមានគោលនយោបាយក្នុងការសម្លាប់យុទ្ធជន ឬក៏ជនស៊ីវិលជាជនជាតិវៀតណាម។

[១៣:៣៩:០០]

ឯកសារបន្តគឺ ខ្ញុំចង់យោងទៅលើរបាយការណ៍កំណត់ហេតុត្រាំកក់ ថ្ងៃទី០៤ ខែកញ្ញា ៧៧, ឯកសារ E3/4112។ នេះគឺជារបាយការណ៍មកពីស្រុក ហើយប្រធានស្រុកក្បាលប៉ោ បានរាយការណ៍អំពីបុគ្គលមួយចំនួនឈ្មោះ ហេង។ ហើយរបាយការណ៍បាននិយាយថា គាត់ហ្នឹងជាមនុស្សខ្ជិលច្រអូស ហើយបានរៀបរាប់ថាតើគាត់ខ្ជិលហ្នឹងខ្ជិលដោយរបៀបណា។ គឺថាគាត់ឈឺ ប៉ុន្តែស៊ីបានច្រើន ហើយរបាយការណ៍ហ្នឹងបាននិយាយបន្តទៅទៀតថា ឈ្មោះ ហៀក ហ្នឹងគឺជាកូនកាត់យួន។ គឺមាននៅត្រង់ឯកសារ E គឺឯកសារលេខ 00322155, ខ្មែរ 00270987 ដល់88 និងបារាំងមានលេខ 00623850។ លោក លោកស្រីចៅក្រម ឯកសារនេះ បានបញ្ជាក់ថា ហៀក គឺជាកូនកាត់វៀតណាមដែលឯកសារនេះបង្ហាញថា មានការកំណត់គោលដៅទៅលើជនស៊ីវិលវៀតណាមនៅក្នុងស្រុកត្រាំកក់។

ឥឡូវនេះខ្ញុំសូមបន្តទៅថ្ងៃ០៦ ខែកញ្ញា ៧៧ គឺឯកសារដដែល E3/2447, ភាសាអង់គ្លេសមានលេខ 00355474, ខ្មែរមានលេខ 00270733 ដល់ 34 និងបារាំងមានលេខ 00632162។ គឺជារបាយការណ៍ប្រហាក់ប្រហែលគ្នានេះដែរ ដែលរបាយការណ៍នេះបានបញ្ជាក់អំពីឈ្មោះ ហ៊ី ឌី ជាយុទ្ធជននៅក្នុងឃុំលាយបូរ ដែលនិយាយថា គាត់មិនចង់រស់នៅ -- មិនរស់ទេ គាត់ចង់តែស្លាប់។ របាយការណ៍នេះ បានរៀបរាប់ថាគាត់តវ៉ាច្រើន គឺតវ៉ាពីរឿងអត់បាយហូប ហើយគាត់ -- ហើយបន្តទៅទៀត

បាននិយាយថា ហើយរបាយការណ៍បាននិយាយថា បុគ្គលម្នាក់នេះគឺជាយួន។ ហើយខាងក្រោមបន្តិច នៅក្នុងរបាយការណ៍នេះដែរ គឺសមមិត្ត គិត នៅថ្ងៃ០៦ ខែកញ្ញា ៧៧ បានស្នើសុំឲ្យមានការស៊ើបអង្កេត ពីព្រោះបុគ្គលនេះគឺជាខ្សែបណ្តាញរបស់ សេ.អ៊ី.អា។

[១៣:៤១:៤៥]

ដូច្នេះខ្ញុំចង់បញ្ជាក់ឡើងវិញថា នេះគឺជាភ័ស្តុតាងនៃគោលនយោបាយក្នុងការកំណត់មុខសញ្ញា ទៅលើជនជាតិវៀតណាមដែលជាជនស៊ីវិលនៅក្នុងស្រុកត្រាំកក់។

ហើយខាងក្រោមបន្តិច គឺឯកសារ E3/2050 គឺថ្ងៃ១៧ កញ្ញា ៧៧ គឺជាកំណត់ត្រាស្រុកត្រាំកក់ ដដែល។ នៅត្រង់ភាសាអង់គ្លេសមានលេខ 00276576 ដល់77, ខ្មែរមានលេខ 00079111 និងបារាំង មានលេខ 00858072។ របាយការណ៍នេះចុះនៅថ្ងៃ១៧ កញ្ញា ៧៧ ផ្ញើជូនអង្គការស្រុក ហើយនិយាយ អំពីការចាប់ស្ត្រីបីនាក់។ ហើយរបាយការណ៍នេះ បញ្ជាក់អំពីស្ត្រីហ្នឹងឈ្លោះគ្នា ដោយសារតែគេមិនចង់ ធ្វើការ ពីព្រោះគេធ្វើវាច្រើនរួចណាស់ទៅហើយ។ ហើយគេបាននិយាយថា ស្ត្រីទាំងបីនាក់ គឺទី១ ឈ្មោះ នាង អឿ គឺជាជនជាតិយួន ជាប្រពន្ធមេស្រុក។ អង្គការបានកម្ទេចប្តីរួចទៅហើយ។

ហើយព្រះរាជអាជ្ញាសូមលើកឡើងថា ការណ៍នេះបានបង្ហាញថា ជនស៊ីវិលវៀតណាម ត្រូវបាន គេកំណត់គោលដៅចាប់ ហើយនិងត្រូវបានចាប់ខ្លួន ដោយសារតែពួកគេជាជនជាតិវៀតណាម។

ឥឡូវនេះ ខ្ញុំចង់លើកយកនូវឯកសារថ្ងៃ០១ មករា ៧៨ គឺឯកសារ E3/248, អង់គ្លេសមានលេខ 00324809, ខ្មែរមានលេខ 00021054 និងបារាំងមានលេខ 00631446។ នេះគឺជារបាយការណ៍មក ពី សៅ សារុន ផ្ញើជូនមន្ទីរ៨៧០ ហើយគាត់រាយការណ៍អំពីស្ថានភាពសន្តិសុខ។ គាត់បានបញ្ជាក់ថា៖ “ជូនចំពោះបងមន្ទីរ៨៧០ ជាទីគោរពស្រឡាញ់។ យើងចង់រាយការណ៍អំពីជនជាតិយួនប្រាំបីនាក់ដែល រត់ចេញពីប្រទេសយើង។ យោងតាមការសួរចម្លើយ ពួកគេបាននិយាយថា យួនបានចាត់តាំងពួកគេឲ្យ មកស៊ើបអង្កេត ស៊ើបការណ៍ក្នុងប្រទេសកម្ពុជា ហើយរស់នៅជាមួយប្រជាជនកម្ពុជា ដើម្បីក្តោបក្តាប់ ប្រជាជនកម្ពុជា។ ហើយបានបញ្ជាក់បន្តទៀតថាឥឡូវនេះយើងបានបោសសម្អាតពួកគេចោលហើយ។”

[១៣:៤៤:៤០]

យើងសូមបញ្ជាក់ថា ចំណុចនេះបង្ហាញថា ជនជាតិវៀតណាម ទោះបីជាជនស៊ីវិលក៏ដោយ ជា គិញក៏ដោយ ជាទាហានក៏ដោយ ត្រូវបានបោសសម្អាតដោយបក្សកុម្មុយនីស្តកម្ពុជា ហើយមិនទទួល បានការការពារតាមរយៈអនុសញ្ញាទីក្រុងវីយែន ដែលនិយាយអំពី--។

ឥឡូវនេះខ្ញុំសូមបន្តទៅលើឯកសារបន្ត គឺ E3/741 ដែលជាការណែនាំរបស់មន្ទីរ៨៧០ គឺជាឯកសារចុះថ្ងៃទី០៣ មករា ១៩៧៨ ហើយឯកសារនេះគឺពាក់ព័ន្ធទៅនឹងការណែនាំរបស់បក្សកុម្មុយនីស្តកម្ពុជាផ្ញើទៅកងពល និងទាហានទាំងអស់អំពីយុទ្ធសាស្ត្រប្រឆាំងជាមួយនឹងកងកម្លាំងវៀតណាម និងគិញរបស់វៀតណាម។ ហើយខ្ញុំសូមយោងទៅលើកថាខណ្ឌទី២ ប្រហែលជាខ្ញុំអាចផ្តល់នូវឯកសារយោង គឺឯកសារ ERN អង់គ្លេសមានលេខ 00296006 ទៅ 07, ខ្មែរមានលេខ 0028428*(ស៊ីក)* ដល់ 82 និងបារាំងមានលេខ 00611867 ដល់68។ ហើយកថាខណ្ឌបានបញ្ជាក់៖ "និយាយសង្ខេបទៅ គឺថាវាជាគោលនយោបាយ ជាមនោគមន៍វិជ្ជា និងអង្គការដើម្បីកម្ទេចភ្នាក់ងារ ក៏ដូចជាសកម្មភាពស៊ីរូងផ្ទៃក្នុង និងសង្គ្រាម ព្រមទាំងខ្មាំង។ ដូច្នេះទាំងបក្ស ទាំងភូមិភាគ តំបន់ និងមេបញ្ជាការសមរភូមិត្រូវតែច្បាស់លាស់ ត្រូវតែមានវិធានការ ហើយសហការឲ្យជិតស្និទ្ធ។ ហើយបានបន្តទៅទៀតថា ចាំបាច់ត្រូវធ្វើការងារនយោបាយ មនោគមន៍វិជ្ជា និងអង្គការក្នុងចំណោមប្រជាជនដើម្បីធ្វើឲ្យពួកគេកក់ក្តៅ ដោះស្រាយបញ្ហារស់នៅ និងជម្រក។ ចាំបាច់ត្រូវម្ហូប ត្រូវមានកម្មាភិបាលមូលដ្ឋានរឹងមាំ ដែលត្រូវពង្រឹងហើយនិងត្រូវពង្រីកនូវកំហឹងជាតិ កំហឹងវណ្ណៈប្រឆាំងជាមួយនឹងខ្មាំងយួន ក៏ដូចជាបង្កើតឲ្យមានកំហឹងផ្នែកសម្ភារៈផងដែរ។

[១៣:៤៧:៣៥]

លោក លោកស្រីចៅក្រម ខ្ញុំសូមបញ្ជាក់ថា ឯកសារនេះនឹងជួយក្នុងការបង្ហាញភ័ស្តុតាងថា ជនជាតិវៀតណាមនៅក្នុងប្រទេសកម្ពុជា គឺជាគោលដៅនៃអំពើហិង្សា។ ហើយឯកសារបានបញ្ជាក់ពីការបង្កើតឲ្យមាននូវបរិយាកាសមួយដែលមានការភ័យខ្លាចយ៉ាងខ្លាំង ប្រឆាំងចំពោះជនជាតិវៀតណាមទាំងជនស៊ីវិល និងយោធា។

ឥឡូវនេះខ្ញុំសូមបន្តទៅថ្ងៃទី១៦ មករា ៧៨ គឺឯកសារ E3/4127។ ឯកសារនេះគឺពាក់ព័ន្ធទៅនឹងកំណត់ត្រាស្រុកត្រាំកក់ អង់គ្លេសមានលេខ 00362232, ខ្មែរមានលេខ 00270809 និងបារាំងមានលេខ 00632507។ នេះគឺជារបាយការណ៍មកពីត្រពាំងធំត្បូង ហើយគាត់បានផ្ញើរបាយការណ៍នេះជូនសមមិត្ត អាន ដើម្បីជូនដំណឹងអំពីសកម្មភាពខ្មាំង ដែលត្រូវបានបញ្ជូនដូចតទៅនេះ។ គាត់បាននិយាយអំពីមនុស្សម្នាក់ឈ្មោះ ណាំ ហើយរបាយការណ៍នេះបានបញ្ជាក់ថា គាត់តវ៉ាអំពីការបន្តបដិវត្តន៍។ ហើយកថាខណ្ឌទី៣ បានបញ្ជាក់ថា៖ "អាណាំ គឺជាយួនសុទ្ធ ហើយគាត់ស្នើសុំឲ្យសមមិត្តបង ទទួលដឹងឮអំពីព័ត៌មាននេះ។" ហើយនេះគឺជាភ័ស្តុតាងបន្ថែមមួយទៀត ដែលថាជនស៊ីវិលត្រូវបានគេកំណត់គោលដៅ

ដោយសារតែពួកគេជាជនជាតិវៀតណាម។

[១៣:៤៩:៣៨]

ឥឡូវនេះខ្ញុំសូមបន្តទៅឯកសារ ២៩ មករា ៧៨ ឯកសារ E3/1249 ERN មានលេខ 00008894ដល់95 ជាភាសាអង់គ្លេស, ជាភាសាខ្មែរមានលេខ 00224832 និងភាសាបារាំងមានលេខ 00292683។ នេះ គឺជារបាយការណ៍របស់ហ្វីប៊ីស មកពីភ្នំពេញ *ហូមសឺវីស* ដែលបានបញ្ជាក់អំពីថ្ងៃ២៩ មករា ៧៨ ហើយរបាយការណ៍នេះ ទាក់ទងទៅនឹងការផ្សព្វផ្សាយចម្លើយសារភាពដែលទទួលបានពីជនជាតិវៀតណាមដែលចាប់ខ្លួនបាន។ ហើយចម្លើយសារភាពនេះ បានពន្យល់អំពីគោលដៅរបស់ទាហានវៀត-ណាម។ ហើយយើងសូមបញ្ជាក់ផងដែរថា ឯកសារនេះជួយក្នុងការបង្ហាញថា ជនជាតិវៀតណាមដែលត្រូវបានចាប់ខ្លួន គឺទាហានវៀតណាមដែលត្រូវបានចាប់ខ្លួននោះ ត្រូវបានគេធ្វើទារុណកម្ម ដើម្បីទទួលបានចម្លើយ ហើយចម្លើយដែលទទួលបានដោយទារុណកម្មហ្នឹង ត្រូវបានផ្សព្វផ្សាយតាមវិទ្យុដើម្បីដុតកំហឹងដល់ប្រជាជនស៊ីវិល ឲ្យមានប្រតិកម្មចំពោះការបំផ្លាញទៅលើទាហាន ក៏ដូចជាបំផ្លាញទៅលើជនស៊ីវិលវៀតណាម។ ហើយការផ្សព្វផ្សាយអំពីចម្លើយសារភាពនេះ គឺគេការផ្សព្វផ្សាយដោយស្ថានីយ៍វិទ្យុរបស់ទីក្រុងភ្នំពេញ។

[១៣:៥១:២៩]

ប្រសិនបើយើងមើលឯកសារ E3/9423 គឺជាបញ្ជីអ្នកទោសមកពី ស-២១ គឺមានប្រជាជន -- គឺមានអ្នកទោស២០០នាក់ជាង ដែលត្រូវបានកត់ត្រានៅក្នុងបញ្ជីអ្នកទោសធំ គឺឯកសារ E3/243។ ហើយបញ្ជីនេះ ត្រូវបានដោះស្រង់ចេញបញ្ជីធំមួយ ដើម្បីបង្ហាញ ដើម្បីជាកំណត់ត្រា ថាតើៗមានជនជាតិវៀតណាមប៉ុន្មាននាក់ ត្រូវបានគេបញ្ជូនទៅស-២១។ ក្នុងចំណោម៣៤៥នាក់ គឺមានអ្នកផ្តល់ចម្លើយសារភាពដែលគេយកទៅផ្សាយតាមស្ថានីយ៍វិទ្យុ។ ខ្ញុំសូមផ្តល់នូវចំនួននេះ ប៉ុន្តែចំនួននេះបានបង្ហាញថា អ្នកទោសវៀតណាមដែលត្រូវបានគេសួរចម្លើយ តាមរយៈការធ្វើទារុណកម្មនោះ ត្រូវបានគេប្រើប្រាស់ធ្វើជាមធ្យោបាយឃោសនា ដើម្បីដុតកំហឹងដល់ប្រជាជនកម្ពុជា ហើយនិងកងកម្លាំងប្រជាជនកម្ពុជា ឲ្យងើបឡើងប្រឆាំងនឹងវៀតណាម។

លោក លោកស្រីចៅក្រម ប្រហែលជាបានឃើញតាមរយៈបញ្ជីហ្នឹង គឺមានអ្នកទោសពីបញ្ជីឈ្មោះអ្នកទោសដែលចូល ស-២១ ចាប់ពីឆ្នាំ៧៦ ហើយភាគច្រើនចូលឆ្នាំ៧៦។ ហើយអ្នកទោសភាគច្រើនត្រូវបានគេរៀប មិនមែនសរសេរថា ជាទាហានវៀតណាមទេ គឺគេនិយាយថា ជាគិញរបស់វៀត-

ណាម មកពីផ្នែកជាច្រើននៃប្រទេសកម្ពុជា ឧទាហរណ៍ដូចជាមកពីខាងព្រំដែនបូព៌ាជាដើម។ ដូច្នេះខ្ញុំចង់បញ្ជាក់ថា ឯកសារមួយនេះ ជួយក្នុងការបង្ហាញថា យុទ្ធជន និងជនស៊ីវិលរបស់វៀតណាម ត្រូវបានគេចាប់ខ្លួន ហើយគេបញ្ជូនទៅ ស-២១។ ហើយចុងក្រោយ ត្រូវបានសម្លាប់ដោយមិនផ្ដល់ឱកាស ឬក៏មិនបានផ្ដល់នូវមធ្យោបាយការពារជាអប្បបរមា តាមអនុសញ្ញាទីក្រុងហ្សឺណែវនោះឡើយ។

[១៣:៥៣:៥៣]

ឥឡូវនេះ ខ្ញុំសូមបន្តទៅឯកសារថ្ងៃ១៤ កុម្ភៈ ៧៨ ឯកសារ E3/9375។ ហើយនេះគឺរៀបរាប់អំពីសារទូរលេខយោធា ដែលបានចម្លងជូន នួន ជា ហើយរៀបរាប់អំពីការដាក់កម្លាំងរបស់វៀតណាម ហើយនិងរាយការណ៍អំពីការចាប់ខ្លួនវៀតណាមពីរនាក់ ហើយបានបញ្ជូនទៅ ស-២១។ ហើយឯកសារនេះ បានចម្លងជូនទៅ ប៉ុល ពត, នួន ជា គឺនៅត្រង់ភាសាអង់គ្លេស 01185439, ភាសាខ្មែរមានលេខ 00020949 និងភាសាបារាំងមានលេខ 00329533។ ហើយឯកសារនេះ ជួយដល់ការបង្ហាញថា មានគោលនយោបាយសម្លាប់យុទ្ធជន ឬក៏ជនស៊ីវិលរបស់វៀតណាម។

ឥឡូវនេះខ្ញុំសូមបន្តទៅឯកសារ ខែមករា, កុម្ភៈ ៧៨ គឺឯកសារ E3/726 ជាទស្សនាវដ្ដីយុវជនយុវនារីបដិវត្ត។ ហើយជាសង្ខេបទៅ ឯកសារនេះ គឺនិយាយអំពីស្ថានភាពខ្មាំង។ ជាពិសេសគឺនៅត្រង់ភាសាអង់គ្លេសមានលេខ 00278717, ភាសាខ្មែរមានលេខ 00063495 និងបារាំងមានលេខ 00524 420 ដល់21។ ដែលបានបញ្ជាក់ថា៖ “ចាំបាច់ត្រូវតែមើលឃើញភាពផ្ទុយគ្នាដូចមេឃ និងដី ជាមួយនឹងគ្រប់ប្រភេទខ្មាំងទាំងអស់ ជាពិសេសពួកឈ្លានពានលេបទឹកដីយួន ហើយនិងបនរបស់ពួកវា។” ហើយយើងសូមបញ្ជាក់ថា ការប្រើប្រាស់ពាក្យគ្រប់ប្រភេទនៃខ្មាំងខាងក្រៅ ហើយនិងយួន ខ្មាំងយួន និងបនរបស់ពួកវាហ្នឹង គឺបង្ហាញថា មិនមែនត្រឹមតែឲ្យមានការសម្លាប់ទាហានវៀតណាមប៉ុណ្ណោះទេ សូម្បីតែជនស៊ីវិលវៀតណាមក៏ត្រូវសម្លាប់ដែរ។

[១៣:៥៦:១០]

ឥឡូវនេះខ្ញុំសូមបន្តទៅឯកសារថ្ងៃ០១ មេសា ៧៨ គឺឯកសារ E3/928 នេះគឺជារបាយការណ៍របស់កងពល១៦៤ គឺ មាស មុត នៅថ្ងៃទី០១ មេសា ៧៨ បានចម្លងជូន ប៉ុល ពត, នួន ជា, អៀង សារី និងឯកសារ។ ភាសាអង់គ្លេសមានលេខ 00183357, ខ្មែរមានលេខ 00017026 និងបារាំងមានលេខ 00611668។ ឯកសារបានបញ្ជាក់ថា៖ “នៅថ្ងៃ០១ មេសា ៧៨ សរុបជនជាតិយួនដែលត្រូវបានចាប់ខ្លួន ហើយបាញ់ងាប់ចាប់ពីថ្ងៃ២៧ មេសា ៧៨ ដល់ថ្ងៃ៣០ មីនា ៧៨ គឺ១២០ក្បាល។” ហើយខ្ញុំសូម

បញ្ជាក់ថា នេះគឺចេតនារបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការសម្លាប់យុទ្ធជន និងជនស៊ីវិលវៀតណាម ដូចដែលគេបានបញ្ជាក់ គេបានចាប់ខ្លួន ហើយបាញ់ងាប់។

ឥឡូវនេះខ្ញុំសូមបន្តទៅឯកសារថ្ងៃ១៥ មេសា ៧៨ គឺឯកសារ E3/562 ហើយជាសេចក្ដីថ្លែងការណ៍របស់ ខៀវ សំផន ដែលជារបាយការណ៍របស់អង្គការដែលនិយាយអំពីខួបថ្ងៃ១៧ មេសា ៧៨ គឺជាខួបលើកទី៣ នៃការគ្រប់គ្រងប្រទេសកម្ពុជាដោយបក្សកុម្មុយនីស្តកម្ពុជា។ ហើយក្នុងសុន្ទរកថានេះគឺមានការចូលរួមប្រជាជន -- មានអ្នកចូលរួមចំនួន ២០.០០០នាក់ ហើយសុន្ទរកថានេះបាននិយាយអំពីប្រធានបទជាច្រើន ដូចជាជម្លោះប្រដាប់អាវុធជាមួយវៀតណាមជាដើម។ ឥឡូវនេះខ្ញុំសូមដកស្រង់នូវចំណុចមួយចំនួន គឺអង់គ្លេសមានលេខ S00010559 ដល់ 60, បារាំងមានលេខ 00280375 ហើយខ្ញុំគិតថា ផ្នែកនេះមិនមាននូវការបកប្រែជាភាសាខ្មែរនោះទេ។ ខៀវ សំផន បានបញ្ជាក់ថា ខ្ញុំសូមដកស្រង់៖ "ត្រូវវាយប្រហារឲ្យអស់ពីកម្លាំងកាយចិត្ត ដើម្បីបំពេញភារកិច្ចទាំងអស់របស់បក្សដែលបានចាត់តាំងមកយើងទាំងអស់គ្នា ដើម្បីគោរព ហើយនិងដើម្បីកម្ទេចជាអចិន្ត្រៃយ៍ទៅដល់ខ្មាំងគ្រប់ប្រភេទ ជាពិសេសពួកឈ្លានពាន ពួកឈ្លានពាន វាតទីនិយមវៀតណាមចេញពីដីកម្ពុជា។"

[១៣:៥៩:១២]

ហើយបន្តមកទៀត គឺមានដំណោះស្រាយមួយចំនួនត្រូវបានគេសម្រេច មានសេចក្ដីសម្រេចមួយចំនួនត្រូវបានធ្វើឡើង គឺភាសាអង់គ្លេសមានលេខ 00010563, ខ្មែរមានលេខ 00249989 និងភាសាបារាំងមានលេខ 00280380។ ហើយបានបញ្ជាក់អំពីចំណុចដូចតទៅនេះ៖ "ក្នុងការការពារជាតិ ដើម្បីបណ្ដេញឲ្យចេញពីដែនដីកម្ពុជា និងកម្ទេចជាអចិន្ត្រៃយ៍នូវពួកវាតទីនិយមឈ្លានពានវៀតណាម ត្រូវកម្ទេចនៅគ្រប់ភ្នាក់ងារវាតទីនិយមឈ្លានពានវៀតណាមចេញពីកងកម្លាំងរបស់យើង និងចេញពីដែនដីកម្ពុជាជារៀងរហូត។"

យើងសូមបញ្ជាក់ថា ភ័ស្តុតាងនេះ បានបង្ហាញអំពីចេតនាការកម្ទេចទាំងយុទ្ធជន និងជនស៊ីវិលវៀតណាម ដែលគេប្រើពាក្យថា "ខ្មាំងគ្រប់ប្រភេទ" ហើយនិងគ្រប់ភ្នាក់ងារវៀតណាមទាំងអស់។

ហើយឥឡូវនេះ ខ្ញុំសូមយោងបន្តទៅទៀត ទៅឯកសារខែមេសា ឆ្នាំ៧៨ គឺឯកសារ E3/4604 គឺជាទស្សនាវដ្ដីទង់បដិវត្ត ហើយវាជាសុន្ទរកថារបស់ ប៉ុល ពត នៅក្នុងខួបជ័យជម្នះដដែលនេះ។ ហើយ ប៉ុល ពត បានបញ្ជាក់ថា គឺនៅត្រង់ភាសាអង់គ្លេសមានលេខ 00519836, ខ្មែរមានលេខ 0006 4717 និងភាសាបារាំងមានលេខ 00520348។ "ដំបូងថាតើយួនធ្លាប់វ៉ៃយើង ហើយឈ្នះយើងដែរទេ?

យួនចង់ឲ្យកម្ពុជាធ្លាក់ទៅក្នុងការគ្រប់គ្រងរបស់គេតាំងឆ្នាំ១៩៣០។ ក្នុងឆ្នាំ៧០ តើពួកគេអាចយកកម្ពុជាបានទេ? គេមិនអាចយកបានទេ។ ក្នុងឆ្នាំ៧៥ ពួកគេអាចយកកម្ពុជាបានទេ? អត់ទេ។ ចុះឥឡូវហ្នឹងតើយួនយ៉ាងម៉េចដែរ? គឺគ្មានយួននៅលើទឹកដីកម្ពុជាទេ។ កន្លងមក គឺមានប្រជាជនយួនជិត១លាននាក់ តើឥឡូវហ្នឹងសូម្បីតែមួយក្បាលក៏គ្មានដែរ។ ដូច្នេះហើយតាមទស្សនៈរបស់យើង គឺមិនត្រូវបោះបង់ចោលឡើយ ត្រូវមើលទៅប្រវត្តិ ថាតើយួនអាចលេបទឹកដីកម្ពុជាបានឬក៏អត់? គឺមិនអាចទេ។”

ភាពពាក់ព័ន្ធនៃចំណុចទាំងអស់នេះ គឺយើងចង់លើកឡើងថា នៅក្នុងខែមេសា ៧៨ គឺការទទួលស្គាល់របស់ ប៉ុល ពត ថាគ្មានជនជាតិវៀតណាមសោះ សូម្បីតែម្នាក់នៅលើទឹកដីកម្ពុជា។

[១៤:០២:០៩]

នៅក្នុងសុន្ទរកថាដដែលនេះដែរ ប៉ុល ពត បានបន្តទៀត គឺនៅត្រង់ភាសាអង់គ្លេសមានលេខ 00519838 ដល់39, ខ្មែរមានលេខ 00064720 និងបារាំងមានលេខ 00520351។ ហើយនេះគឺជាបញ្ហាដែលនិយាយអំពីគោលការណ៍ កម្ពុជាសម្លាប់ជនជាតិវៀតណាម៣០នាក់។ ហើយខ្ញុំសូមដកស្រង់៖ “បក្សបានសម្រេចថា បន្តវាយប្រហាររហូតដល់ពួកគេទទួលស្គាល់ព្រំដែនសមុទ្រ និងព្រំដែនអាកាស។ យើងត្រូវវាយបន្ត គឺខ្មែរម្នាក់វាយយួនម្នាក់ ដើម្បីឲ្យពួកគេទទួលស្គាល់ ទទួលស្គាល់ទាំងទៅលើឯកសារ ទទួលស្គាល់ទាំងទៅលើឆាកអន្តរជាតិ ហើយមិនហ៊ានចូលមកកាន់ព្រំដែនយើងបាន។”

ហើយសុន្ទរកថាបាននិយាយបន្តទៅទៀត អំពីប្រជាជនវៀតណាម៥០លាននាក់ ចំណែកខ្មែរមានត្រឹមតែ៨លាននាក់។ ហើយគេបាននិយាយ ថាតើទាហានខ្មែរហ្នឹងត្រូវធ្វើយ៉ាងណា ដើម្បីយកឈ្នះលើទាហានវៀតណាម។

ខ្ញុំមិនអាននោះទេ ប៉ុន្តែខ្ញុំចង់ឲ្យលោក លោកស្រីចៅក្រម ពិនិត្យមើលទៅលើឯកសារនេះ ហើយគោលជំហររបស់ព្រះរាជអាជ្ញា គឺថាចំនួននៃប្រជាជននេះ គឺគិតទាំងចំនួនស៊ីវិល ទាំងចំនួនទាហានផងដែរ បើតាមអ្វីដែល ប៉ុល ពត និយាយ។

យើងសូមបញ្ជាក់ថា នេះជាចំណុចដែលមានភាពពាក់ព័ន្ធ ដែលថាសុន្ទរកថាបែបនេះ ជំរុញឲ្យមានបរិយាកាសមួយដែលមានការស្អប់ខ្ពើមចំពោះជនជាតិវៀតណាម ពីសំណាក់កងទ័ព ក៏ដូចជាជនស៊ីវិល និងអាជ្ញាធររបស់កម្ពុជា។ ហើយការណ៍នេះ ជួយបង្កើតជាបរិយាកាសមួយដែលធ្វើឲ្យជនស៊ីវិលវៀតណាមត្រូវបានគេសម្លាប់ ក៏ដូចជាទាហានវៀតណាមត្រូវសម្លាប់ផងដែរនៅពេលដែលគេចាប់ខ្លួន ដោយមិនទទួលបាននូវការការពារណាមួយ ដូចដែលមានចែងក្នុងអនុសញ្ញាទីក្រុងហ្សឺណែវ

នោះឡើយ។

[១៤:០៤:៣៦]

ឥឡូវនេះខ្ញុំសូមបន្តទៅឯកសារ E3/833 នេះគឺជាសៀវភៅកំណត់ត្រារបស់ ចាន់ គឺអង់គ្លេសមានលេខ 00184607, ខ្មែរមានលេខ 00077894 ប៉ុន្តែមិនមានភាសាបារាំងនោះឡើយ។ "នៅថ្ងៃ០៦ មករា ៧៨ ចាន់ បានចូលទៅវាយយួន គោលដៅការវាយប្រហារយួន គឺនៅសមរភូមិកងពលទី៣ នៅខាងភូមិភាគបូព៌ា។ ហើយយើងមានជ័យជម្នះលើយួន បានវាយប្រហារចូលទឹកដីយួន ហើយសម្រេចគោលដៅមួយទល់នឹង៣០នាក់។" ដែលនេះគឺជាអ្វីដែលបានលើកឡើងដោយមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ហើយទាហានបានយកគោលការណ៍នេះទៅអនុវត្តជាក់ស្តែង គឺមួយទល់នឹង៣០។

ហើយខាងក្រោមបន្តិច គឺភាសាអង់គ្លេសមានលេខ 00184616, ខ្មែរមានលេខ 00077952 ប៉ុន្តែមិនមានភាសាបារាំងនោះឡើយ គឺបានបញ្ជាក់នៅថ្ងៃ២៥ កក្កដា ៧៨ អំពីការណែនាំឲ្យរកចាប់យួន។ "យើងរកឃើញថា ពួកវានៅគ្រប់ទីកន្លែង។ យើងដឹងថាមានយួនបង្កប់នៅខាងបូព៌ា នៅខាងពាយ័ព្យ នៅភ្នំពេញដែលយើងរកមិនទាន់ឃើញ ប៉ុន្តែពួកគេពិតជាមានមែន។ ហើយបន្តទៅទៀត យើងត្រូវកម្ទេចយួន ប៉ុន្តែវាមិនចាំបាច់ដែលត្រូវរកឃើញនោះឡើយ។ លក្ខខណ្ឌតម្រូវគឺរកឲ្យឃើញ ហើយនិងត្រូវតម្រូវ។"

ហើយឯកសារថ្ងៃ២៥ កក្កដា ៧៨នេះគឺថាចំណុចនេះបានបង្ហាញថា ជនជាតិវៀតណាមនៅក្នុងប្រទេសកម្ពុជា គឺមានការណែនាំឲ្យស្វែងរកជនជាតិវៀតណាម ហើយនិងកំណត់គោលដៅទៅលើជនជាតិវៀតណាមនោះ។

[១៤:០៧:០៩]

ហើយខ្ញុំបន្តទៅឯកសារ ១៧ ឧសភា ៧៨ E3/863 ជារបាយការណ៍របស់ រស់ ញឹម ផ្ញើជូនអង្គការ គឺនិយាយអំពីស្ថានភាពនៅព្រំដែនថៃ និងកង្វះម្ហូបអាហារជាដើម។ ហើយគាត់បានលើកឡើងអំពីបញ្ហាការរៀបការចម្រុះពូជសាសន៍ អង់គ្លេសមានលេខ 00321962, ខ្មែរមានលេខ 00076287 និងបារាំងមានលេខ 00623409។ ហើយគាត់បាននិយាយថា៖ "ការប្រជុំបានលើកឡើងពីបញ្ហាថាតើត្រូវសម្រេចយ៉ាងណាអំពីសមាសធាតុទាហានពីរបបមុន ហើយនិងយួនដែលមានប្តី ឬប្រពន្ធជាជនជាតិខ្មែរ និងកូនកាត់យួន។ ពាក់ព័ន្ធទៅនឹងបញ្ហានេះ កិច្ចប្រជុំចង់ស្នើសុំដល់អង្គការ៨៧០ ថាតើត្រូវធ្វើយ៉ាងម៉េច។ អង្គការសម្រេចយ៉ាងម៉េច? សូមផ្តល់ការណែនាំ។ និយាយជារួមទៅ ក្រុមទាំងអស់នេះបានភ័យ

បារម្ភអំពីស្ថានភាព ហើយព្រួយបារម្ភអំពីជោគវាសនារបស់ពួកគេ ប៉ុន្តែមិនមានសញ្ញាណាមួយបង្ហាញពីសកម្មភាពប្រឆាំងនោះឡើង។ ប្រសិនបើពួកគេធ្វើសកម្មភាពណាមួយគួរឲ្យសង្ស័យ យើងនឹងសម្រេចថាយកពួកគេចេញ។ ឥឡូវនេះខ្ញុំដឹងថាវាមិនពិបាកទេ ប៉ុន្តែសំខាន់បំផុតយើងត្រូវតែក្តោបពួកគេឲ្យបានជារៀងរហូត។ ប្រសិនបើគេបង្ហាញនូវការសង្ស័យណាមួយ យើងត្រូវតែគ្រប់គ្រងស្ថានភាពឲ្យបានភ្លាមៗតែម្តង។" នេះគឺជារបាយកាណ៍សង្ខេបរបស់ខ្ញុំ។

ឯកសារមួយនេះបានបង្ហាញថា ជនស៊ីវិលវៀតណាមគឺជាកម្មវត្ថុនៃការកំណត់គោលដៅ និងការរើសអើង ហើយអាចនឹងជួយបង្ហាញអំពីគោលនយោបាយនៃការកំណត់គោលដៅនេះបាន។

[១៤:០៩:១២]

លោក លោកស្រីចៅក្រម ឥឡូវនេះខ្ញុំសូមបន្តទៅរបាយការណ៍ខែមិថុនា ឆ្នាំ៧៨ គឺឯកសារ E3/1094 គឺបាន ឯកសារនេះបានបញ្ជាក់នៅត្រង់ភាសាអង់គ្លេស 00315374 ដល់75, ខ្មែរមានលេខ 00143604 និងបារាំងមានលេខ 00593530។ ខ្ញុំសូមដកស្រង់៖ "អំពីការចម្រាញ់រកសមាសធាតុយួនភ្នាក់ងារ សេ.អ៊ី.អា កម្ទេចជនជាតិយួន១០០នាក់ រួមបញ្ចូលទាំងមនុស្សធំ មនុស្សតូច មនុស្សពេញវ័យ និងកូនក្មេង។ កម្ទេចមនុស្ស៦០នាក់ដែលៗដែលមិនដែលជាភ្នាក់ងារ សេ.អ៊ី.អា ចក្រពត្តិអាមេរិក។"

ខ្ញុំសូមបញ្ជាក់ថា នេះគឺជាភ័ស្តុតាងបង្ហាញច្បាស់ថា មានការសម្លាប់យុទ្ធជនវៀតណាម ហើយ និងជនស៊ីវិលវៀតណាម។

ឥឡូវនេះខ្ញុំសូមបន្តទៅឯកសារថ្ងៃ០១ មករា -- ថ្ងៃ០២ មករា ៧៩ ឯកសារ E3/8404 ជារបាយការណ៍របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ អង់គ្លេសមានលេខ 00419728, ខ្មែរមានលេខ 00716183 និងបារាំងមានលេខ 00017542។ ខ្ញុំសូមដកស្រង់៖ "ក៏ប៉ុន្តែការតស៊ូរបស់ជនជាតិកម្ពុជា និងប្រជាជនកម្ពុជា ក្នុងការការពារឯករាជ្យភាព បូរណភាព និងបូរណភាពទឹកដីរបស់ប្រទេស និងការពារគោលការណ៍មិនចូលបក្សសម្ព័ន្ធ សន្តិភាព និងស្ថិរភាពនៅក្នុងអាស៊ីអាគ្នេយ៍ នៅក្នុងអាស៊ី ហើយនៅក្នុងពិភពលោក គឺនឹងប្រាកដជាឈ្នះលើវៀតណាម។ ពួកវាតទីនិយមអន្តរជាតិសូវៀត ហើយ និងក្រុមស្រេកឃ្លានសង្គ្រាម គឺជាឧក្រិដ្ឋជន ពីព្រោះថាការវាយប្រហាររបស់យើង មានភាពយុត្តិធម៌ ពីព្រោះថាយើងអនុវត្តដើម្បីការពារ ហើយយើងធ្វើឡើងដើម្បីប្រយោជន៍ប្រជាជនកម្ពុជា ប្រឆាំងប្រជាជនវៀតណាម។ ហើយក្នុងពេលឥឡូវនេះ យើងកំពុងតែមានមិត្តកាន់តែច្រើនឡើងៗ ទាំងនៅជិតនៅឆ្ងាយ ដែលបានជួយ ហើយនិងការគាំទ្រដល់យើង។"

ហើយចំណុចនេះបានបង្ហាញថា ជនជាតិវៀតណាមត្រូវបានគេកំណត់ជាគោលដៅ ដោយសារតែពូជសាសន៍ មិនមែនដោយសារតែពួកគេជាយុទ្ធជននោះឡើយ។

[១៤:១២:០៣]

លោក លោកស្រីចៅក្រម ឥឡូវនេះខ្ញុំចង់និយាយដោយសង្ខេបបន្តិច អំពីរបាយការណ៍អ្នកជំនាញ។ របាយការណ៍របស់ អេលីហ្សាប៊េត ដូ គឺE3/4541។ នេះគឺជាការសិក្សាអំពីការប្រព្រឹត្តចំពោះជនជាតិវៀតណាមនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពីការទស្សនៈប្រៀបធៀប ហើយស្ត្រីមួយនេះគាត់ធ្វើការនៅសាកលវិទ្យាល័យ។ ហើយគោលដៅនៃការសិក្សានេះ គឺធៀបជនជាតិវៀតណាម និងជនជាតិខ្មែរនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ហើយគាត់បានប្រៀបធៀបអំពីការប្រព្រឹត្តចំពោះខ្មែរ និងប្រជាជនវៀតណាម។ ទី១ គឺការហាមឃាត់ការអប់រំ ការរៀនសូត្រ និងការសម្រេច ហើយនិងការបាត់ខ្លួន ក៏ដូចជាការកម្ទេច។ ការសិក្សាធ្វើឡើងរយៈពេលពីរឆ្នាំកន្លះ ដោយចុះផ្ទាល់ដល់មូលដ្ឋាន។ ពេលខ្លះធ្វើការស្រាវជ្រាវនៅនៅកម្ពុជាផងដែរ។ ហើយប្រភពព័ត៌មានដែលគាត់ប្រើ គឺឯកសាររបស់បក្សកុម្មុយនីស្តកម្ពុជា ហើយជារបាយការណ៍របស់អ្នកស្រាវជ្រាវ ក៏ដូចជាកិច្ចសម្ភាសន៍ប្រជាជនខ្មែរ វៀតណាម និងចិន នៅទូទាំងប្រទេសៗកម្ពុជា។ ហើយគាត់បានបញ្ជាក់ថា ភាគច្រើនគឺមកពីព្រៃវែង មកពីស្វាយ-រៀង កំពង់ឆ្នាំង និងខេត្តកណ្តាលផងដែរ។

[១៤:១៣:៤១]

ឥឡូវនេះខ្ញុំចង់ឲ្យលោក លោកស្រីពិនិត្យមើលទៅលើរបាយការណ៍មួយនេះ ប៉ុន្តែខ្ញុំក៏ចង់និយាយយោងផងដែរទៅលើផ្នែកមួយពាក់ព័ន្ធទៅនឹងការប្រព្រឹត្តចំពោះជនជាតិវៀតណាមធៀបទៅនឹងជនជាតិខ្មែរ ក្នុងការបាត់ខ្លួន និងការកម្ទេចក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ នៅលេខ 00548856 ដល់ 59 ជាភាសាអង់គ្លេស, ខ្មែរមានលេខ 00768961 ដល់ 65 និងបារាំងមានលេខ 00751016 ដល់ 20។ គាត់បានបញ្ជាក់ថា៖ “គឺនិយាយអំពីឆ្នាំ៧៧ ឬក៏ពាក់កណ្តាលរបបកម្ពុជាប្រជាធិបតេយ្យ ដែលជាចំណុចប្រែប្រួលក្នុងការប្រព្រឹត្តចំពោះជនជាតិវៀតណាម។ មុនឆ្នាំ៧៧ ជនជាតិវៀតណាមត្រូវបានគេប្រព្រឹត្តដូចគ្នា ឬក៏ប្រហែលគ្នានឹងប្រជាជនដទៃ។ ប៉ុន្តែនៅពេលក្រោយមក គឺមានការប្រែប្រួលនៅក្នុងចន្លោះឆ្នាំ ៧៦ ដល់៧៧ គឺថាខ្មែរក្រហមចាប់ផ្តើមប្រមូលផ្តុំវៀតណាមនៅតាមភូមិនានា។ ហើយអ្នកបានផ្តល់ព័ត៌មាន បាននិយាយថា កម្មាភិបាលបានយកជនជាតិវៀតណាមទៅ ហើយគេប្រើប្រាស់ហេតុផលផ្សេងៗគ្នាជាច្រើន ឧទាហរណ៍ដូចជារៀនសូត្រ ផ្លាស់ទីលំនៅ ធ្វើការ ឬក៏ចាប់ខ្លួន។ ប្រជាជនត្រូវបាន

គេបញ្ជូនចេញពីភូមិតាមរទេះគោ ហើយមិនដែលឃើញត្រឡប់មកវិញទេ។ អ្នកផ្ដល់ព័ត៌មានបាននិយាយអំពីការបាត់ខ្លួនវៀតណាមនៅក្នុងភូមិរបស់ពួកគេ ហើយពួកគេនិយាយថា ត្រឹមចុងឆ្នាំ៧៧ ឬក៏ ៧៨ ជនជាតិវៀតណាមសឹងតែទាំងអស់បានបាត់ខ្លួន។ មានប្រជាជនវៀតណាមមួយចំនួនតូចដែលនៅរស់រានមានជីវិត ប៉ុន្តែពួកគេជាករណីលើកលែងប៉ុណ្ណោះ មិនមែនជាករណីជាក់ស្ដែងនោះឡើយ។ តាមពិតទៅ ភាគច្រើនលើសលុបបានបញ្ជាក់មតិផ្ទាល់ខ្លួនថា ប្រសិនបើខ្មែរក្រហមគិតថានរណាម្នាក់ជាវៀតណាម គេនោះនឹងត្រូវបានបាត់ខ្លួន ឬក៏សម្លាប់ចោលដោយគ្មានសួរនាំ។ ក្នុងចំណោមអ្នកផ្ដល់ចម្លើយប្រហែលជា ២៧នាក់ហ្នឹង គឺបានបញ្ជាក់ថា វៀតណាមនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យគឺគាត់ឆ្លើយថា៩០ភាគរយ ៩០ភាគរយ គាត់ឆ្លើយថាបាទ។ ហើយគេសួរថា ប្រសិនបើថា តើមានអ្នកនៅរស់ទេ គឺឆ្លើយច្រើនគ្នាថា អ្នកខ្លះគាត់អាចលាក់អត្តសញ្ញាណរបស់ពួកគាត់បាន អ្នកខ្លះត្រូវបានការពារដោយមេភូមិ ឬក៏អ្នកចាត់ចែងនៅក្នុងខ្មែរក្រហម ហើយអ្នកខ្លះទៀតនិយាយថា ខ្មែរក្រហមមិនខ្វល់ថាតើគាត់ជាជនជាតិវៀតណាម ឬក៏អត់ ព្រោះពួកគាត់ជាប្រជាជនមូលដ្ឋាន ហើយអាចធ្វើការបាន។

[១៤:១៦:៣៨]

ដូច្នេះហាក់ដូចជាថា វៀតណាមនៅបូព៌ាធ្វើការសម្លាប់ ហើយនិងធ្វើការបំបាត់ខ្លួនទាំងខ្មែរ ទាំងវៀតណាម។ ហើយវាមានទាំងអ្នកស្លាប់ មាននៅរស់រានមានជីវិត។ ចំពោះប្រជាជនថ្មីខ្មែរ និងប្រជាជនវៀតណាម ពួកគេគឺទទួលរងគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរដោយសារការប្រព្រឹត្តរបស់ខ្មែរក្រហម។

មានចំណុចមួយចំនួនដែលថា វៀតណាមបានទទួលនូវបទពិសោធន៍ខុសពីជនជាតិខ្មែរ។ ទី១ គឺថា អ្នកជូនដំណឹងពីពោធិ៍ចិន្ដាំបាននិយាយ ថាតើខ្មែរក្រហមធ្វើការប្រមូលផ្ដុំគ្រួសារវៀតណាមដោយរបៀបណា ដែលទាំងអស់នោះរួមមានទាំងខ្មែរ និងគ្រួសារជាវៀតណាម។ គេនិយាយថា វៀតណាមប្រមូលផ្ដុំម្ដាយឪពុកជាវៀតណាម ប្រសិនបើម្ដាយជាវៀតណាម គឺថាគេសម្លាប់ទាំងអស់។ អ្នកផ្ដល់ព័ត៌មានបាននិយាយថា ខ្មែរក្រហមបានប្រមូលគ្រួសារវៀតណាមទាំងអស់នៅពោធិ៍ចិន្ដាំ ហើយកម្មាភិបាលខ្មែរក្រហមមិនបំបែកគ្នានោះឡើយនៅពេលដែលគេប្រមូលប្រជាជនចេញពីភូមិដទៃទៀត។ អ្នកផ្ដល់ព័ត៌មាននៅភូមិដទៃទៀតបាននិយាយថា ខ្មែរក្រហមនៅក្នុងភូមិរបស់ពួកគេយកតែឪពុកម្ដាយជាវៀតណាម ប៉ុន្តែមិនយកកូននោះឡើយ។ ហើយមានអ្នកខ្លះនិយាយថា កម្មាភិបាលខ្មែរក្រហមយកគ្រួសារទាំងអស់តែម្ដង ប្រសិនបើគេរកឃើញថា សូម្បីតែមានតែម្នាក់ជាវៀតណាម ក៏គេយកទាំងអស់ដែរ។

[១៤:១៨:២១]

ទម្រង់នេះត្រូវបានគេសង្កេតឃើញ ហើយប៉ុន្តែទម្រង់នេះមិនដែលត្រូវបានប្រកាសជាសាធារណៈថាជាគោលនយោបាយរបស់ខ្មែរក្រហមនោះឡើយ។ ទម្រង់ដែលគេសង្កេតឃើញនៅក្នុងឃុំពោធិ៍ចិន្តាំ គឺមានភាពខុសគ្នារវាងខ្មែរ ហើយនិងវៀតណាម ដែលថាពួកគេទទួលយកបទពិសោធន៍ខុសៗគ្នា។ មានភ័ស្តុតាងបង្ហាញថា មានការទទួលរងខុសៗគ្នារវាងវៀតណាម និងខ្មែរ។

ទាក់ទងទៅនឹងការសម្លាប់ជនជាតិវៀតណាម។ ជនជាវៀតណាមនៅក្នុងកម្ពុជាប្រជាធិបតេយ្យមានមធ្យោបាយតិចតួច ដើម្បីគេចចេញពីការសម្លាប់។ ដូចដែលយើងបានបញ្ជាក់នៅក្នុងចំណុចទាំងបួនហ្នឹងគឺថា ជនជាតិវៀតណាម គឺមានភាពខុសគ្នាផ្នែករូបរាងកាយ ខុសពីជនជាតិខ្មែរ។ ឧទាហរណ៍ដូចជាស្បែកសជាង តុងនិយាយខុសគ្នាជាដើម។ ភាពខុសគ្នាបែបនេះគឺពិបាកក្នុងការលាក់ ហើយវាមិនអាចបង្ហាញបាន មិនងាយក្នុងការលាក់លៀមបាន។ ជនជាតិវៀតណាមគឺមានការខុសគ្នា ងាយនឹងការកំណត់ដោយខ្មែរក្រហម ហើយក៏ងាយរងនឹងការកម្ទេចចោលនោះដែរ។ នៅពេលដែលខ្មែរក្រហមវែកមុខរកជនជាតិវៀតណាម ក៏ដូចជា យុទ្ធនាការប្រឆាំងនឹងប្រជាជនថ្មី ខ្មែរក្រហមបានប្រកាសថា អ្នកដែលមាន -- គឺថាខ្លួនមានបំណងសម្លាប់អ្នកណាដែលជាប់ពាក់ព័ន្ធជាមួយនឹងវៀតណាម។ ហើយដើម្បីលុបបំបាត់ដានពាក់ព័ន្ធទៅនឹងជនជាតិវៀតណាមតែម្តង។ អ្នកដែលផ្តល់កិច្ចសម្ភាសន៍ក៏បានឆ្លើយផងដែរ ថាប្រសិនណាជាខ្មែរក្រហមរកឃើញថាអ្នកណាម្នាក់ជាជនជាតិវៀតណាម អ្នកនោះនឹងត្រូវយកទៅសម្លាប់ចោលហើយ។ ឧទាហរណ៍នេះ បញ្ជាក់ឲ្យឃើញថា តើជនជាតិខ្មែរនៅក្នុងប្រទេសកម្ពុជា ក៏រងការគំរាមកំហែងទៅដល់ជីវភាពរស់នៅ ការរស់នៅ ដោយសារតែគោលនយោបាយមកលើពួកគេមិនមែនត្រឹមតែវត្តមានដោយផ្ទាល់ខ្លួនតែប៉ុណ្ណោះទេ។ របបនេះ គឺមិនផ្តល់ជម្រើសណាមួយឲ្យជនជាតិវៀតណាម ដើម្បីឲ្យបង្ហាញស្តែងនូវអត្តសញ្ញាណរបស់ខ្លួននោះទេ។ ខ្មែរក្រហមនិយាយថា បើសិនណាអ្នកណាម្នាក់ជាជនជាតិវៀតណាម អ្នកនោះពិតជាមិនរស់ទេ នៅពេលណាគេរកឃើញ ចប់ហើយ។

[១៤:២១:០៧]

ចុងក្រោយ ខ្មែរក្រហមក៏បានសម្លាប់រង្គាល ហើយក៏មានផលប៉ះពាល់ទៅដល់ជនជាតិខ្មែរ ក៏ដូចជនជាតិវៀតណាម បើទោះណាជាមានជនជាតិវៀតណាមតែពីរបីនាក់ ដែលរស់រានមានជីវិតក៏ដោយ ក៏ជនជាតិវៀតណាមភាគច្រើន គឺបានស្លាប់នៅក្នុងរបបខ្មែរក្រហម។ អ្នកទស្សនវិទូក៏បានរកឃើញថា ជនជាតិវៀតណាមភាគច្រើនត្រូវបានស្លាប់។ ទោះបីជាជនជាតិខ្មែរក៏ដោយ ក៏ប្រឈមនឹងការសម្លាប់

រង្គាល ហើយមានការប៉ះពាល់យ៉ាងខ្លាំងទៅដល់សមាមាត្រភាពនៃប្រជាជនរបស់ខ្លួន។ នេះរបៀបយុទ្ធនាការដែលខ្មែរក្រហមបានធ្វើឡើងដើម្បីប្រឆាំងជាមួយជនជាតិវៀតណាម ហើយបានបណ្តាលឲ្យមានការស្លាប់ប្រជាជនយ៉ាងច្រើន ជាពិសេសករណីនេះវៀតណាម។ សូមដកស្រង់៖ បើប្រៀបធៀបទៅនឹងក្រុមដទៃទៀត ជនជាតិវៀតណាមស្ទើរតែទាំងអស់ត្រូវបានកម្ទេចចោល គឺថា១០០ភាគរយដែលជាជនជាតិវៀតណាម ដែលមានប្រហែលជា១.០០០ ទៅ ១០០.០០០នាក់ គឺបានស្លាប់នៅក្នុងឆ្នាំ៧៥ដល់៧៩។ ផ្ទុយទៅវិញ គឺថាចាម ឡាវ វៀតណាម គឺបាត់ប្រហែលជា៣៩ភាគរយនៃចំនួនប្រជាពលរដ្ឋទាំងអស់។ នេះបើធ្វើការប្រៀបធៀប។ បន្ថែមពីលើនេះទៅទៀត កម្ពុជាប្រជាធិបតេយ្យក៏បានធ្វើការយុទ្ធនាការប្រឆាំងជាមួយជនជាតិថៃ ឡាវ ចាមផងដែរ។ ឯកសារជាច្រើននិយាយអំពីទំនាក់ទំនងកម្ពុជាវៀតណាមបានធ្លាក់ចុះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យចំនួនប្រជាពលរដ្ឋបាត់យ៉ាងច្រើន។ ដោយហេតុនេះ ប្រជាជនវៀតណាម និងប្រជាជនកម្ពុជា ប្រឈមមុខនឹងការប្រព្រឹត្តខុសៗគ្នា ពាក់ព័ន្ធទៅនឹងការសម្លាប់រង្គាល និងការបាត់ខ្លួន។”

[១៤:២៣:១៥]

ខ្ញុំសូមចូលទៅដល់សេចក្តីសន្និដ្ឋានរបស់អ្នកនិពន្ធ គឺអង់គ្លេស 00548861, ខ្មែរ 00768966 ដល់69, បារាំង 00751023 ដល់ 24 គឺនិយាយអំពីអ្នកដែលមានឯកសណ្ឋាន គឺថាត្រូវបានគេរកឃើញ ហើយអ្នកណារកឃើញជាជនជាតិវៀតណាម ហើយអ្នកប្រជាជនថ្មីដែល -- ហើយវៀតណាម នោះ ក៏ធ្វើយុទ្ធនាការដើម្បីបណ្តេញកម្ពុជាចេញពីប្រទេសកម្ពុជាផងដែរ។ ហើយទង្វើបែបនេះ មិនធ្វើទៅលើប្រជាជនខ្មែរនៅពេលនោះ។ ហើយសរុបមក គឺការប្រព្រឹត្តមកលើក្រុមទាំងពីរ គឺមានលក្ខណៈខុសគ្នា។ នេះប្រៀបធៀបទៅនឹងចំនួនប្រជាពលរដ្ឋមួយក្រុមៗនេះ។

ទាក់ទងទៅនឹងកត្តាជនជាតិ និងកត្តានយោបាយនេះ នៅពេលដែលខ្មែរក្រហមឡើងកាន់អំណាចភ្លាម ខ្មែរក្រហមបានប្រកាសភ្លាមៗថាមានតែជនជាតិខ្មែរមួយទេ ត្រូវមានតែជនជាតិខ្មែរមួយទេ ហើយក៏ចាប់ផ្តើមស្វែងរកអ្នកដែលមានសញ្ជាតិដទៃទៀត។ ហើយអ្នកដែលផ្តល់ការសម្ភាសហ្នឹង ចងចាំថាមេដឹកនាំខ្មែរក្រហមនៅក្នុងភូមិនីមួយៗ គឺបានប្រជុំ ហើយបានអំពាវនាវ។ ហើយក៏បាននិយាយដដែលៗថា វៀតណាមនេះគឺជាខ្មាំងប្រវត្តិសាស្ត្រ ដូចជាលើកឡើងអំពីបញ្ហាព្រឹត្តិការណ៍តែអុង។ ហើយអ្នកផ្តល់បទសម្ភាសន៍ហ្នឹង អ្នកណាដែលធ្វើការជំទាស់ ហើយឲ្យអ្នកទាំងអស់គ្នាប្រើពាក្យ “យួន” មិនឲ្យបាច់ប្រើពាក្យ“វៀតណាម”ទេ។ មធ្យោបាយដែលបានប្រើប្រាស់វិធីបែបនេះនៅក្នុងកម្ពុជាប្រជាធិបតេយ្យ

គឺមានភ័ស្តុតាងនៅក្នុងឯកសារខ្មៅ ដែលបានប្រើប្រាស់ពាក្យនេះ សំដៅយួននេះ សំដៅទៅលើជនជាតិវៀតណាម។

[១៤:២៥:៣៥]

កំហឹងបែបនេះផ្តល់នូវភ័ស្តុតាងដែលថាខ្មែរក្រហម គឺថាមានការកំណត់យ៉ាងច្បាស់ក្នុងការបោសសម្អាតជាតិសាសន៍ ហើយនៅក្នុងការបង្កឲ្យមានប្រទូសរ៉ាយជាមួយជនជាតិភាគតិច។ នៅក្នុងការពន្យល់ទៅលើគោលនយោបាយ ក៏ដូចការអនុវត្តដែលមិនឲ្យនិយាយភាសាចាម មិនឲ្យប្រើប្រាស់ -- ភាសាវៀតណាមនិងវប្បធម៌វៀតណាម ហើយបញ្ហានេះក៏ឈានទៅដល់ការកម្ទេចវៀតណាម។ ហើយខ្មែរក្រហមខ្លះ គឺថាបានធ្វើការសម្លាប់ជនជាតិវៀតណាមទ្រង់ទ្រាយធំតែម្តង ដោយមិនផ្តល់សញ្ញាណណាដែលជាការបង្កប្រទូសរ៉ាយឲ្យដឹងជាមុននោះឡើយ។ ហើយក៏វាហាក់បីដូចផងដែរថា របបនេះបានប្រើប្រាស់ឥទ្ធពលនយោបាយដទៃទៀត ហើយក៏ដូចជាប្រើប្រាស់សង្គ្រាមនៅតាមព្រំដែន ដើម្បីបំបែកបំបាក់ទំនាក់ទំនងខាងផ្នែកនយោបាយ។ ជាពិសេសការបណ្តេញចេញ ក៏ដូចជាការអនុវត្តគោលនយោ-បាយនៅក្នុងបរិបទ និយាយអំពីសង្គ្រាមក្នុងតំបន់ គឺសន្តិសុខក្លាយទៅជាអាទិភាពបំផុតសម្រាប់របបកម្ពុជាប្រជាធិបតេយ្យ។ នៅក្នុងឯកសារខ្មៅខ្មែរក្រហមបានធ្វើការស្រាវជ្រាវរកជនជាតិវៀតណាមនៅក្នុងប្រទេស ដោយសារថា៖ "ជនជាតិវៀតណាមដែលជ្រៀតចូលមកក្នុងប្រទេសកម្ពុជា ហើយកំពុងរស់លួចលាក់រស់នៅក្នុងចំណោមប្រជាជនរបស់យើង។" អ្នកផ្តល់កិច្ចសម្ភាសន៍ក៏បានឆ្លើយ ហើយនិងផ្តល់កំណត់ត្រាតាមកាលប្បវត្តិថា ទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរកាន់តែអាក្រក់ទៅៗ ហើយការកម្ទេចជនជាតិវៀតណាមដោយពួកខ្មែរក្រហមនេះ ក៏បានឈានកាន់តែខ្លាំងឡើង សាហាវព្រៃផ្សៃឡើង និងស្តែងឡើងៗ និងទូលំទូលាយ។

[១៤:២៧:៣៣]

នៅក្នុងឆ្នាំមួយពាន់ប្រាំបួនរយ -- អ្នកផ្តល់ព័ត៌មានបានបញ្ជាក់ឲ្យឃើញថា នៅក្នុងឆ្នាំ៧៧ និងមុំឆ្នាំ៧៧ សង្គ្រាមព្រំដែនបានចាប់ផ្តើម ហើយខ្មែរក្រហមហ្នឹងបានបង្កើនសុន្ទរកថា ធ្វើឲ្យស្អប់ទៅដល់ជនជាតិវៀតណាម ក៏កាន់តែខ្លាំងឡើងៗ។ ហើយនៅក្នុងឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ ក៏មានសុន្ទរកថាញុះញង់ឲ្យមានអំពើហិង្សាប្រឆាំងទៅនឹងជនជាតិវៀតណាមដើម្បីការពារទឹកដីកម្ពុជា។

អ្នកនិពន្ធក៏បានរកឃើញផងដែរថា ជនជាតិវៀតណាម ជាពិសេសនៅភូមិភាគបូព៌ានៃកម្ពុជាប្រជាធិបតេយ្យរងការប្រព្រឹត្តដោយមិនរើសមុខ ដើម្បីវែកមុខរកឲ្យឃើញតែម្នាក់ក្តី ហើយនិងការធ្វើ

ការអនុវត្តទៅលើពួកគេខុសពីអ្នកដទៃទៀត។ នេះគឺជាសេចក្តីសន្និដ្ឋាន ពាក់ព័ន្ធទៅនឹងអ្នកដែលផ្តល់ការសម្ភាសចំនួន៤៨នាក់ជាមួយ ប៊ែន ឃៀរនិន នៅក្នុងឆ្នាំពីរពាន់--។

ហើយមួយទៀតគឺឯកសារ E3/2413 នេះគឺជារបាយការណ៍ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៩ ដោយឌុកទ័រ តាបូ។ ឌុកទ័រ -- យើងដឹងហើយថា សហចៅក្រមស៊ើបអង្កេតបានឲ្យបណ្ឌិត តាបូ នេះគឺថាធ្វើការស្រាវជ្រាវអំពីចំនួនប្រជាសាស្ត្រនៅក្នុងប្រទេសកម្ពុជា ដោយយោងទៅលើព័ត៌មានទាំងឡាយណាដែលអាចយកមកប្រើប្រាស់បាននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ គាត់បានបង្ហាញអំពីចំនួនមនុស្សស្លាប់ ហើយជាពិសេសគឺផ្តោតទៅលើជនជាតិវៀតណាម ចន្លោះពីឆ្នាំ១៩៧៥ ទៅដល់ ១៩៧៨។ ខ្ញុំគិតថា ៧៨នេះគួរតែជាឆ្នាំ១៩៧៩វិញ។ ERN ជាភាសាអង់គ្លេស 00385310 ដល់ 11, ខ្មែរ00499517 ដល់ 18, បារាំង 00405354។ គាត់បានលើកឡើងពាក់ព័ន្ធទៅនឹងជនជាតិវៀតណាម។ ចំនួនជនជាតិវៀតណាមនៅក្នុងប្រទេសកម្ពុជា ត្រូវបានគេរាយការណ៍ស៊ីសង្វាក់គ្នាណាស់ មានចំនួន៤០០.០០០នាក់ នៅមុំឆ្នាំ១៩៧០។ តាមរយៈទូរលេខនេះ ក្នុងចំណោម៤០០.០០០នាក់ហ្នឹង គឺ២០០.០០០នាក់ ត្រូវបានរបប លន់ នល់ បណ្តេញចេញនៅក្នុងឆ្នាំ១៩៧០។ ឯ១៥០.០០០ ទៅ២០០.០០០ ដែលនៅសល់ក្នុងប្រទេសកម្ពុជា ក្រោយពីខ្មែរក្រហមបានកាន់កាប់អំណាចនៅខែមេសា ១៩៧៥។

[១៤:៣០:៥៥]

ជនជាតិវៀតណាមជាច្រើន ត្រូវបានរបប លន់ នល់ សម្លាប់ចោល ហើយៗបន្ទាប់ពីរបបខ្មែរក្រហមមក កម្រមានជនជាតិវៀតណាមអាចរស់រានមានជីវិតណាស់ ក្រោយខែមករា ១៩៧៩។ ហើយនៅខែមេសា ១៩៧៥ហ្នឹងគឺនេះ គឺធ្វើការប៉ាន់ប្រមាណថា មានប្រហែល២០.០០០នាក់ ប៉ុន្តែក៏ត្រូវបានសម្លាប់ស្ទើរតែទាំងអស់ ចន្លោះពីខែមេសា ៧៥ ដល់ខែមករា ៧៩។

ខ្ញុំសូមចូលទៅសៀវភៅរបស់លោក ប៊ែន ឃៀរនិន គឺឯកសារ E3/15 -- ២៧៥ ទៅដល់ឆ្នាំ ១៩៧៩ ERN ជាភាសាអង់គ្លេស 00--

**អ្នកបកប្រែ៖**

លោកប្រធាន សូមការអនុញ្ញាត សូមឲ្យលោកសហព្រះរាជអាជ្ញាបន្ថយល្បឿនតិច លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

លោកៗ វីល្មៀម ស្មីត សូមបន្ថយល្បឿនឲ្យយឺតបន្តិច ហើយសូមអាននូវលេខ ERN ឯកសារ

ចុងក្រោយសាជាថ្មីម្តងទៀត ព្រោះបកប្រែបកអត់ទាន់ទេ។

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ ERN ជាភាសាអង់គ្លេស 00786950, ខ្មែរ 00637821, បារាំង 00639073-4។ នៅត្រង់ផ្នែកនេះចុះមកក្រោម គឺពីរទំព័រចុះមកក្រោមទៀត ដែលលោក ប៉ែន យៀរ និន បានធ្វើការសរុបការស្រាវជ្រាវរបស់គាត់ ពាក់ព័ន្ធទៅនឹងជនជាតិវៀតណាម ហើយគាត់បានលើកឡើងថា មានជនជាតិវៀតណាម១៥០ពាន់នាក់ដែលបានចាកចេញពីប្រទេសកម្ពុជា ឬក៏ខ្មែរក្រហមបណ្តេញនៅខែកញ្ញា ១៩៧៥។

[១៤:៣៣:២០]

ខ្ញុំមិនចូលនិយាយលម្អិតទេ គឺនេះនិយាយអំពីពាក់កណ្តាលឆ្នាំ១៩៧៦។ ហើយក្រោយមក ក៏និយាយអំឡុងពេលឆ្នាំ៧៧ នៅភូមិភាគបស្ចិម និងឆ្នាំ៧៧ នៅតំបន់កោះ ហើយឆ្នាំ១៩៧៧ នៅភូមិភាគបូព៌ា ក៏ដូចជានៅភូមិភាគពាយ័ព្យ... 

តាមរយៈភ័ស្តុតាងរបស់គាត់ និងលេខយោងជើងទំព័រ ទាក់ទងទៅនឹងកិច្ចសម្ភាសន៍របស់អ្នកនិពន្ធ ជាមួយកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា គាត់បានសន្និដ្ឋានថា មានយុទ្ធនាការជាប្រព័ន្ធប្រឆាំងទៅនឹងជនជាតិវៀតណាម គឺថានៅទូទាំងប្រទេសតែម្តង។ មិនមែនតែនៅភូមិភាគបូព៌ា មិនមែននៅតែស្វាយរៀង ឬក៏ព្រៃវែងទេ គឺនៅទូទាំងប្រទេសតែម្តង ហើយជាពិសេស នៅក្នុងឆ្នាំ១៩៧៧នេះតែម្តង។

ខ្ញុំសូមចូលទៅឯកសារចុងក្រោយ នេះចេញពីសៀវភៅរបស់ គឺឯក -- នៅខាងក្រោយការសម្លាប់ គឺឯកសារ E3/4202 ជាសៀវភៅដែលសរសេរឡើង ថេត សម្បត្តិ ដែលគាត់សរសេររៀបរាប់អំពីជីវប្រវត្តិរបស់ នួន ជា ហើយមានការដកស្រង់មួយគឺត្រង់ ERN 00757520 ជាភាសាអង់គ្លេស, ជាភាសាបារាំង 00849413, ខ្មែរ 00858306។ ហើយគាត់បានលើកឡើង សូមដកស្រង់៖ “នួន ជា បាននិយាយថា យើងមិនសម្លាប់អ្នកក្បត់នៅក្នុងជួរបក្សរបស់យើងទេ បើសិន ហើយបើសិនយើងមិនកម្ទេចខ្មាំងចោលទេ ក៏មិនបានកម្ពុជាដល់សព្វថ្ងៃនេះដែរ។ នៅពេលដែលយើងក្រឡេកមើលទៅលើចលនាតស៊ូដែលយើងប្រយុទ្ធប្រឆាំងជាមួយនឹងខ្មាំង គឺយើងមានអាវុធតូចធំ ប៉ុន្តែខ្មាំងផ្ទៃក្នុងគឺកាន់តែអាក្រក់មែនទែន ហើយនិងមានគ្រោះថ្នាក់សម្រាប់បក្ស ហើយនិងប្រទេសជាតិ។ ប៉ុន្តែយើងមិនបានសម្លាប់ប្រជាជនស្លូតត្រង់ទេ”។ បញ្ចប់ការដកស្រង់។ ហើយនៅក្នុងខ្សែវីដេអូដែលនិយាយថា “សត្រូវរបស់ប្រជាជនឯង” គឺនិយាយអំពីការសម្លាប់ខ្មាំង។

[១៤:៣៦:២២]

យើងខ្ញុំសូមលើកឡើងថា តាមរយៈឯកសារចេញពីឯកសារគោលនយោបាយពីមន្ទីរប-៧០ និយាយអំពីនៅក្នុងទស្សនាវដ្ដីទង់បដិវត្ត។ អ្នកទាំងអស់គ្នាបានគូររូបជនជាតិវៀតណាម គឺថាមិនមែនតែកងទ័ពទេ ទាំងជនស៊ីវិល គឺថាគូររូបជនជាតិវៀតណាមហើយ បង្ហាញថាអ្នកទាំងអស់នេះគឺខ្មាំងតែម្ដងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ហើយតាមរយៈការយល់ឃើញរបស់ នួន ជា យើងខ្ញុំសូមបញ្ជាក់ថា កិច្ចការបែបនេះគំរូរូបភាពបែបនេះ វាគាំទ្រទៅដល់ទ្រឹស្ដីនេះហើយ ដែលថាជនជាតិវៀតណាមគឺត្រូវបានគេកំណត់ជាគោលដៅ ថាជាខ្មាំងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

បទបង្ហាញរបស់ខ្ញុំចប់តែប៉ុណ្ណេះហើយ លោកប្រធានសូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ឥឡូវនេះក៏ដល់ពេលសមស្របសម្រាកដែរហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី ខ្វះប្រាំនាទីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៧ នាទី ដល់ម៉ោង ១៤:៥៨ នាទី)*

[១៤:៥៨:១៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយបន្តទៅនេះ ផ្ដល់វេទិកាទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីដាក់បង្ហាញឯកសារគន្លឹះរបស់ខ្លួន។

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ភាគី ដើមបណ្ដឹងរដ្ឋប្បវេណី និងសាធារណជន។ ជាបឋម ខ្ញុំសូមលើកបង្ហាញឯកសារគន្លឹះពាក់ព័ន្ធទៅនឹងដើមបណ្ដឹងរដ្ឋប្បវេណី ជាពិសេសពាក់ព័ន្ធទៅនឹងការប្រព្រឹត្តទៅលើជនជាតិចាមដូចតទៅ។

នៅក្នុងឯកសារដំបូងរបស់ខ្ញុំ គឺជាឯកសារលេខ E3/6718 ដែលជាពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោក ម៉ាត់ គើ ដែលមាន ERN ជាភាសាខ្មែរ 00563555 ដល់60 មិនមានជាភាសាអង់គ្លេសទេ ក៏ប៉ុន្តែបានស្នើសុំឲ្យមានការបកប្រែរួចហើយ តាំងពីខែ០៨ (សីហា) ឆ្នាំ២០១៥។ ខ្ញុំសូមដកស្រង់សម្រង់របស់ពាក្យសុំរបស់លោក ម៉ាត់ គើ ដូចតទៅ៖ “ខ្ញុំបាទ ម៉ាត់ គើ សព្វថ្ងៃរស់នៅភូមិទី៥ ឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម។ ការបះបោររបស់អ្នកភូមិស្វាយឃ្លាំង (ភូមិទី៥) នៅពេលដែលខ្មែរក្រហមវាយបែកទីក្រុងភ្នំពេញ ឆ្នាំ១៩៧៥ នៅពេលដែលអ្នកទីក្រុងភ្នំពេញត្រូវបានខ្មែរក្រហមជម្លៀសមកនៅតាមជនបទ ខ្មែរក្រហមបានយករទេះមកដឹកចាស់ៗ នៅក្នុងភូមិម្ដងប្រហែល១០នាក់ ដាក់រទេះសេះដឹកចេញទៅ ប្រហែលបួនប្រាំរទេះសេះ។ ខ្ញុំមិនដឹងថាខ្មែរក្រហម (មិនស្គាល់ឈ្មោះ) ដឹកពួកគាត់យកទៅណានោះទេ។ គ្រាន់តែដឹងថា អ្នកដែលខ្មែរក្រហមដឹកយកទៅ គឺមិនដែលបានឃើញត្រឡប់មកភូមិវិញ។ ខ្ញុំគិតថា ពួកគាត់ត្រូវពួកខ្មែរក្រហមយកទៅសម្លាប់បាត់ហើយ។ ចាស់ៗ ដែលត្រូវខ្មែរក្រហមដឹកទៅមានដូចជា ឪពុករបស់ លី ប៉ាត់ ឈ្មោះ អេល លី និងឪពុករបស់ លី ស៊ូកី ឈ្មោះ សាន់ លី ត្រូវបានខ្មែរក្រហមយកទៅសម្លាប់។ ខ្ញុំមិនបានដឹងថា ហេតុអ្វីបានជាខ្មែរក្រហមយកអ្នកចាស់ៗទៅសម្លាប់នោះទេ។ ខ្ញុំគ្រាន់តែធ្លាប់ឮខ្មែរក្រហមឈ្មោះ ឱក (ភេទប្រុស) ជាប្រធានសន្តិសុខស្រុកក្រូចឆ្មារ ដែលជាជនជាតិខ្មែរ បាននិយាយពេលប្រជុំថា ត្រូវតែបោសសម្អាតពួកសក្តិភូមិឲ្យអស់ ប៉ុន្តែខ្ញុំមិនដឹងថា នរណា ឬពួកណាទេជាសក្តិភូមិ។

[១៥:០២:០៦]

ក្រោយពីការប្រកាសហើយ នៅក្នុងភូមិចេះតែមានបាត់មនុស្សនៅក្នុងភូមិ។ កាលនោះប្រធានភូមិទី៥ ឈ្មោះ ម៉ាត់ (ប្រធានភូមិខ្មែរក្រហម) និងមាន តាសុះ ជាប្រធានសន្តិសុខភូមិ។ ដោយសារតែអ្នកភូមិចេះតែបាត់ចេញពីភូមិ នៅយប់ថ្ងៃមួយ ឮតាមអ្នកភូមិដូចគ្នានិយាយតៗគ្នាថា ខ្មែរក្រហម (មិនស្គាល់ឈ្មោះ) មានផែនការ និងយកអ្នកភូមិ២០នាក់ បន្ទាប់មកនឹងយក២០០នាក់ផ្សេងទៀតទៅ ដោយមានរៀបចំផែនការ និងដាក់ឈ្មោះរួចជាស្រេច ថានឹងត្រូវយកនរណាគេទៅ។ ដោយសារតែឮដំណឹងនេះ អ្នកចាស់ៗក្នុងភូមិដែលនៅសេសសល់ បាននាំគ្នារៀបចំផែនការបះបោរនឹងពួកខ្មែរក្រហម ដែលចង់បំផ្លាញពូជសាសន៍ចាម (ខ្ញុំគិតថាដូច្នេះ)។ មិនតែប៉ុណ្ណោះ នៅពេលដែលខ្មែរក្រហមចូលមកដល់ខ្មែរក្រហមធ្វើបាបពួកអ៊ិស្លាមជាងប្រជាជនខ្មែរ ដូចជា ប្រសិនបើប្រជាជនអ៊ិស្លាមចង់ធ្វើដំណើរទៅណាមកណា ត្រូវសុំលិខិតអនុញ្ញាតពីពួកខ្មែរក្រហម មិនអាចដើរហើរបានទេ។ ជាងនេះទៅទៀត ខ្មែរ

ក្រហមបានបំបាត់សិទ្ធិជនជាតិចាមមិនឲ្យរៀនសូត្រតាមគម្ពីរអ៊ីស្លាមទេ គឺឲ្យរៀនសូត្រអក្សរខ្មែរ ក្នុងគោលបំណងលុបបំបាត់ភាសា និងអក្សរអ៊ីស្លាម។ ដោយសារតែបញ្ហាទាំងអស់នេះហើយ ទើបបណ្ដាលឲ្យអ្នកភូមិទី៥ នាំគ្នារើបម្រះពីការជិះជាន់ និងការចង់សម្លាប់ផ្ដាច់ពូជនេះ (ខ្ញុំគិតដូច្នេះ)។ ដូចនេះហើយបានចាស់ៗនៅក្នុងភូមិបានផ្ដួចផ្ដើមគំនិតគ្នា ធ្វើការបះបោរជាមួយខ្មែរក្រហម។ ខ្ញុំបានភ្លេចឈ្មោះអស់ខ្លះហើយ នៅស្គាល់និងចាំតែ អ៊ីម៉ាស្រុកក្រូចឆ្មារបច្ចុប្បន្ន ឈ្មោះ សុះ ពន់យ៉ាមីន ដែលជាអ្នកចូលរួមផ្ដើមគំនិតឲ្យមានការប្រឆាំងនឹងខ្មែរក្រហម។

[១៥:០៤:៤០]

នៅពេលថ្ងៃមុនការបះបោរ ខ្មែរក្រហមបាននិយាយគ្នាថា យប់នេះនឹងយកអ្នកភូមិ២០នាក់ ដោយអ្នកភូមិបានឮដំណឹងនេះ ក៏បានរៀបចំផែនការទប់ទល់ជាមួយក្រុមខ្មែរក្រហមវិញ ដើម្បីកុំឲ្យខ្មែរក្រហមយកអ្នកភូមិចេញពីភូមិទៅសម្លាប់បាន។ ដល់ពេលយប់ឡើង បើខ្មែរក្រហមមកហៅអ្នកណាម្នាក់នៅក្នុងភូមិ មិនត្រូវចុះទៅទេ ត្រូវនៅលើផ្ទះ បិទទ្វារឲ្យជិត ហើយស្រែកមកបំផុសបំផុលឲ្យអ្នកភូមិឮ ជិតៗគ្នាបានឮ។ នៅពេលឮសម្រែកអ្នកភូមិ (មិនចាំឈ្មោះ) បានទូងស្គរឲ្យសញ្ញាឲ្យអ្នកនៅក្នុងភូមិបានឮ ថាមានអាសន្នកើតឡើងហើយ។ បន្ទាប់មកប្រជាជនក្នុងភូមិនាំគ្នាកាន់កាំបិត ពូថៅ ចុះពីលើផ្ទះសំដៅទៅទីតាំងខ្មែរក្រហមនៅក្បែរព្រែក។ នៅយប់នោះខ្មែរក្រហម (មិនស្គាល់) មានគ្នាច្រើន ប៉ុន្តែក្ដាប់មិនបានថាមានប៉ុន្មាននាក់ទេ ព្រោះពេលយប់។ ដល់ពេលនោះអ្នកភូមិបានវាយប្រទប់ជាមួយខ្មែរក្រហម ហើយបានកាប់ស្លាប់ម្នាក់ខ្មែរក្រហមម្នាក់ឈ្មោះ ចែត្រ (ភេទប្រុស) ជាយោធាខ្មែរក្រហម។

ខ្ញុំបានចូលការបះបោរដែរ ប៉ុន្តែខ្ញុំអត់បាននៅខាងមុខទេ ខ្ញុំនៅខ្សែត្រៀមទី៣ ព្រោះកាលនោះប្រពន្ធខ្ញុំទើបឆ្លងទន្លេ។ បន្ទាប់ពីការបះបោរពីរយប់មួយថ្ងៃ បានពីរយប់មួយថ្ងៃ ខ្មែរក្រហមក៏បានព័ទ្ធជិតភូមិ ហើយបានបញ្ជាឲ្យអ្នកភូមិទម្លាក់កាំបិត ពូថៅ ហើយធ្វើដំណើរទៅលិច ទៅដល់វត្តដើមជ្រៃ និងវត្តកញ្ជក នៅភូមិដើមជ្រៃ ឃុំក្រូចឆ្មារ ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម។ នៅវត្តដើមជ្រៃ និងវត្តកញ្ជក់នោះ ខ្មែរក្រហមបានបំបែកឲ្យស្រីៗ និងកុមារនៅទីនោះ។ រីឯបុរសៗ ខ្មែរក្រហមបានដាក់ឲ្យនៅសាលាខ្សាច់ប្រឆេះ នៅភូមិក្រូចឆ្មារ ឃុំក្រូចឆ្មារ ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ចម្ងាយប្រហែលជាង១,៥គីឡូពីវត្តដើមជ្រៃ និងវត្តកញ្ជក់។ ខ្ញុំត្រូវខ្មែរក្រហមឃុំនៅសាលាខ្សាច់ប្រឆេះ។

[១៥:០៧:៤១]

ពេលនោះគ្រួសារខ្ញុំមានគ្នាប្រាំពីរនាក់ មានឪពុកម្ដាយ ជីតាឈ្មោះ វ៉ាត់ មូសា, ប្អូនប្រុសម្នាក់

ឈ្មោះ ម៉ាត់ ស៊ីន, ប្រពន្ធខ្ញុំឈ្មោះ សុះ ម៉ានយ៉ាន និងកូនស្រីអាយុប្រហែល២ខែ ឈ្មោះ ប៉ាវ ស៊ីយ៉ាស់។ ម្តាយរបស់ប្រពន្ធខ្ញុំ -- ម្តាយរបស់ខ្ញុំ ប្រពន្ធខ្ញុំ ប្អូនប្រុសខ្ញុំអាយុប្រហែល១៨ឆ្នាំ និងកូនស្រីខ្ញុំត្រូវដាក់នៅវត្តដើមជ្រៃ។ រីឯឪពុក និងជីតាខ្ញុំ ព្រមទាំងខ្ញុំនៅសាលាខ្សាច់ប្រឆេះ ឃុំក្រូចឆ្មារ ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម។ សាលាខ្សាច់ប្រឆេះមានបីបន្ទប់ ហើយមួយបន្ទប់មានគ្នាប្រហែល៤០នាក់។ នៅទីនោះបានប្រហែលមួយអាទិត្យ ខ្មែរក្រហម (មិនស្គាល់ឈ្មោះ, ជាសន្តិសុខ) បានកាន់ក្រដាសមួយមកហៅប្រជាជននៅក្នុងនោះ។ នៅក្នុងបន្ទប់ដែលខ្ញុំនៅ ខ្មែរក្រហមបានហៅឈ្មោះចេញទៅមានគ្នាប្រាំពីរនាក់។ ខ្ញុំមិនបានចាំថា ជាអ្នកណាទេ ដោយក្នុងនោះមានបងថ្លៃខ្ញុំម្នាក់ (ប្រុស) ឈ្មោះ អេល ហ៊ីម និងបងថ្លៃ ស៊ីម កូប ដោយប្រាប់ថាឲ្យមកផ្ទះវិញ។ នៅសាលារៀនខ្សាច់ប្រឆេះជាងមួយខែ ខ្មែរក្រហមបានលែងឲ្យមកជួបប្រពន្ធកូនវិញ ដើម្បីជម្លៀសទៅកន្លែងផ្សេងទៀត។ ខ្ញុំបានមកសួរម្តាយនិងបងស្រីខ្ញុំថា បានឃើញបងថ្លៃទាំងពីរឬអត់? ពួកគាត់ឆ្លើយថា មិនបានឃើញទេ។ ដូចនេះខ្ញុំគិតថា អ្នកដែលខ្មែរក្រហមចុះឈ្មោះនៅក្នុងក្រដាសនោះ ត្រូវបានយកទៅសម្លាប់បាត់ហើយ។

នៅសាលាខ្សាច់ប្រឆេះនោះ ខ្មែរក្រហមបានវាយធ្វើបាប និងបង្អត់អាហារអ្នកភូមិ។ ខ្មែរក្រហមចែកបបរវាវឲ្យក្នុងម្នាក់មួយវែកឲ្យហូប ហើយពេលដែលខ្មែរក្រហមឲ្យទៅងូតទឹក គឺខ្មែរក្រហមលែងឲ្យទៅម្តងពីរនាក់ ងូតទឹកនៅកំពង់ ព្រោះសាលានោះនៅជិតមាត់ទន្លេ។ ប្រសិនបើអ្នកណារត់យឺត ខ្មែរក្រហមនឹងវាយអ្នកនោះ។ ហើយនៅក្នុងសាលានោះ ខ្មែរក្រហមបិទទ្វារបង្អួចជិត មិនមានពន្លឺ និងខ្យល់ចេញចូលទេ។

[១៥:១០:២៧]

នៅក្នុងបន្ទប់ឃុំឃាំងនៅសាលាខ្សាច់ប្រឆេះ ភូមិក្រូចឆ្មារ ឃុំក្រូចឆ្មារ ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម មានអ្នកឃុំឃាំងដូចជា ម៉ើរ រួន, ទេស ស្រេន, សុះ ស្មើរ (ស្លាប់នៅឆ្នាំ១៩៩៩) និងអ្នកភូមិផ្សេងទៀត មិនស្គាល់ឈ្មោះ។ ក្រោយមក៣០ថ្ងៃ បន្ទាប់ពីឃុំឃាំងនៅសាលាខ្សាច់ប្រឆេះ ខ្មែរក្រហមបានយកទូកចែវ មកដឹកអ្នកភូមិចេញសំដៅទៅភូមិឈើធាង ឃុំ(មិនស្គាល់) ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម។ ពេលនោះគ្រួសារខ្ញុំទាំងប្រាំពីរនាក់ បានធ្វើដំណើរទៅជាមួយគ្នាតាមទូក។ លុះដល់ភូមិឈើធាង ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ខ្មែរក្រហមបានឲ្យអ្នកភូមិចុះដើរសំដៅទៅភូមិបីផ្សេងគ្នា មានភូមិបន្ទាយជ័យ ភូមិជ័យសម្បត្តិ និងភូមិតំបែ ឃុំតំបែ ស្រុកតំបែ ខេត្តកំពង់ចាម។”

ខ្ញុំនឹងអានព័ត៌មានរបស់ដើមបណ្តឹងរដ្ឋប្បវេណីមួយទៀត ដែលមានលក្ខណៈខ្លីជាងនេះ គឺដើម

បណ្តឹងរដ្ឋប្បវេណីឈ្មោះ ម៉ាត់ មូសា ដែលមានលេខERNជាភាសាខ្មែរ 00499859 រហូតដល់ 0049 9859, ជាភាសាអង់គ្លេស 01063871 ដល់01063872, ERNជាភាសាបារាំង 00897184 ដល់008 97184។ ខ្ញុំសូមបញ្ជាក់លេខឯកសារ គឺលេខឯកសារ E3/6035 ដែលព្រឹត្តិការណ៍ដែលដើមបណ្តឹងរដ្ឋប្បវេណីនេះបានលើក គឺនៅឃុំជយោ ស្រុកចំការលើ ខេត្តកំពង់ចាម។ ខ្ញុំសូមដកស្រង់ព័ត៌មានរបស់គាត់ដូចតទៅ៖ "នៅក្នុងឆ្នាំ១៩៧៦ អង្គការបានប្រកាសឲ្យហូបបាយរួម។ នៅពេលនោះ ដែលសាសនិកអ៊ីស្លាមទទួលរងគ្រោះគ្រប់បែបយ៉ាង តាំងពីនិយាយស្តី ថ្វាយបង្គំព្រះ ហូបចុក ។ល។ បើគេចង់ធ្វើបាបជនជាតិចាម ពួកគេធ្វើបបរគ្រឿងសាច់ជ្រូក មួយដង ពីរដង ឬក៏បីដង បើមិនព្រមហូប អង្គការយកដាក់មន្ទីរសន្តិសុខ ហើយវាយចោល។ នៅពេលដែលយើងឥតហូប មានតែអត់ ពីព្រោះចានឆ្នាំង និងអ្វីៗទាំងអស់ សូម្បីតែស្លាបព្រាក៏គ្មានដែរ។ នៅពេលដែលយើងឃ្លានខ្លាំងពេក ដើរទៅបេះផ្លែឈើមកហូបដោយគ្មានការអនុញ្ញាតពីអង្គការទេ ប្រហែលជាទទួលទោសហើយ។ កុំថាឡើយផ្លែឈើនោះ ផ្លែឈើនោះជារបស់គេ សូម្បីតែរបស់យើងដាំនៅជុំវិញផ្ទះយើង ក៏មិនបានដែរ។ ពិសេស ឲ្យតែឃើញផ្សែងភ្លើងគឺមិនបាន ពីព្រោះអង្គការ មានអ្នកឈ្លបរាយការណ៍ច្រើន ពិសេសគឺកុមារតូចៗ ដែលអង្គការប្រមូលយកទៅដាក់នៅកន្លែងមួយ ហៅថា មន្ទីរកុមារបដិវត្ត។"

[១៥:១៥:00]

ខ្ញុំសូមអនុញ្ញាតអានព័ត៌មានរបស់ដើមបណ្តឹងរដ្ឋប្បវេណីដដែលនេះ ដែលជាព័ត៌មានបន្ថែមរបស់គាត់ គឺឯកសារលេខ E3/6035a ដែលមាន ERN ជាភាសាខ្មែរ 00584903, ជាភាសអង់គ្លេស 00858208, ជាភាសាបារាំង 00881065។ ដែលខ្ញុំសូមដកស្រង់ចំណុចទី៣ របស់ព័ត៌មានបន្ថែមរបស់លោក ម៉ាត់ មូសា ដូចតទៅ៖ "៣) ការធ្វើទុក្ខបុកម្នេញចាម ក្នុងឆ្នាំ១៩៧៥-៧៦ ខ្មែរក្រហមបានចាប់យកទាហាន និងប្រជាជន១៧មេសា ទៅសម្លាប់ចោល។ ទាហានខ្មែរក្រហមក៏បានហៅខ្ញុំទៅសួរចម្លើយពីប្រវត្តិរូបរបស់ខ្ញុំ ថាតើខ្ញុំជាទាហាន ឬមិនមែនជាទាហាន។ តែខ្ញុំបដិសេធថា ខ្ញុំមិនមែនជាទាហានទេ ពីព្រោះពេលនោះ ខ្ញុំគ្មានឈ្មោះក្នុងបញ្ជី។ ម្យ៉ាងទៀតសាក្សីដែលឆ្លើយដាក់ខ្ញុំដែលជាទាហានជាមួយគ្នា ត្រូវបានខ្មែរក្រហមយកទៅសម្លាប់អស់ហើយ។ គេបានដោះលែងខ្ញុំមកវិញ ដោយសារគ្មានភ័ស្តុតាង។ ក្រោយការសម្លាប់នេះ គេបែងចែករវាងប្រជាជនមូលដ្ឋាន និងប្រជាជនថ្មីទៀត។ ជំនាន់ខ្មែរក្រហម គេឲ្យខ្ញុំធ្វើចុងភៅ ដោយសារគេដឹងថាខ្ញុំជាចាម ដូច្នេះខ្ញុំមិនហ៊ានលួចស៊ីសាច់ជ្រូករបស់អង្គការទេ។ ហើយបានធ្វើបាបជនជាតិចាមខ្ញុំ ដូចជា បង្ខំឲ្យស៊ីសាច់ជ្រូកជាដើម។ ក្រោយមកខ្ញុំត្រូវបានគេឲ្យ

ទៅរកត្រីនៅទន្លេ ពួកខ្មែរក្រហមតែងតែជេរប្រមាថពួកចាមថា ពួកអត់នគរ ត្រូវគាស់រំលីងឲ្យអស់។"

ខ្ញុំសូមអនុញ្ញាតអានឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណីមួយទៀត គឺឯកសារបន្ថែមរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ឯល ឡេះ។ លេខឯកសារ E3/6226a ដែលមានលេខ ERN ជាភាសាខ្មែរ 00584410, ជាភាសាអង់គ្លេស (សូមទោស) ជាភាសាខ្មែរ 00584410 រហូតដល់11, ជាភាសាអង់គ្លេស 01184705, ជាភាសាបារាំង 01202983 ដល់01202983។

[១៥:១៩:០៤]

ខ្ញុំសូមដកស្រង់ដូចតទៅ៖ "កាលពីជំនាន់សម័យ លន់ នល់ ខ្ញុំគឺជាប្រជាកសិករធម្មតារស់នៅភូមិត្រពាំងឈូក ឃុំបឹង ស្រុកបារាយណ៍ ខេត្តកំពង់ធំ ជាមួយនិងក្រុមគ្រួសារ។ រហូតមកដល់ដើមឆ្នាំ ១៩៧៥ កងឈ្លបខ្មែរក្រហមបានជម្លៀសអ្នកភូមិរបស់ខ្ញុំទៅកាន់ភូមិដោម ឃុំបាក់ស្នា ស្រុកបារាយណ៍ ខេត្តកំពង់ធំដដែល។ ការប្រតិបត្តិសាសនានៅក្នុងភូមិរបស់ខ្ញុំ មានការគាបសង្កត់ខ្លាំង ដូចជា មានការបង្ខំឲ្យហូបសាច់ជ្រូវមនៅក្នុងសហករណ៍ ដោយមានកងឈ្លបធ្វើម្ហូបតាមដើរមើល ចាំមើល។ ពេលខ្លះមានការគំរាមកំហែង ឬសម្លុតឲ្យហូប។ ជាមួយគ្នានេះមានអ្នកភូមិខ្ញុំឈ្មោះ តាំ សំ ត្រូវបានគេបង្ខំឲ្យចិញ្ចឹមជ្រូក មើលថែឲ្យចំណីជ្រូកនៅពីក្រោយផ្ទះរបស់ខ្ញុំ។ នៅចុងឆ្នាំ១៩៧៨ ខ្មែរក្រហមឈ្មោះ យ៉េម បានចាប់គាត់យកទៅសម្លាប់ទាំងយប់ ដោយសារការរអ៊ូរទាំ។ តាំ សំ នេះត្រូវបានគេឃុំនៅក្នុងគុកសហករណ៍បាក់ស្នាមុនយកទៅសម្លាប់។ ខ្ញុំបានលួចសំយ៉ាំងបានរយៈពេលប្រហែលមួយឆ្នាំ ប៉ុន្តែជិតដល់ពេលឆ្នាំរំដោះ ខ្ញុំមិនហ៊ាន ពីព្រោះខ្លាចគេសម្លាប់ ពីព្រោះថា ខ្ញុំបានឃើញរណ្តៅខ្មែរក្រហមសម្លាប់មនុស្ស។ សម្រាប់ការធ្វើបាបមកលើប្រជាជនខ្មែរនៅក្នុងភូមិរបស់ខ្ញុំ មានស្ថានភាពស្រាលជាងប្រជាជនអ៊ីស្លាម ពីព្រោះប្រសិនបើជនជាតិអ៊ីស្លាមនិយាយអ្វីខុស ខ្មែរក្រហមយកទោសពៃរ៍ជាងប្រជាជនខ្មែរ។ តាមគំនិតខ្ញុំៗ គិតថា វាជាការរើសអើងមកលើខ្មែរអ៊ីស្លាម។"

[១៥:២១:៣២]

ខ្ញុំសូមអនុញ្ញាតអានឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ទៀតឈ្មោះ ម៉ាត ហាក់ ដែលមានលេខឯកសារ E3/6725 មិនមានឯកសារជាភាសាបារាំង ឬភាសាអង់គ្លេសទេ ក៏ប៉ុន្តែបានស្នើសុំរួចហើយនៅថ្ងៃទី០៣ ខែ៨ ឆ្នាំ២០១៥។ ខ្ញុំសូមដកស្រង់ដូចតទៅ៖ "ខ្ញុំបាទឈ្មោះ ម៉ាត់ ហាក់ អាយុ៦៩ ឆ្នាំ បច្ចុប្បន្នស្នាក់នៅភូមិទី៥ ឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម។ ខ្ញុំសូមប្តឹងពីរឿងរ៉ាវដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហមដូចខាងក្រោម៖ នៅចុងឆ្នាំ១៩៧៥ ខែ៨ នៅខែទឹកឡើង បងប្អូន

អ៊ីស្លាមក្នុងភូមិទី៥ ឃុំស្វាយឃ្លាំងបានធ្វើការតស៊ូជាមួយយោធាខ្មែរក្រហម ដោយសារតែយោធាខ្មែរក្រហមបានរឹតបន្តឹងឲ្យគោរពប្រតិបត្តិសាសនា -- ពុំឲ្យគោរពប្រតិបត្តិសាសនា។ ការសំពះយ៉ាំងត្រូវបានហាមឃាត់ ហើយចាប់ប្រជាជននៅក្នុងភូមិយកទៅបាត់ជារៀងរាល់ថ្ងៃ។ ខ្ញុំបានឃើញអ្នកភូមិរស់នៅភូមិជាប់របងជាមួយមានឈ្មោះ ស៊ឹម មីន ត្រូវយោធាខ្មែរក្រហមគ្នាពីរនាក់ មកហៅចំៗឈ្មោះថាទៅខាងណោះមួយភ្លែត។ ពេលចុះពីលើផ្ទះមក ហើយមកដល់ផ្លូវ ក៏ត្រូវយោធាខ្មែរក្រហម (ខ្ញុំមិនស្គាល់ឈ្មោះ) ចាប់ចងស្លាបសេកបណ្តើរ អ្នកភូមិជនរងគ្រោះ ដទៃទៀតចាប់ចងស្លាបសេក អ្នកភូមិដទៃទៀតសំដៅទៅ -- និងអ្នកភូមិដទៃទៀតសំដៅទៅទិសខាងកើត។ ខ្ញុំពុំដឹងថាបណ្តើរយកទៅណាទេ ក្រោយមកទើបបងប្អូនអ៊ីស្លាមទ្រាំពុំបានក៏ធ្វើការបះបោរ។”

[១៥:២៣:៣៥]

ខ្ញុំសូមរំលងព័ត៌មានរបស់គាត់ដោយសារវែង ហើយឈានចូលទៅស្តាប់ព័ត៌មានរបស់ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ទៀត គឺឈ្មោះ លី ប៉ាត់។ ដែលមានលេខ ERN ជាភាសាខ្មែរ 00563582 ដល់ 84, ជាភាសាអង់គ្លេស 01069332 និងភាសាបារាំង01139851។ ខ្ញុំសូមបញ្ជាក់ថា នេះគឺជាឯកសារលេខ E3/6119 ដែលខ្ញុំសូមស្រង់ដូចតទៅ៖ “ព្រឹត្តិការណ៍បះបោរនៅស្វាយឃ្លាំង៖ ក្រោយពីការចាប់ឪពុកខ្ញុំបានរយៈពេលពីរខែ មានព្រឹត្តិការណ៍បះបោរនៅស្វាយឃ្លាំង បន្ទាប់ពីមានការបះបោរនៅភូមិកោះផល ឃុំប៉ឺស១ ស្រុកក្រូចឆ្មារ។ មុនពេលបះបោរនៅភូមិទី៥ ឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាមរយៈពេលពីរថ្ងៃ ខ្ញុំបានឮគេនិយាយថា និយាយតៗគ្នាថា មានការដាក់ផែនការចាប់មនុស្សនៅក្នុងភូមិបន្ថែម ប្រហែល៥០ទៅ៦០នាក់ទៀត នាំឲ្យប្រជាជនក្នុងភូមិមានការជ្រួលច្របល់ ភ័យខ្លាចដោយពុំដឹងថាអ្នកណានឹងត្រូវខ្មែរក្រហមចាប់បន្តបន្ទាប់។ ដោយសារតែឮដំណឹងនេះ ហើយខ្មែរក្រហមបានរឹតបន្តឹងសាសនាអ៊ីស្លាមមិនឲ្យថ្វាយបង្គំ។ ចំពោះស្រីៗ មិនឲ្យទទូរក្រមា និងឲ្យកាត់សក់ខ្លី ដែលខុសពីអ៊ីស្លាម គឺស្រីត្រូវទទូរក្រមា មិនឲ្យអ្នកដទៃឃើញសក់របស់ខ្លួន និងទុកសក់វែង ពីព្រោះតែខ្លាចបាប (ធ្លាក់នរក)។ ជាហេតុធ្វើឲ្យការបះបោរចាប់ផ្តើមធ្វើពីម៉ោងប្រាំបីយប់ ដោយចាប់ផ្តើមពីអ្នកភូមិចំនួន២០-៣០នាក់ ទូងស្គរពេញភូមិដើម្បីប្រកូកប្រកាសហៅអ្នកភូមិផ្សេងទៀត ឲ្យធ្វើការរើបម្រះរហូតដល់ម៉ោងប្រាំពីរយប់ថ្ងៃបន្ទាប់ ទើបទ័ពខ្មែរក្រហម(មិនចាំឈ្មោះ និងចំនួនពិតប្រាកដ) ប៉ុន្តែខ្ញុំដឹងថា ទ័ពខ្មែរក្រហមទាំងនោះ ព័ទ្ធជុំវិញភូមិ ដោយមានកាន់កាំភ្លើងបេ-៤០ និងកាំភ្លើងដៃមួយចំនួន ដែលទ័ពខ្មែរក្រហមបានបាញ់ចូលទៅក្នុងភូមិ ដើម្បីបំបែកការប្រឆាំងនេះ។ ដោយសារតែអ្នកភូមិទាំងអស់ពុំមានអ្វីត

តាំងជាមួយទ័ពខ្មែរក្រហម និងការស្លាប់ជាច្រើននាក់ ទើបអ្នកភូមិដែលធ្វើការបះបោរទាំងអស់ នៅរស់ត្រូវបានចាប់ខ្លួនទាំងអស់។ ព្រឹត្តិការណ៍បះបោរនេះកើតនៅក្នុងភូមិទី៥ ឃុំស្វាយឃ្លាំង ពេលនោះខ្ញុំទើបតែមានអាយុប្រហែល១៥-១៦ឆ្នាំ ដោយខ្ញុំ ជាមួយបងស្រីឈ្មោះ លី នាង, ម្ដាយខ្ញុំឈ្មោះ ម៉ាត់ យ៉ុម, ប្អូនស្រីខ្ញុំឈ្មោះ លី សាំរ៉ូស និងប្អូនស្រីឈ្មោះ លី ប៉ៃតាស់ រួមទាំងអ្នកភូមិចំនួន១.០០០គ្រួសារ ត្រូវបានកៀរជម្លៀសចេញទៅឃុំក្រូចឆ្មារ ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ដោយបំបែកបុរស និងស្ត្រី រួមទាំងក្មេងៗឲ្យនៅផ្សេងៗគ្នា។ មូលហេតុដែលនាំឲ្យមានការបំបែកបុរស និងស្ត្រីឲ្យនៅផ្សេងពីគ្នា ពីព្រោះតែខ្មែរក្រហម (មិនស្គាល់ឈ្មោះ) ចោទបុរសៗភូមិទី៥ ឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ថាជាអ្នកខ្មាំង។ ចំណែកឯខ្ញុំត្រូវបានទៅរស់ជាមួយម្ដាយ និងប្អូនស្រីរបស់ខ្ញុំ។”

[១៥:២៧:៥១]

បាទ ខ្ញុំសូមបន្តទៅព័ត៌មានរបស់ដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់ទៀត ដែលមាន ខ្ញុំស្រង់ព័ត៌មានខ្លី គឺដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ សុះ វីនី ដែលមានឯកសារ E3/5050 ដែលមាន ERN ជាភាសាខ្មែរ 00565287, ជាភាសាអង់គ្លេស 01060089, ជាភាសាបារាំង 00932703 ដល់04។ ខ្ញុំសូមស្រង់ដូចតទៅ៖ “ក្នុងថ្ងៃមួយ តែចៃនដ្យ--”។ សូមទោស ខ្ញុំសូមស្រង់ម្ដងទៀត លោកបានលើកថា៖ “ការគោរពសាសនា គឺមិនអាចធ្វើបានទេ ពួកខ្មែរក្រហមបំបាត់មិនឲ្យគោរព សូត្រធម៌ ថ្វាយបង្គំព្រះ ហើយមិនឲ្យស្លៀកពាក់បែបអ៊ីស្លាមទេ។”

នៅក្នុងឯកសារ -- អ៎! ផ្នែកបន្ទាប់នៃឯកសាររបស់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនោះ លោកក៏បានលើកដែរថា ខ្ញុំសូមស្រង់៖ “ចំពោះការគោរពសាសនាគឺមិនបានតែម្ដង។ ទោះបីជាដឹងថា ពួកខ្ញុំជាខ្មែរអ៊ីស្លាម ពួកខ្មែរក្រហមធ្វើបាប ពេលខ្លះបង្ខំឲ្យហូបសាច់ជ្រូក ឬភូតកុហកឲ្យហូបបបរដែលមានលាយជាមួយសាច់ជ្រូក។ ខ្មែរអ៊ីស្លាមដែលទ្រាំអត់អាហារមិនបាន សុខចិត្តហូបសាច់ជ្រូក។ ពិសេសក្មេងៗដែលវាឃ្លាននាំ គ្នាហូបសាច់ជ្រូកដែលខុសពីសាសនា។ ពួកវាបង្ខំឲ្យស៊ីសាច់ជ្រូក បើមិនស៊ី ពួកវាថាបញ្ជូនទៅអង្គការលើ គឺយកទៅសម្លាប់។ មានអ្នកខ្លះហូប អ្នកខ្លះមិនហូប។ ពួកវាកាប់ជ្រូកយកសាច់ចែកឲ្យម្នាក់២ខាំ ហើយឈ្លបវាបានតាមដានយើង ពួកខ្មែរអ៊ីស្លាមខ្លះយកសាច់ជ្រូកនោះទៅសហករណ៍ដូរយកអំបិលវិញ។”

[១៥:៣០:៣៤]

ខ្ញុំសូមស្រង់ព័ត៌មានរបស់ដើមបណ្ដឹងរដ្ឋប្បវេណីចុងក្រោយ ដែលពាក់ព័ន្ធទៅនឹងផ្នែកចាមនេះ

គឺលោក ហាក់ ម៉ាត់ ដែលមានលេខឯកសារ E3/4892 ដែលមានERNជាភាសាខ្មែរ 00540804 ដល់ 06, ជាភាសាអង់គ្លេស 00890956 ដល់57, ជាភាសាបារាំង 00894003។ ខ្ញុំសូមស្រង់ដូចតទៅ៖ "ខ្ញុំឈ្មោះ ហាក់ ម៉ាត់ (ភេទប្រុស) សព្វថ្ងៃរស់នៅភូមិ៥ ឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ខ្ញុំសូមប្ដឹងអំពីរឿងដូចខាងក្រោម៖ ១) ការហាមឃាត់មិនឱ្យប្រណិប័តន៍សាសនាអ៊ីស្លាម។ ខ្មែរក្រហមចូលភូមិរបស់ខ្ញុំតាំងពីឆ្នាំ១៩៧០មកម្ល៉េះ រហូតដល់ឆ្នាំ១៩៧៥ ទើបខ្មែរក្រហមធ្វើការគាបសង្កត់លើប្រជាជន។ អ្នកមានមុខមាត់នៅក្នុងភូមិ ត្រូវខ្មែរក្រហមចាប់ខ្លួននៅក្នុងឆ្នាំ១៩៧៣ ក្នុងនោះមានឪពុកខ្ញុំម្នាក់ដែរ។ ឪពុកខ្ញុំត្រូវបានគេចាប់ខ្លួននៅឆ្នាំ១៩៧៣ ហើយបាត់ខ្លួនរហូតមកដល់សព្វថ្ងៃនេះ។ ឪពុករបស់ខ្ញុំឈ្មោះ ម៉ាន ហាក់។ នៅចុងឆ្នាំ១៩៧៥ ខ្មែរក្រហមបានហាមឃាត់មិនឱ្យសំឃុំង (ថ្វាយបង្គំព្រះ) ចំណែកស្រីៗត្រូវកាត់សក់ខ្លី ដែលនេះគឺផ្ទុយទៅនឹងការអនុវត្តក្នុងសាសនាអ៊ីស្លាម។ គេហាមឃាត់មិនឱ្យយើងនិយាយភាសាចាមទេ។

[១៥:៣២:៤០]

២) ការបង្ក្រាបការបះបោរជនជាតិចាម។ នៅចុងឆ្នាំ១៩៧៥ ប្រហែលជាខែកញ្ញា ពេលដែលជិតផុតខែបួសហើយនោះ ប្រជាជនភូមិខ្ញុំចាប់ផ្ដើមបះបោរប្រឆាំងខ្មែរក្រហមដែលធ្វើបាបប្រជាជន។ នៅមុនពេលបះបោរនោះ មានការចាប់ខ្លួនជាបន្តបន្ទាប់ ដូច្នេះហើយទើបប្រជាជននាំគ្នាបះបោរប្រឆាំង។ ប្រជាជននៅស្វាយឃ្លាំងនាំគ្នាកាន់កាំបិត និងពូថៅប្រឆាំង ដោយចាប់ទុកខ្មែរក្រហមធ្វើការឃុំឃាំងនៅឃុំស្វាយឃ្លាំងម្នាក់ឈ្មោះ ចែត្រ (ជនជាតិខ្មែរ) ហើយសម្លាប់។ ក្រោយមកខ្មែរក្រហមក៏មកព័ទ្ធភូមិស្វាយឃ្លាំង។ ប្រុសៗ ត្រូវចាប់ដាក់ទៅក្នុងឃ្លាំងស្តុកថ្នាំ នៅខាងលិចស្ពានព្រែកតាឌួង ឃុំក្រូចឆ្មារ ខ្ញុំក៏ត្រូវគេយកទៅដាក់នៅក្នុងឡថ្នាំនោះដែរ។ ចំណែកស្រីៗ ត្រូវគេយកទៅដាក់នៅតាមវត្តនិងព្រះវិហារ។ នៅក្នុងឃ្លាំងថ្នាំនោះ ខ្ញុំទទួលបានតែបបររាវៗ ពីរចានចង្កឹះក្នុងមួយពេល និងពីរពេលក្នុងមួយថ្ងៃ។ ការហូបចុកនេះគឺមិនគ្រប់គ្រាន់ទេ។ ខ្ញុំនៅទីនោះរយៈពេលប្រហែលជា២០ថ្ងៃនៅក្នុងឃ្លាំងនោះ។ ខ្ញុំឃើញខ្មែរក្រហមវាយធ្វើបាបអ្នកទីនោះ។ ខ្ញុំចាំថា ខ្មែរក្រហមវាយធ្វើបាបម្នាក់ឈ្មោះ ម៉ាន។ ចំណែកអ្នកភូមិម្នាក់ឈ្មោះ ឡោះ ដែលមានជំងឺត្រូវគេហៅចេញទៅក្រៅព្យាបាលនៅពេទ្យ ក៏បាត់ខ្លួនរហូត។ ពេលនៅក្នុងឡនោះ ខ្មែរក្រហមចម្រាញ់ប្រវត្តិរូបអ្នកដែលពាក់ព័ន្ធនឹងការបះបោរនោះ។ បន្ទាប់ពីនោះមកខ្ញុំត្រូវគេជម្លៀសជាបន្តបន្ទាប់ ឱ្យធ្វើស្រែចម្ការ រហូតដល់ឆ្នាំ១៩៧៩ ខ្ញុំក៏ត្រឡប់មកភូមិវិញ។"

បាទ ខ្ញុំសូមអានត្រឹមនេះ ហើយសូមលោកប្រធានអនុញ្ញាតឱ្យសហការីរបស់ខ្ញុំអានបន្តឯកសារ

របស់ដើមបណ្តឹងរដ្ឋប្បវេណី។ បាទ សូមអរគុណលោកប្រធាន។

[១៥:៣៥:១៦]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ ខ្ញុំមានឯកសារប្រាំ ដែលត្រូវបង្ហាញជូន ពាក់ព័ន្ធទៅនឹងដើមបណ្តឹងរដ្ឋប្បវេណីប្រាំរូប ដែលត្រូវបានទទួលយក ពាក់ព័ន្ធទៅនឹងវគ្គសវនាការស្តីអំពីជនជាតិចាម។ ជាពិសេស ខ្ញុំផ្តោតទៅលើព័ត៌មានដែលមានទំនាក់ទំនងជាមួយនឹងអង្គហេតុដែលអង្គជំនុំជម្រះធ្វើសវនាការ គឺពាក់ព័ន្ធទៅនឹងការជម្លៀសដោយបង្ខំ ដំណាក់កាលទី២។

ខ្ញុំចាប់ផ្តើមដោយឯកសារមួយដែលពាក់ព័ន្ធទៅនឹងដើមបណ្តឹងរដ្ឋប្បវេណី ដែលសហភាតារបស់ខ្ញុំទើបតែនិយាយ ឈ្មោះ ហាក់ ម៉ាត់។ គាត់មកពីស្វាយឃ្លាំង។ គឺឯកសារ E3/4893 ERNជាភាសាអង់គ្លេស 00851263 ដល់65, ERN ជាភាសាបារាំង គឺ00905154 ដល់55, ERN ជាភាសាខ្មែរ 00578133 ដល់36។ ចំពោះអ្នកបកប្រែ ខ្ញុំនឹងអានកថាខណ្ឌទី១នៃឯកសារនេះ។ ខ្ញុំសូមដកស្រង់៖ "បន្ទាប់ពីបានធ្វើការចម្រាញ់ប្រវត្តិរូបរួចរាល់ហើយ ខ្មែរក្រហមក៏បានជម្លៀសគ្រួសាររបស់ខ្ញុំ និងគ្រួសារបងប្អូនអ៊ីស្លាមជាច្រើនទៀត ដែលមិនមានជាប់ទាក់ទងទៅនឹងការបះបោរ ឲ្យទៅនៅភូមិ៤ ឃុំព្រែកអាជី ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម។ ពេលនោះពួកខ្មែរក្រហម (ខ្ញុំមិនស្គាល់ឈ្មោះ) មិនបានប្រាប់ពីមូលហេតុនៃការជម្លៀសនេះទេ។ ពួកវាគ្រាន់តែបញ្ជូនដាក់ទូក ហើយដឹកយើងយកទៅដាក់ភូមិ៤ ដោយមានឈ្លបក្មេងៗអមជាមួយយើងនៅលើទូកដែរ។ ពេលទៅដល់ភូមិ៤ គ្រួសាររបស់ខ្ញុំ រួមមានខ្ញុំ ប្រពន្ធខ្ញុំ ព្រមទាំងកូនបីនាក់ទៀត រស់នៅក្រោមដំបូលផ្ទះរបស់លោកយាយ ថោ ដែលជាជនជាតិខ្មែរ ហើយចិត្តល្អម្នាក់ គឺប្រហែលជាចុងឆ្នាំ៧៥។"

[១៥:៣៨:០៥]

បន្ទាប់មកទៀត នៅកថាខណ្ឌបន្ទាប់ទៀត គាត់ថា៖ "មានការជម្លៀសទី២មួយទៀត គឺគេដឹកតាមទូក រហូតទៅដល់ស្ទឹងត្រង់។ ពីដំបូងនោះគេថា គេដឹកយកទៅបាត់ដំបង ក៏ប៉ុន្តែពេលទៅដល់ស្ទឹងត្រង់ បងប្អូនចាមមួយចំនួន ត្រូវបានគេបញ្ជូនទៅខាងកំពង់ធំ ហើយមួយចំនួនទៀត គេបញ្ជូនទៅឲ្យទៅនៅភូមិសូភាស ឃុំសូភាស ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។"

ដើមបណ្តឹងរដ្ឋប្បវេណីមួយរូបទៀត មកពីស្វាយឃ្លាំងដែរ ហើយសព្វថ្ងៃនេះ គាត់ស្លាប់ទៅហើយ។ គាត់ឈ្មោះ លី តាំ គឺមានខ្សែជីវិតដូចគ្នា ក្រោយពីការបះបោរ។ ខ្ញុំសូមយោងទៅលើឯកសារ

គាត់គឺ E3/6715 ERN ជាភាសាខ្មែរគឺ 00564253 រហូតទៅដល់55, ERN ជាភាសាបារាំងគឺ 00 (សុំទោស) 01203007 ដល់08។ ក្នុងនេះមានការស្នើសុំឱ្យមានការបកប្រែជាភាសាអង់គ្លេស។ ដើមបណ្តឹងរដ្ឋប្បវេណី គាត់បានពន្យល់យ៉ាងច្បាស់នៅក្នុងព័ត៌មានបន្ថែមរបស់គាត់គឺឯកសារ E3/6715a។ ERN ជាភាសាខ្មែរគឺ 00585940 រហូតទៅដល់41, ERN ជាភាសាអង់គ្លេសគឺ 01184736 និងជាភាសាបារាំងគឺ 01203767។ លក្ខខណ្ឌជីវភាព និងវិធានការចំពោះជនជាតិចាមនៅក្នុងស្រុកស្ទឹងត្រង់ បន្ទាប់ពីមានការជម្លៀស គាត់បាននិយាយ ខ្ញុំសូមដកស្រង់ ចំពោះអ្នកបកប្រែគឺនៅជំពូកដែលមាននិយាយថា "ការធ្វើទុក្ខបុកម្នេញផ្នែកសាសនា"។ ខ្ញុំសូមដកស្រង់៖ "នៅឆ្នាំ១៩៧៧ ពេលទៅដល់ ហើយរស់នៅក្នុងភូមិស្វាភា ឃុំស្ទឹងត្រង់ ខេត្តកំពង់ចាម ពួកខ្មែរក្រហមបានបង្ខំឱ្យបងប្អូនជនជាតិអ៊ីស្លាមហូបសាច់ជ្រូក។ ពេលហូបសាច់ជ្រូកម្តងៗ ពួកវាតែងតែចាត់ឱ្យឈ្លបពីរបីនាក់ (ខ្ញុំមិនស្គាល់ឈ្មោះ) មកដើរមើល ថាតើពួកបងប្អូនអ៊ីស្លាមហូប ឬក៏អត់។ គ្មានអ៊ីស្លាមណាម្នាក់ហ៊ានប្រកែកទេ ពីព្រោះថា ខ្លាចគេយកទៅសម្លាប់ចោល។"

[១៥:៤១:១៧]

បន្ទាប់មកទៀត គាត់បានបញ្ជាក់នៅចុងបញ្ចប់នៃជំពូកអំពីការធ្វើទុក្ខបុកម្នេញខាងផ្នែកសាសនានេះ គាត់ថា៖ "ខ្ញុំឃើញខ្មែរក្រហមបានបង្ខំឱ្យជនជាតិចាមចិញ្ចឹមជ្រូក ហើយឱ្យមើលថែជ្រូកនៅក្នុងភូមិ។ ខ្មែរក្រហមនៅក្នុងភូមិហាមមិនឱ្យយើងសំឃុំាង ឬនិយាយភាសាអ៊ីស្លាមទេ។ បើអីចឹងគេនឹងសម្លាប់ចោល។ តែយើងចេះតែព្យាយាមលួចធ្វើខ្លះៗដែរ។ ខ្ញុំមិនដឹងពីមូលហេតុដែលខ្មែរក្រហមចេះតែធ្វើទុក្ខបុកម្នេញលើប្រពៃណីសាសនារបស់ជនជាតិអ៊ីស្លាមនោះទេ។ ជីវិតក្នុងសម័យខ្មែរក្រហមនេះ គឺវាពិបាកណាស់។"

ដើមបណ្តឹងរដ្ឋប្បវេណីចុងក្រោយដែលខ្ញុំចង់ដកស្រង់ ដែលគាត់មកពីស្វាយឃ្លាំងគឺ សុះ ម៉ូស្តើត ដែលមានអាយុ១៥ឆ្នាំនៅឆ្នាំ៧៥។ ខ្ញុំសូមយោងទៅលើឯកសារ E3/6716 ERN ជាភាសាបារាំងគឺ 01203011 រហូតទៅដល់14, ERN ជាភាសាខ្មែរគឺ 00563517 រហូតទៅដល់22។ យើងបានសូមឱ្យមានការបកប្រែជាភាសាអង់គ្លេសហើយ តែមិនទាន់បានទទួលនៅឡើយទេ។ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានឃុំនៅក្នុងវត្តពោធិ៍ព្រឹក្ស ដែលសហភាតារបស់ខ្ញុំបាននិយាយរួចមកហើយ។ គាត់បាននិយាយអំពីការជម្លៀសគ្រួសាររបស់គាត់ គឺនៅពាក់កណ្តាលទំព័រនៃឯកសារជាភាសាបារាំង៖ "ក្រោយមកខ្មែរក្រហមបានដឹកគ្រួសារខ្ញុំ និងអ្នកភូមិតាមទូក ហើយបញ្ជូនទៅភូមិរកាខ្នុរ ឃុំរកាខ្នុរ ស្រុកក្រូចឆ្មារ ខេត្ត

កំពង់ចាម។ ខ្ញុំចាំថា គេជម្លៀសខ្ញុំក្នុងពេលជាមួយគ្នានឹងគ្រួសាររបស់ លី ស៊ូគី។"

នៅក្នុងឃ្លាបន្ទាប់មកទៀតគាត់បាននិយាយថា៖ "យើងរស់នៅក្នុងភូមិរកាខ្នុរ ក្នុងរយៈពេល២ឆ្នាំ ហើយក្នុងតំបន់នោះ ខ្ញុំត្រូវឃ្វាលគោនៅក្នុងក្រុមមួយដែលមានមេឈ្មោះ ព្រៃ ហើយគាត់បានស្លាប់តាំងពីពេលនោះមកហើយ។ ខ្ញុំមិនស្គាល់ប្រធានភូមិ ប្រធានក្រុម ឬប្រធានសហករណ៍ទេ។ នៅក្នុងភូមិនេះ ខ្មែរក្រហមមិនបង្ខំជនជាតិចាមឲ្យហូបសាច់ជ្រូកទេ ក៏ប៉ុន្តែគេមិនឲ្យនិយាយភាសាចាម ហាមមិនឲ្យប្រតិបត្តិសាសនា និងហាមមិនឲ្យទុកសក់វែង។"

[១៥:៤៤:២៥]

ខ្ញុំមានដើមបណ្តឹងរដ្ឋប្បវេណីពីររូបទៀត ខ្ញុំនឹងនិយាយឲ្យបានឆាប់ ដែលត្រូវបានទទួលយកពាក់ព័ន្ធនឹងសវនាការស្តីពីការប្រព្រឹត្តទៅលើជនជាតិចាម។ គាត់ត្រូវបានជម្លៀសពីស្រុកកំពង់សៀមទៅស្រុកចំការលើ។ ខ្ញុំសូមយោងទៅលើឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ សា ឡិប គឺឯកសារ E3/6816a គឺជាពាក្យសុំព័ត៌មានបន្ថែមរបស់ឈ្មោះ សា ឡិប។ ERN ជាភាសាខ្មែរ 00588463រហូតទៅដល់ 65, ERN ជាភាសាបារាំង 00860859 ទៅដល់60, ERN ភាសាអង់គ្លេសគឺ 00853984 រហូតទៅដល់85។ គាត់មានអាយុ២៦ឆ្នាំនៅឆ្នាំ៧៥។ ខ្ញុំសូមយោងទៅលើកថាខណ្ឌទី២ នៃឯកសារដែលមានចំណងជើងថា ព័ត៌មានបន្ថែមអំពីការជម្លៀស។

"នៅឆ្នាំ១៩៧៥ ខ្ញុំនិងក្រុមគ្រួសាររបស់ខ្ញុំមានគ្នាទាំងអស់មានគ្នាទាំងអស់ប្រាំពីរនាក់ មានខ្ញុំ, ប្រពន្ធខ្ញុំ ម៉ាត់ អាំណាស់, កូនប្រុសពីរនាក់ ឡិប ពុកគ្រី និង ឡិប ស៊ុលសារី ព្រមទាំងកូនស្រីបីនាក់ ឡិប ហ្វាម៉ាស់, ឡិប សហ្វីយ៉ា និងម្នាក់ទៀតឈ្មោះ ឡិប ស្រីហ្វា បានទៅរស់នៅភូមិរងារ ឃុំសំបួរមាស ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ នៅពេលដែលខ្មែរក្រហមវាយឈ្នះទាហានលន់ នល់ ភ្លាមៗ យោធាខ្មែរក្រហម (មិនស្គាល់ឈ្មោះ) បានឲ្យខ្ញុំ ក្រុមគ្រួសារខ្ញុំ និងអ្នកភូមិនៅទីនោះទាំងអស់មានគ្នាប្រហែលជា១.០០០នាក់ ឲ្យជម្លៀសចេញពីភូមិ ដោយដើរដង្ហែរគ្នាទៅភូមិកំពង់ក្របី ខេត្តកំពង់ចាម ពីព្រលឹមស្រាងៗ។ រហូតទៅដល់ម៉ោងដប់មួយ សាមសិបនាទីទើបទៅដល់ទីនោះ (ភូមិកំពង់ក្របីក៏ជាភូមិចាមដែរ)។ ខ្ញុំនិងក្រុមគ្រួសារខ្ញុំរស់នៅទីនោះ ខ្មែរក្រហមឲ្យធ្វើស្រែចម្ការធម្មតា។"

[១៥:៤៧:០៤]

ឯកសារចុងក្រោយ គឺជាដើមបណ្តឹងរដ្ឋប្បវេណីមួយរូបដែលឈ្មោះ កសឹម ទូល័ស ដែលត្រូវបានជម្លៀសពីឃុំកោះសូទិន ខេត្តកំពង់ចាមទៅកាន់ខេត្តបាត់ដំបង។ ខ្ញុំសូមយោងទៅលើឯកសារ

E3/4776 ERN ជាភាសាអង់គ្លេសគឺ 00915942, ERN ជាភាសាបារាំងគឺ 01063310 រហូតទៅដល់11, ERN ជាភាសាខ្មែរគឺ 00497121 រហូតទៅដល់22។ ដើមបណ្ដឹងរដ្ឋប្បវេណីនេះគាត់មានអាយុក្មេងណាស់ គឺត្រឹមតែ១០ឆ្នាំតែប៉ុណ្ណោះនៅឆ្នាំ១៩៧៥។ ខ្ញុំសូមដកស្រង់នូវកថាខណ្ឌទី១នៃឯកសារ ៖ “ក្រោយពីទីក្រុងភ្នំពេញដួលរលំនៅឆ្នាំ៧៥ ខ្មែរក្រហមបានបណ្ដេញក្រុមគ្រួសាររបស់ខ្ញុំដែលមានគ្នាប្រាំបីនាក់ គឺឪពុកម្ដាយខ្ញុំ, បងខ្ញុំ(គឺ ទូល័ស លី និង ទូល័ស ស្លេះ) និងប្អូនប្រុសពីរនាក់របស់ខ្ញុំ (ទូល័ស ហ៊ីម និង ទូល័ស កូប) ប្អូនស្រីរបស់ខ្ញុំ (ទូល័ស ស្រីហ្វាស់) ហើយនិងខ្លួនខ្ញុំផ្ទាល់ គឺពីភូមិលេខ១៣ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម ហើយជម្លៀសទៅភូមិវត្តថែង ខេត្តបាត់ដំបងជាមួយនឹងអ្នកជិតខាងជាច្រើននាក់ផ្សេងទៀតដូចជា កូប ស៊ីន, កូប ចេះ, កូប ម៉ាត់។ ក្រោយពីរស់នៅពីរខែនៅក្នុងភូមិវត្តថែង ខេត្តបាត់ដំបង ខ្មែរក្រហមដែលខ្ញុំមិនស្គាល់ឈ្មោះ បានជម្លៀសគ្រួសាររបស់ខ្ញុំទៅភូមិស្រះកែវ ឃុំស្រះកែវ ខេត្តបាត់ដំបង តំបន់៥។ នៅរដូវវស្សាឆ្នាំ១៩៧៧ ប្អូនស្រីរបស់ខ្ញុំឈ្មោះ ទូល័ស ស្រីហ្វាស់ បានរាកមួលរហូតដល់ស្លាប់ ដោយសារតែអត់មានបាយហូបគ្រប់គ្រាន់។”

ខ្ញុំសូមបញ្ចប់នូវការបង្ហាញឯកសារពាក់ព័ន្ធនឹងការប្រព្រឹត្តជនជាតិចាម ហើយខ្ញុំសូមប្រគល់វេទិកានេះទៅលោកមេធាវី អង្គ ពេជ ម្ដងទៀត ដែលគាត់នឹងបង្ហាញឯកសារពាក់ព័ន្ធទៅនឹងការប្រព្រឹត្តចំពោះជនជាតិវៀតណាម។ សូមអរគុណលោកប្រធាន។

[១៥:៤៩:៥០]

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន ខ្ញុំសូមបញ្ជាក់បន្ថែមបន្តិចពាក់ព័ន្ធទៅនឹងការធ្វើទុក្ខបុកម្នេញទៅលើជនជាតិវៀតណាម មានដើមបណ្ដឹងរដ្ឋប្បវេណី -- ជនជាតិចាម មានដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់ទៀតដែលមានព័ត៌មានពាក់ព័ន្ធដែរគឺលោក ព័ត៌មានរបស់លោក ទើ ម៉ាត់។ លេខឯកសារ D22/1381a ដែលខ្ញុំសុំមិនអានឯកសាររបស់គាត់ទេ គ្រាន់តែលើកអំពីលេខរបស់ឯកសារតែប៉ុណ្ណោះ ដោយសារមានពេលវេលាខ្លី។

ពាក់ព័ន្ធទៅនឹងការធ្វើទុក្ខបុកម្នេញទៅលើជនជាតិវៀតណាម ខ្ញុំមានឯកសារដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួនដែលនឹងត្រូវលើក ហើយករណីខ្លះខ្ញុំនឹងលើកជាសង្ខេប។ ជាបឋមពាក់ព័ន្ធទៅនឹងការសម្លាប់ជនជាតិវៀតណាមនៅខេត្តព្រៃវែង និងការប្រព្រឹត្តទៅលើពលរដ្ឋខ្មែរដែលមានប្ដី ឬក៏ប្រពន្ធជាជនជាតិវៀតណាម និងដែលមានកូនដែលមានឪពុកម្ដាយជាជនជាតិវៀតណាម ខ្ញុំសូមលើកដូចតទៅ។

ជាដំបូង គឺឯកសាររបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ចិន ផៃ ដែលមានលេខឯកសារ E3/5900.1 ដែលជាឯកសារសម្ភាសរបស់លោកស្រី ដោយមន្ត្រីរបស់ ឌី.ស៊ី.ខេម ដែលមាន ERN ជាភាសាខ្មែរ 00352748 ដល់50, ជាភាសាអង់គ្លេស 01133203ដល់05, ជាភាសាបារាំងមិនមានទេ ក៏ប៉ុន្តែបានស្នើសុំបកប្រែរួចហើយ តាំងពីថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៥។ ដែលខ្ញុំសូមមិនអានទាំងអស់ទេ ក៏ប៉ុន្តែតែផ្នែកខ្លីតែប៉ុណ្ណោះនៃឯកសាររបស់គាត់។

[១៥:៥១:៥៣]

អ្នកដែលសម្ភាសលោកស្រី គឺឈ្មោះ វិជ្ជា ដែលខ្ញុំសូមដកស្រង់ដូចតទៅ៖ "វិជ្ជា៖ ចុះពេលដែលមីងទៅជីកព្រែកហ្នឹង មីងថាឆ្នាំ១៩៧៧ ពេលហ្នឹងគេយកវៀតណាមទៅសម្លាប់នៅ ឬក៏មិនទាន់សម្លាប់ទេ? ចម្លើយ៖ វាអ៊ីចេះ ដូចថា គេយកពីដើមខែអ៊ីចឹង ទេដូចនៅទេនៅឆ្នាំ៧៧។ វិជ្ជា៖ ពេលនោះគេយកវៀតណាមទៅសម្លាប់ហើយ បានគេយកមីងទៅជីកព្រែក ឬក៏មីងទៅជីកព្រែក ត្រឡប់មកវិញបានគេយកពួកវៀតណាមទៅសម្លាប់ អ៎! វៀតណាមទៅសម្លាប់? ឆ្លើយ៖ ត្រឡប់មកវិញ ព្រោះគេខឹងរឿងយួនចូលឈ្លានពាន បានគេស្រាវជ្រាវយកវៀតណាមទៅហ្នឹង។ វិជ្ជា៖ អ្ហ៎! ពេលនុ៎ងវៀតណាមឈ្លានពានមែនឬព្រំដែន? ឆ្លើយ៖ អ្ហ៎ ខ្ញុំទៅក៏មិនបានឃើញដែរណ៎ា។ វិជ្ជា៖ បាទ។ ឆ្លើយ៖ ប៉ុនគ្រាន់តែទៅនុ៎ងឃើញផ្ទះនៅជិតព្រំដែននុ៎ងខ្លះក៏វាឆេះ ខ្លះក៏វាអីទៅ។ វិជ្ជា៖ អ្ហ៎!ហើយមកវិញ គេចាប់ផ្ដើមរើបបណ្ដោយអ្ហ? ឆ្លើយ៖ មកពីជីកព្រែកវិញ។ វិជ្ជា៖ គេរើនុ៎ង រើម៉េចទៅ រើរកម៉េចទៅ? ផៃ៖ គេរើរកដូចថា អ្នកណាជាជនជាតិយួននុ៎ងណ៎ា គេរកអ៊ីចឹង។ វិជ្ជា៖ ទាំងចាស់ ទាំងក្មេងរើរកអ្ហ៎? គ្មានសល់ គេឱ្យតែថាជាប់យួន ជាប់ប្ដីយកប្ដីទៅ ជាប់ប្រពន្ធយកប្រពន្ធទៅ។ បើជាប់ប្រពន្ធអ៊ីចឹង យកដោយទាំងកូន។"

បាទ ចំពោះឯកសារនេះខ្ញុំសូមចប់ត្រឹមនេះ។ ហើយខ្ញុំឈានទៅឯកសាររបស់ដើមបណ្ដឹងរដ្ឋប្បវេណីបន្តទៀត គឺឯកសារទី២ដែលជាកិច្ចសម្ភាសន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី លោកស្រី យុន សាមិត ដែលមានលេខឯកសារ E3/7211 ដែលជាកិច្ចសម្ភាសន៍របស់លោកស្រីផងដែរ។ ហើយសូមជម្រាបថាឯកសារនេះ មានលេខមួយទៀត ឯកសារដដែលមានលេខពីរគឺ E3/7586 ដែលលេខចុងក្រោយនេះមានទាំងបីភាសាតែម្ដង។ ហើយឯកសារដែលនៅក្នុងលេខ E3/7211 មាន ERN ដូចតទៅ ភាសាខ្មែរ 00353071 ដល់72, ERN ជាភាសាអង់គ្លេស ខ្ញុំមិនបានស្រង់មកទេ ហើយជាភាសាបារាំងគឺ ERN 01155167។

[១៥:៥៥:១៤]

អ្នកដែលសួរសម្ភាសទៅលោកស្រី ឃុន សាមិត គឺឈ្មោះ ដានី។ "ដានីសួរ៖ ប្រពន្ធអ៊ំ ឃុន មុន ហ្នឹងគាត់ដឹងថា គេយកទៅសម្លាប់ដែរឬទេ? ដែរអ៊ីចឹង? ឆ្លើយ៖ គេដឹងដែរ។ បើគេប្រជុំថ្ងៃណា ក៏ និយាយអំពីយួនដែរ គណៈកងគេហ្នឹង។ ដានី សួរ៖ គេនិយាយថាម៉េចអ៊ំ? មិត ឆ្លើយ៖ គេនិយាយថា វៀតណាមនុំង អត់ឲ្យនៅជាមួយខ្មែរ។ ត្រូវប្រមូលឲ្យអស់ពីខ្មែរហ្នឹងទៅ។ ពីដំបូងស្មានតែគេប្រមូលឲ្យ ទៅនៅវៀតណាមនុំង មិនដឹងគេប្រមូលយកទៅវាយចោលអ៊ីចឹងអី។ ដានី សួរ៖ ដល់ពេលគាត់ដឹងខ្លួនថា គេប្រមូលអ៊ីចឹង គាត់មានអារម្មណ៍យ៉ាងម៉េចដែរ? មិត៖ គាត់ដឹងខ្លួនគាត់ដែរ។ ដានី៖ អារម្មណ៍គាត់ ម៉េចដែរ? គាត់ភ័យ គាត់យំ គាត់? មិត៖ គាត់ភ័យដែរស្លេកស្លាំងអស់ដែរហ្នឹង។"

ហើយខ្ញុំឈានទៅដល់ឯកសារដដែលនេះដែរ ក៏ប៉ុន្តែERN ខ្មែរ 00353073, អង់គ្លេស 0032 4465, ជាភាសាបារាំង 01155168។ មិត ដើមបណ្ដឹងរដ្ឋប្បវេណីនេះ បានឆ្លើយថា៖ "ព្រលឹមឡើង គេហៅចៅនុំង។ គេថា សុំយកកូនហ្នឹងទៅជួបម៉ែវា។ ខ្ញុំសុំមួយ គេមិនព្រម។ កាលនុំងបងខ្ញុំនេះ គាត់សុំ ដែរ។ គេហៅគាត់ទៅរករឿងគាត់មួយយប់ទៀតណ៎ា បងៗទៅមុននុំង។ គាត់អាណិតក្មួយ សុំមួយដែរ តែគេមិនព្រម។ គេបានយកក្មួយទៅវាយចោលអស់ហើយ។ គេហៅគាត់ទៅកសាង ណែនាំថា យួនទុក ធ្វើអីឲ្យជាប់ពូជ យកទៅវាយចោលឲ្យអស់ទៅ។ ដានី៖ គេប្រាប់ថា គេយកទៅចោលឲ្យអស់អ្ហ? ចម្លើយ៖ ចាស គេមិនទុកទេ ខ្លាចជាប់ពូជយួន។ គេនិយាយអ៊ីចឹង នោះបងខ្ញុំនុំងគាត់និយាយ គេហៅ គាត់ទៅ តែខ្ញុំហ្នឹងគេមិនហៅទេ។"

[១៥:៥៧:៤៧]

ខ្ញុំឆ្ពោះទៅឯកសាររបស់ដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់ទៀត ឈ្មោះ ផៃ ស្រុង ដែលមានលេខ ឯកសារ E3/5634 ដែលលោកនិយាយអំពីការនិរទេសជនជាតិវៀតណាមពីប្រទេសកម្ពុជាទៅវៀត-ណាម។ លេខERNជាភាសាខ្មែរ 00897516 ដល់18, លេខERNជាភាសាអង់គ្លេស 00678299ដល់ 300, លេខERNជាភាសាបារាំង 00899197 ដល់98។ ហើយខ្ញុំសូមស្រង់សម្រង់ដែលនៅក្នុងឯកសារ E3/5634របស់លោក ផៃ ស្រុង ដូតតទៅ៖ "ការនិរទេសទៅប្រទេសវៀតណាម៖ នៅខែកក្កដា ឆ្នាំ៧៥ ប៉ុន្មានថ្ងៃមុនការជម្លៀសនិរទេសទៅកាន់ប្រទេសវៀតណាម ខ្មែរក្រហមបានប្រាប់យើងឲ្យត្រៀមរៀបចំ ការចាកចេញ។ យើងបានសួរពួកវាថា ឲ្យពួកយើងទៅណា ប៉ុន្តែគេមិនឲ្យយើងដឹងឡើយ យើងគ្មានសិទ្ធិ សួរអ្វីទាំងអស់។ មុនពេលបង្ខំឲ្យយើងទៅប្រទេសវៀតណាម គ្មានពួនិយាយអ្វីអំពីយើងថា ឲ្យពួកយើង ទៅណាឡើយ ប៉ុន្តែយើងបានយល់ថា គេដូរយើងយកអំបិលនិងរដ្ឋាភិបាលវៀតណាម។ ជំនួញដូញដូរ

ជនជាតិវៀតណាម និងអំបិល គឺជាការជួយសង្គ្រោះរបស់ប្រទេសវៀតណាម។ ខ្ញុំមិនឃើញមានអំបិល ឬអង្ករសម្រាប់ដូររូបខ្ញុំទេ ប៉ុន្តែខ្ញុំបានដឹងរឿងនេះតាមអ្នកដទៃ។ ហើយខ្ញុំជឿថា វាជាការពិត ពីព្រោះខ្ញុំជឿថា បើគ្មានការដោះដូរទេ គឺគេមិនអនុញ្ញាតឱ្យយើងរស់នៅក្នុងស្រុកខ្មែរដែរ។ ប្រសិនបើយើងមិនអាចជម្លៀសទៅកាន់ប្រទេសវៀតណាមនោះទេ យើងប្រាកដជាស្លាប់នៅក្នុងប្រទេសកម្ពុជាមិនខាន។ ខ្ញុំរស់នៅក្នុងស្រុក១០ (ស្រុកបរិបូរ ខេត្តកំពង់ឆ្នាំង) ហើយគ្រប់គ្នាត្រូវបញ្ជូនចុះទៅកាន់កំពង់ផែ ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង។

[១៦:00:00]

នៅពេលយើងនៅឯកំពង់ផែ យើងបានឃើញជនជាតិវៀតណាមមកពីភ្នំកិប (ស្រុក១៦) ក៏ត្រូវបញ្ជូនមកពីភ្នំទៅកាន់កំពង់ផែដែរ។ គ្រប់គ្នាត្រូវគេបង្ខំឱ្យចាកចេញពីភ្នំកិប ហើយយើងក៏ចំណាយពេលប្រហែលមួយថ្ងៃ ដើរពីភ្នំកិបមកកាន់កំពង់ផែ។ មនុស្សទាំងអស់ត្រូវបញ្ជូនពីស្រុក១០ និងស្រុក១៦ ក្នុងខេត្តកំពង់ឆ្នាំង ឱ្យមកជិះទូកធ្វើដំណើរចាកចេញ។ អ្នកដែលមានជំងឺក៏បានស្លាប់នៅតាមផ្លូវ។ មានមនុស្សជាច្រើន ខ្ញុំមិនអាចចាំថាមានប៉ុន្មាននាក់ទេ យើងទាំងអស់គ្នាត្រូវគេឱ្យនៅជុំគ្នា ហើយចាកចេញ។ យើងចាកចេញពីស្រុកកំពង់ឆ្នាំង ដោយជិះទូកនៅពេលយប់។ យើងឆ្លងកាត់ទីក្រុងភ្នំពេញទៅកាន់ប្រទេសវៀតណាម តាមដងទន្លេសាប។ មានកម្មាភិបាលខ្មែរក្រហមពីប្រាំពីរទៅប្រាំបីនាក់ ជិះទូកជាមួយយើង។ ខ្ញុំបានចងចាំនៅពេលយើងឆ្លងកាត់ទីក្រុងភ្នំពេញ វាងងឹតនៅពេលយប់។ ខ្ញុំបានកត់សម្គាល់ថា គ្មានភ្លើងទេ។

ពួកយើងបានទៅដល់ប្រទេសវៀតណាមប្រហែលម៉ោងបួនប្រាំល្ងាចនៅថ្ងៃបន្ទាប់។ ពេលមកដល់ប្រទេសវៀតណាម គេបានដាក់យើងនៅលើឆ្នេរ ហើយអាជ្ញាធរវៀតណាមបានមកទទួល។ ខ្ញុំមិនបានឃើញមានការពិភាក្សាគ្នាណាមួយរវាងអាជ្ញាធរវៀតណាម និង កម្មាភិបាលខ្មែរក្រហមអំពីការដោះដូរមនុស្ស និង អង្ករ ហើយនិងអំបិលនោះទេ។ កិច្ចព្រមព្រៀងរវាងអាជ្ញាធរទាំងសងខាងនេះ ប្រហែលជាធ្វើឡើងពីមុនមកហើយ។ ពេលដែលយើងមកដល់ព្រំដែន ពួកគេបានពិនិត្យមើលម្តងទៀត ហើយនរណាជាខ្មែរ ឬក៏ចិនត្រូវទុកនៅលើទូក គេមិនអនុញ្ញាតឱ្យឡើងច្រាំងទេ ឯជនជាតិវៀតណាមវិញ គេអនុញ្ញាតឱ្យចុះពីទូកនៅព្រំដែនកម្ពុជាវៀតណាម។ ពួកវាបានគ្រប់គ្រង និងកំណត់អត្តសញ្ញាណថានរណាជាជនជាតិខ្មែរ នរណាជាជនជាតិវៀតណាម។ គេបានបង្ហាញជនជាតិវៀតណាមពីចំណោមជនជាតិខ្មែរ ពីព្រោះជនជាតិវៀតណាមនិយាយភាសាវៀតណាម ឯជនជាតិខ្មែរនិយាយភាសាខ្មែរ។”

បាទសូមទោសលោកប្រធាន ខ្ញុំមានប្រហែលជា១០នាទីទៀត ឬមួយខ្ញុំសង្ខេបតែចំណងជើងឯកសារ អ៎! ឈ្មោះឯកសារ ឬក៏លោកប្រធានអនុញ្ញាតឱ្យខ្ញុំ១០នាទីនៅថ្ងៃស្អែក។ សូមអស់លោកប្រធាន។

[១៦:០២:២៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយនៅទំនងនៅមានពេលវេលាច្រើនដែរ ហើយអ៊ីចឹងទំនងមិនអីទេ យើងនឹងអាចបន្តធ្វើនៅថ្ងៃស្អែកចុះ។

បាទ ហើយសវនាការនៅថ្ងៃនេះ ដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ទី២៤ ខែកុម្ភៈ ឆ្នាំ ២០១៦ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃស្អែកនៃអង្គជំនុំជម្រះនឹងបន្តធ្វើសវនាការដាក់បង្ហាញឯកសារគន្លឹះ ពាក់ព័ន្ធនឹងការប្រព្រឹត្តទៅលើក្រុមមនុស្សគោលដៅជាក់លាក់ចំពោះជនជាតិចាម ជនជាតិវៀតណាម ហើយនិងចំពោះអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ហើយបន្តបន្ទិចដោយសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងដោយសហមេធាវីការពារក្ដីលោក ខៀវ សំផន សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាដែលបានកំណត់នេះ។

ហើយបង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទាំងពីររូប លោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃអ.វ.ត.ក វិញចុះ និងបង្គាប់ឱ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅថ្ងៃស្អែកឱ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៣ នាទី)*